# ពុទ្ធិសាកលវិទ្យាល័យព្រះសីហមុនីរាជា

## ពុទ្ធិកមហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ និងវិទ្យាសាស្ត្រ

## ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ ជំនាន់ទី២

ប្រធានបទសិក្សា

«វេយ្យាករណ៍(សម្ព័ន្ធវិទ្យា)លោកស្ទូ មុយយៀង(សង្ខេប)»

ដឹកនាំដោយលោកសាស្ត្រាចារ្យ ឈិន សីហា

និស្សិតក្រុម១០ រាយនាមដូចខាងក្រោម៖

១. នួន សារ៉េត    ២. ថន ឆារៈ

៣. ឃីម វល្លី    ៤. អាហ្សីត រ៉ូសទី

ឆ្នាំសិក្សា២០២៣

# អារម្ភកថា

«វេយ្យាករណ៍» គឺជាក្បួនសម្រាប់បង្រៀននូវអក្ខរវិធីដើម្បីនឹងសរសេរ និយាយឱ្យបានត្រឹមត្រូវក្នុងភាសាខ្មែរ[1]។ ជាកម្មវត្ថុសំខាន់ណាស់ដែលអ្នកសិក្សាអក្សរសាស្ត្រខ្មែរ ក្នុងការសង្កេត អង្កេតក្នុងការប្រើប្រាស់ប្រចាំថ្ងៃទាំងជីវភាពរស់នៅ និងក្នុងកិច្ចការសរសេរនានា។ វេយ្យាករណ៍ ជាកម្មបទមួយដែលអ្នកសិក្សាអក្សរសាស្ត្រខ្មែរយកចិត្តទុកដាក់បំផុត ក្នុងការប្រើប្រាស់ក្បួនខ្នាតឱ្យបានច្បាស់លាស់ ល្អប្រសើរ និងប្រើប្រាស់ក្នុងកម្រិតខ្ពស់ក្នុងការប្រើប្រាស់ភាសា។ ក្នុងការសិក្សាវេយ្យាករណ៍ខ្មែរ កម្មវត្ថុសិក្សាមានច្រើនដូចជា ថ្នាក់ពាក្យ សម្ព័ន្ធ ល្បះ វចនៈសូរ សទ្ទតា ការបង្កើតពាក្យ។ល។ ដោយឡែកការសិក្សាទាំងអស់សុទ្ធតែមានភាពទូលំទូលាយ ប៉ុន្តែទោះជាយ៉ាងណា ការសិក្សាវេយ្យាករណ៍ តាមរយៈសៀវភៅ សម្ព័ន្ធវិទ្យា របស់លោកបណ្ឌិត្យសភាចារ្យ សូ មុយឃៀង មានគោលបំណងស្វែងយល់បន្ថែមលើពាក្យ ល្បះ និងឧទាហរណ៍ផ្សេងៗក្នុងការប្រើប្រាស់ពាក្យ ភាសាវេយ្យាករណ៍ប្រចាំថ្ងៃដោយរក្សាកម្មវត្ថុសិក្សាដដែល។

សូមអរគុណ!

ថ្ងៃពុធ ៣រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣

**និស្សិតបរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរនៃពុទ្ធិសាកលវិទ្យាល័យព្រះសីហមុនីរាជា**

[1] *ឌ. គាម (១៩៩៧) វេយ្យាករណ៍ដោយរូបភាពសម្រាប់ឧត្តមដ្ឋាន ភ្នំពេញ: បណ្ណាគារសេង នូន ហួត ទំព័រ១។*

# សេចក្តីថ្លែងអំណរគុណ


## សូមថ្លែងអំណរគុណជូនចំពោះ

ក្រុមយើងសូមថ្លែងអំណរគុណយ៉ាងកក់ក្តៅ ចំពោះ **លោកបណ្ឌិត ឈិន សីហា** ដែលជាសាស្ត្រាចារ្យដឹកនាំ។ សូមអរគុណដល់លោកគ្រូដែលបានចំណាយពេលវេលាបង្ហាត់បង្រៀន ណែនាំពន្យល់ដល់ក្រុមយើងខ្ញុំយ៉ាងយកចិត្តទុកដាក់កន្លងមក។

ទន្ទឹមនឹងនេះយើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ **លោកបណ្ឌិត សូរ ម៉ុយឡៀង** ផងដែរបាន បណ្តុះបណ្តាលធនធានជំនាន់ក្រោយ និងការបន្សល់ទុកនៅស្នាដៃល្អៗសម្រាប់អ្នកសិក្សាជំនាន់ក្រោយបំភ្លឺគំនិត។

ក្រុមយើងខ្ញុំបាទក៏សូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ ដែលជាថ្នាក់ដឹកនាំទាំងអស់ដែលបានប្រឹងប្រែងបណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយការអភិវឌ្ឍ ក្នុងការលើកស្ទួយវិស័យអប់រំប្រទេសជាតិយើងឲកាន់តែមានភាពរីកចម្រើនថែមទៀត។

ម្យ៉ាងវិញទៀតសូមថ្លែងអំណរគុណនិងអរព្រះគុណចំពោះសមាជិកក្រុមគ្រប់អង្គរូបគឺ ***ព្រះអង្គគុណម្ចាស់ នួន សារ៉េត លោកថន ធារៈលោកឃីម វរលី*** និង***លោកអាហ្សិត រ៉ុសទី*** ដែលបានចូលរួមយ៉ាងមមាញឹកដើម្បីការស្រាវជ្រាវសិក្សាសង្ខេបកិច្ចការស្រាវជ្រាវមួយនេះបានយ៉ាងល្អប្រសើរប្រកបដោយស្មារតីសាមគ្គី អភិវឌ្ឍ។

ជាចុងក្រោយក៏សូមថ្លែងអំណរគុណដល់មិត្តអ្នកអាន អ្នកសិក្សាទាំងអស់ផងដែរ ដែលបានសិក្សាវែកញែក យកចិត្តទុកដាក់ និងរិះគន់នូវចំណុចខ្វះខាតដើម្បីស្ថាបនាឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត។

## មាតិកា ទំព័រ

ផ្នែកទី១៖ សញ្ញាណទូទៅអំពីសម្ព័ន្ធវិទ្យា........- 1 -
១- អំពីសម្ព័ន្ធវិទ្យា........- 1 -
១.១- ប្រវត្តិនៃសម្ព័ន្ធវិទ្យា........- 1 -
១.២- និយមន័យ........- 1 -
១.៣- ទិដ្ឋភាពនៃសម្ព័ន្ធវិទ្យា........- 2 -

ផ្នែកទី២៖ ថ្នាក់ពាក្យ........- 3 -
១- អំពីថ្នាក់ពាក្យ........- 3 -
១.១- បច្ចេកសព្ទសម្គាល់ «ថ្នាក់ពាក្យ» និងនិយមន័យ........- 3 -
១.២. នាម........- 3 -
៣- គុណនាម........- 9 -
៤- សព្វនាម........- 19 -
៥- កិរិយាសព្ទ........- 25 -
៦- គុណកិរិយា ឬកិរិយាវិសេសន៍........- 31 -
៧- ចំណងធ្នាក់ ឬធ្នាក់........- 33 -
៨- ចំណងឈ្នាប់ ឬឈ្នាប់........- 34 -
៩. ឧទានសព្ទ........- 35 -

ផ្នែកទី៣៖ កន្សោមពាក្យ........- 36 -
១- អំពីកន្សោមពាក្យ........- 36 -
១.១- កន្សោមពាក្យ........- 36 -
១.២- ប្រភេទកន្សោមពាក្យ........- 36 -
២- កន្សោមនាម........- 37 -
២.១- ធាតុនៃកន្សោមនាម........- 37 -
២.២- ពង្រីកនៃកន្សោមនាម........- 40 -

២.៣- មុខងារកន្សោមនាមក្នុងល្បះ - 46 -
៣- កន្សោមគុណនាម និងកន្សោមគុណកិរិយា - 49 -
៣.១- កន្សោមគុណនាម( កគុ ) - 49 -
៣.២- កន្សោមគុណកិរិយា( កគុណ ) - 49 -
៤- កន្សោមមានធ្នាក់ - 50 -
៤.១- កម្មបទមិនផ្ទាល់( កបម ) - 50 -
៤.២- កម្មបទទី២ ( ក២ ) - 50 -
៤.៣- កម្មទេសកាល - 51 -

ផ្នែកទី៤៖ ល្បះ - 52 -
១.ល្បះជាអ្វី ? - 52 -
១.១- និយមន័យ - 52 -
១.២- ធាតុនៃល្បះ - 53 -
១.៣- ប្រភេទល្បះ - 55 -
២- ប្រភេទរង ( ម្នទម្រង់ ) នៃល្បះ - 59 -
២.១- ល្បះស្រប និងល្បះមិនស្រប - 59 -
២.២- ល្បះកត្តុនិងល្បះកម្ម - 62 -
២.៣- ល្បះធម្មតា និងល្បះសង្កត់ - 63 -
៣- បែបល្បះ - 66 -
៣.១- ល្បះគោល - 66 -
៣.២- ល្បះផ្សំ - 67 -
៣.៣- ល្បះក្រុង - 83 -
ឯកសារពិគ្រោះ - 84 -

# ផ្នែកទី១៖ សញ្ញាណទូទៅអំពីសម្ព័ន្ធវិទ្យា

## ១- អំពីសម្ព័ន្ធវិទ្យា

### ១.១- ប្រវត្តិនៃសម្ព័ន្ធវិទ្យា

សម្ព័ន្ធវិទ្យាបានកកើតឡើងដោយផ្អែកលើការសរសេរ។ តាមរយៈស្នាដៃលោកប៉ាញីនី( ស.វ. ទី៤ មុនគ.ស.) បានបង្ហាញពីវត្តមានសម្ព័ន្ធវិទ្យាក្នុងវេយ្យាករណ៍។ នៅបច្ចឹមប្រទេសគេបានបង្កើតសាលាបង្រៀនវេយ្យាករណ៍ប្រពៃណី (Traditional Grammar) ឈ្មោះថា « Dionysisus Thrax»នៃប្រទេសក្រិក។ ក្រោយមកគេបានចាត់ទុកសម្ព័ន្ធវិទ្យាជាវេយ្យាករណ៍ទូទៅ (អធិប្បាយដោយលោក Antoine Arnauld, Grammaire Générale, Philosophy of France, 1660)។

ក្រោយមកទៀតគេបានយកវេយ្យាករណ៍ Port-Royal ធ្វើជាគំរូនៃការសិក្សាសម្ព័ន្ធវិទ្យាដោយផ្ដោតលើតក្កវិជ្ជា(មួយផ្នែកធំនៃ Port-Royalចម្លងចេញពី Grammaire Générale)។ ថ្នាក់វាក្យសម្ព័ន្ធ (Syntactic categories)បានបង្កើតឡើងជាមួយតក្កវិជ្ជា និងត្រូវវិភាគល្បះទៅលើ ប្រធាន និងបម្រាប់ប្រធាន(subject-copular-predicate).

អារីស្តូត(Aristotle)បានចែកល្បះជា ប្រធាន(subject) និងបម្រាប់ប្រធាន(predicates)។ លុះការសិក្សាសម្ព័ន្ធវិទ្យាមានភាពរីកចម្រើនយឺត ក្នុងសតវត្សរ៍ទី២០ គេផ្ដោតតែចំពោះសទ្ទតាវិទ្យា (phonology) និងរូបសាស្ត្រ(morphology)ដោយមិនសម្ព័ន្ធវិទ្យាមិនបានរំលេចឡើងឱ្យច្បាស់នោះទេ ប៉ុន្តែវាបានដើរតួយ៉ាងសំខាន់ក្នុងទ្រឹស្តីភាសាវិទ្យាដែលគេហៅថា សតវត្សរ៍នៃទ្រឹស្តីសម្ព័ន្ធវិទ្យា(century of syntactic theory)។

លុះមកដល់ទសវត្សរ៍ទី៤០ ស.វ.ទី២០ ភាសាវិទូម្នាក់ឈ្មោះ Zelling Harris បានចាប់ផ្ដើមអភិវឌ្ឍវិធីថ្មី មានការចាប់អារម្មណ៍ចំពោះសម្ព័ន្ធវិទ្យានេះឡើងអស់កាលមួយទសវត្សរ៍ទើបកូនសិស្សរបស់លោកឈ្មោះ ណម ឆមស្គី( Noam Chomsky)បានបកស្រាយគំនិតគ្រូរបស់លោកគឺ Generative Grammar) និងផ្នែកសំខាន់ៗហៅថា វេយ្យាករណ៍បម្លែង(Transformational Grammar)។ លោកណម ឆមស្គីយល់ថាសម្ព័ន្ធវិទ្យាស្រួលក្នុងការបង្រៀន និងមានភាពលេចធ្លោរហូតមកដល់សព្វថ្ងៃនេះ ដែលមានទស្សនវិទូជាច្រើនបានដើរតាមទ្រឹស្តីរបស់លោកឆមស្គី និងយល់ឃើញថាសម្ព័ន្ធវិទ្យាជាស្នូលនៃភាសា។ នៅទ.ស.៦០, ស.វ.២០ ភាសាវិទូអាមេរិកម្នាក់ទៀតឈ្មោះ Joseph Greenberg បានបោះពុម្ពស្នាដៃរបស់ខ្លួនមួយគឺ Syntactic typology។

### ១.២- និយមន័យ

សម្ព័ន្ធវិទ្យា ជាវិទ្យាមួយដែលសិក្សាអំពីរចនាសម្ព័ន្ធ និងមុខងារនៅក្នុងល្បះ។[2]

[2] សូ មុយឃៀង (២០១៦) *មេរៀនសម្ព័ន្ធវិទ្យា* ភ្នំពេញៈ ឯកសារប្រើប្រាស់ផ្ទៃក្នុង ទំព័រ៤។

## ១.៣- ទិដ្ឋភាពនៃសម្ព័ន្ធវិទ្យា

សម្ព័ន្ធវិទ្យាផ្តោតសំខាន់លើរចនាសម្ព័ន្ធល្បះ( sentence structure )ហើយបែងចែកជាទិដ្ឋភាពគឺ ការដាក់ពាក្យជាក្រុម( grouping ) មុខងារពាក្យ( function ) និងលំដាប់ពាក្យ( word order )។ ទិដ្ឋភាពបីនៃរចនាសម្ព័ន្ធល្បះនេះ គឺបង្កើតឱ្យឃើញនៅក្នុងការតាងមែកធាងនៃល្បះ។

ឧទាហរណ៍៖ គោមួយក្បាលនេះស៊ីស្មៅលើវាលស្រែ។

**១.៣.១- ការដាក់ពាក្យជាក្រុម៖** គឺជាការប្រមូលផ្តុំពាក្យចូលក្នុងកន្សោមពាក្យដែលមានន័យ និងមុខងារ ហើយសមាសធាតុផ្សំនីមួយៗបង្កើតបានជាកន្សោមពាក្យផ្សេងៗទៀត។ ឧ. ល្បះ «គោមួយក្បាលនេះស៊ីស្មៅលើវាលស្រែ។» មានកន្សោមនាម កន ( noun phrase ) កន្សោមកិរិយា កកិ ( verb phrase ) និងកន្សោមមានធ្នាក់ កមធ ( prepositional phrase )។

**១.៣.២- មុខងារពាក្យ៖** ផ្តោតលើទំនាក់ទំនងកន្សោមនាម និងកន្សោមកិរិយា និងពាក្យផ្សេងទៀតក្នុងល្បះ។ វាមានមុខងារបីប្រភេទគឺ ទំនាក់ទំនងវេយ្យាករណ៍( grammatical ) ថ្នាក់ពាក្យ( part of speech ) និងទំនាក់ទំនងបង្គោលនិងរណប( relations of head and modifier )។

ឧ. ល្បះ «គោមួយក្បាលនេះស៊ីស្មៅលើវាលស្រែ។» យើងឃើញមាន មុខងារ ប្រធាន( subject ) កិរិយា( verb ) កម្មបទ( Object )។ល។

**១.៣.៣- លំដាប់ពាក្យ៖** ជាការរៀបចំពាក្យជាលំដាប់បន្តបន្ទាប់នៅក្នុងល្បះ។ ភាសាខ្លះមានលំដាប់ពាក្យក្នុងកន្សោមពាក្យ និងល្បះដូចគ្នា ខ្លះទៀតមានលំដាប់ពាក្យខុសគ្នា។

<u>**ល្បះមានលំដាប់ខុសគ្នា**</u>

ឧ. ល្បះខ្មែរ ៖ តុធំមួយ

ល្បះអង់គ្លេស៖ A big Table

<u>**ល្បះមានលំដាប់ដូច និងប្រហាក់ប្រហែល**</u>

ឧ. ល្បះខ្មែរ ៖ «គោមួយក្បាលនេះស៊ីស្មៅលើវាលស្រែ។»

ល្បះអង់គ្លេស៖ «This's a cow eating grass on the field.»

ឧ. ល្បះខ្មែរ ៖ «គាត់ស្រលាញ់កញ្ញាបុប្ផា។»

ល្បះអង់គ្លេស៖ «He love Mrs. Bubha. »

ល្បះបារាំង៖ « Il aime Mademoiselle Buppa.»

# ផ្នែកទី២៖ ថ្នាក់ពាក្យ

## ១- អំពីថ្នាក់ពាក្យ

### ១.១- បច្ចេកសព្ទសម្គាល់ «ថ្នាក់ពាក្យ» និងនិយមន័យ

ថ្នាក់ពាក្យជាបញ្ហាសំខាន់សម្រាប់វិភាគវេយ្យាករណ៍។ នៅក្នុងភាសាខ្មែរយើងសង្កេតឃើញថា មានបច្ចេកសព្ទច្រើនអំពីថ្នាក់ពាក្យដូចជា៖

- លោក ពូវ អ៊ុម បានប្រើ «ជំនំពាក្យ»។
- លោក រ៉ាយ ប៊ុក បានប្រើ «សង្កាត់សុន្ទរកថា»
- លោក កេង វ៉ាន់សាក់ បានប្រើ «សព្ទប្រភេទ»
- ភិក្ខុ ខៀវ ជុំ បានប្រើ «លក្ខណៈនៃពាក្យ»
- អ្នកនិពន្ធសៀវភៅវេយ្យាករណ៍ក្រសួងអប់រំបានប្រើពាក្យ «ថ្នាក់ពាក្យ» និង«ប្រភេទពាក្យ»។

ថ្នាក់ពាក្យ ជាប្រភេទពាក្យទាំងឡាយណាដែលកំណត់បានដោយទីតាំងក្នុងឃ្លាដូចគ្នា[3]។ ឧ. ចាត់ថាពាក្យណាមួយជា«កំណត់»ដោយសារវាស្ថិតនៅក្បែរនាមដែលវាបញ្ជាក់លក្ខណៈ ដូចជា «សៀវភៅមួយ»។ **មួយ** ជាពាក្យក្នុងថ្នាក់កំណត់។

ថ្នាក់ពាក្យក្នុងភាសាខ្មែរមាន៨គឺ

| | | |
|---|---|---|
| ១- នាម | អក្សរកាត់ជា | ន. |
| ២- គុណនាម | អក្សរកាត់ជា | គុ. |
| ៣- សព្វនាម | អក្សរកាត់ជា | សព្វ. |
| ៤- កិរិយា | អក្សរកាត់ជា | កិ. |
| ៥- គុណកិរិយា ឬកិរិយាវិសេសន៍ | អក្សរកាត់ជា | គុណ. ឬកិ.វិ. |
| ៦- ឈ្នាប់ | អក្សរកាត់ជា | ឈ. |
| ៧- ធ្នាក់ | អក្សរកាត់ជា | ធ. |
| ៨- ឧទានសព្ទ | អក្សរកាត់ជា | ឧ. |

### ១.២. នាម

#### ១.១.២.១- នាម

នាមគឺជាពាក្យសម្រាប់សម្តែងឈ្មោះមនុស្ស សត្វ រុក្ខជាតិ ទីកន្លែង ឬវត្ថុអ្វីមួយ។ ឧ. សុខា គោ ត្នោត សាលា ទូរសព្ទ...។

មានមាន៨ប្រភេទ គឺ៖

[3] ហាន សុខុម (១៩៩៨) *សទ្ទានុក្រមស័ព្ទទំនើប* ភ្នំពេញ លីដេខ្មែរ.ទំ៧៨

**១.២.១.១- នាមសាធារណ៍ ឬសាធារណនាម**

នាមសាធារណ៍ ឬនាមសាធារណនាម គឺជានាមស្តែងឈ្មោះទូទៅ មិនចំពោះ។ ឧ. មនុស្ស ចាប សាលា គុ ស្រូវ ...។

**១.២.១.២- នាមសាធារណ៍ ឬសាធារណនាម**

នាមអសាធារណ៍ ឬអសាធារណនាម គឺជានាមស្តែងឈ្មោះប្រាកដ មិនទូទៅ ដោយចំពោះ។ ឧ. មនុស្សស្រី ចាបពូក សាលាបុណ្យ គុបាយ ស្រូវផ្ការំដួល...។

**១.២.១.៣- នាមជីវចល**

នាមជីវចល ជានាមទាំងឡាយណា ដែលមានជីវិតប្រកបដោយញាណ និងមាមសកម្មភាពរស់រវើក ដើម្បីរស់នៅ។ នាមជីវចលសម្តៅដល់មនុស្ស និងសត្វនេះតែម្តង។[4]

ឧ. ជីតា តាសុក សំ មាន់ ទា ជ្រូក...។

**ចំណាំៈ នាមជីវចល** ឆ្លើយនឹងសំណួរថា ឯងឃើញនរណា?

ឆ្លើយ ឃើញមនុស្ស ឃើញសត្វ ឃើញកសិករ ឃើញក្របី...។

**១.២.១.៤- នាមអជីវចល**

នាមអជីវចល ជានាមទាំងឡាយណា ដែលគ្មាន ឬមានជីវិតដែរ តែមិនមានសកម្មភាពក្នុងការរស់នៅទេ។[5]

ឧ. ម៉ូតូ ដើមឈើ សៀវភៅ ស្បែកជើង...។

**ចំណាំៈ នាមអជីវចល** ឆ្លើយនឹងសំណួរថា ឯងឃើញអ្វី?

ឆ្លើយ ឃើញសៀវភៅ ឃើញទូ ឃើញកង់ ឃើញដើមឈើ...។

**១.២.១.៥- នាមរូបី**

នាមរូបី គឺជានាមបង្ហាញពីមនុស្ស សត្វ វត្ថុ ទីកន្លែង រុក្ខជាតិ ដែលយើងអាចដឹងដោយវិញ្ញាណ [6]។

នាមរូបីមានបីប្រភេទគឺ

- មើលឃើញប៉ះបានៈ កម្មករ កសិករ គោ ក្របី រុក្ខជាតិ វត្ថុនានា...។
- មើលឃើញប៉ះមិនបានៈ ព្រះអាទិត្យ ព្រះចន្ទ ពពក ផ្កាយ...។
- ស្រមៃឃើញតាមមនោគតិៈ ព្រះឥន្ទ ទេវៈ នាគ គ្រុឌ ...។

**១.២.១.៦- នាមអរូបី**

នាមអរូបី គឺជានាមបង្ហាញពីគុណភាព ភាពលក្ខណៈរបស់មនុស្ស សត្វ ឬវត្ថុ។[7]

---

[4] ឧ. គាម (១៩៩៧) *វេយ្យាករណ៍ដោយរូបភាពសម្រាប់ឧត្តមដ្ឋាន* ភ្នំពេញៈ បណ្ណាគារសេដ ទូន ហួត ទំព័រ៣២។

[5] ឧ. គាម (១៩៩៧) *វេយ្យាករណ៍ដោយរូបភាពសម្រាប់ឧត្តមដ្ឋាន* ភ្នំពេញៈ បណ្ណាគារសេដ ទូន ហួត ទំព័រ៣៣។

[6] ឈុន លិះ (២០០៧) *វេយ្យាករណ៍ខ្មែរ សម្រាប់គ្រប់ថ្នាក់* ភ្នំពេញ ទំព័រ២១។

[7] ឈុន លិះ (២០០៧) *វេយ្យាករណ៍ខ្មែរ សម្រាប់គ្រប់ថ្នាក់* ភ្នំពេញ ទំព័រ២២។

ឧ. ស្នេហា សេចក្ដីសុខ សេចក្ដីសង្ឃឹម  ភាពអង់អាច...។

**១.២.១.៧- នាមករណ៍ ឬករណនាម**

នាមករណ៍ ឬករណនាម គឺជានាមសម្ដែងសភាព ឬសកម្មភាព។

នាមករណ៍ ឬករណនាមមានដើមកំណើត២ប្រភពគឺៈ

**ក. កើតចេញពីកិរិយា**

| កិរិយា | នាមករណ៍ ឬករណនាម | កិរិយា | នាមករណ៍ ឬករណនាម |
|---|---|---|---|
| កើត | កំណើត | សង្កេត | ការសង្កេត |
| កក | កំណក | គោរព | ការគោរព |
| ធ្វើ | ទង្វើរ | រើសអើង | ភាពរើសអើង |
| កត់ | កំណត់ | មរណ | មរណភាព |
| នឹក | លំនឹក | ស្រលាញ់ | សេចក្ដីស្រលាញ់ |
| លើក | ល្បើក | អធិប្បាយ | សេចក្ដីអធិប្បាយ |

**ខ. កើតចេញពីគុណនាម**

| គុណនាម | នាមករណ៍ ឬករណនាម | គុណនាម | នាមករណ៍ ឬករណនាម |
|---|---|---|---|
| កាច | កំណាច | សុខ | សេចក្ដីសុខ |
| ខ្ពស់ | កម្ពស់ | ចម្រើន | សេចក្ដីចម្រើន |
| ក្រ | កម្រ | ថ្លៃថ្នូរ | ភាពថ្លៃថ្នូរ |
| ខ្លៅ | កម្លៅ | សម្បូរ | ភាពសម្បូរ |
| ល្អ | លម្អ | អច្ឆរិយ | អច្ឆរិយភាព |
| ធំ | ទំហំ | វីរៈ | វីរភាព |

**១.២.១.៨- នាមការក៍ ឬការកនាម**

នាមការក៍ ឬការកនាម គឺជានាមអ្នកធ្វើអំពើ។

នាមការក៍ ឬការកនាម មានកំណើត៣ប្រភពគឺៈ

- នាមការក៍ ឬការកនាមកើតពីនាម

  ( ន. + អ្នក- = អ្នកន. ឧ. អ្នក+ស្រែ>អ្នកស្រែ )

- នាមការក៍ ឬការកនាមកើតពីគុណនាម

  ( គុ. + អ្នក- = អ្នកគុ. ឧ.អ្នក+ក្រ>អ្នកក្រ )

- នាមការក៍ ឬការកនាមកើតពីកិរិយា

  ( កិ. + អ្នក- = អ្នកកិ. ឧ.អ្នក+ចាំ>អ្នកចាំ ឬឆ្មាំ )

ក. កើតចេញពីនាម

| នាម | នាមការក៍ ឬការកនាម | នាម | នាមការក៍ ឬការកនាម |
|---|---|---|---|
| ក្រុង | អ្នកក្រុង | ភ្នំ | អ្នកភ្នំ |
| ព្រៃ | អ្នកព្រៃ | ផ្ទះ | អ្នកផ្ទះ |
| ផ្សារ | អ្នកផ្សារ | ស្រុក | អ្នកស្រុក |

ខ. កើតចេញពីគុណនាម

| គុណនាម | នាមការក៍ ឬការកនាម | គុណនាម | នាមការក៍ ឬការកនាម |
|---|---|---|---|
| ធំ | អ្នកធំ | ខ្ពស់ | អ្នកខ្ពស់ |
| តូច | អ្នកតូច | ទាប | អ្នកទាប |
| មាន | អ្នកមាន | ខ្សត់ | អ្នកខ្សត់ |

គ. កើតចេញពីកិរិយា

| កិរិយា | នាមការក៍ ឬការកនាម | កិរិយា | នាមការក៍ ឬការកនាម | |
|---|---|---|---|---|
| យាម | អ្នកយាម | ចាំ | អ្នកចាំ | ឆ្មាំ |
| ពោល | អ្នកពោល | ដើរ | អ្នកដើរ | ថ្មើរ |
| ចម្លង | អ្នកចម្លង | កាន់ | អ្នកកាន់ | ក្មាន់ |

**ចំណុចបន្ថែម៖** នាមការក៍ ឬការកនាមបែបបាលី-សំស្រ្កឹត

- បន្ថែមចុង៖ -ករ, -ក, -ឥក, -ជន

  ឧ. កសិករ មគ្គុទេសក៍ ស្ថាបនិក ទុគ៌តជន...។

- បន្ថែមដើម៖ ជន-,

  ឧ. ជនពិការ, ជនឧក្រិដ្ឋ, ជនពាល...។

## ១.១.២.២- មុខងាររបស់នាមក្នុងល្បះ

នាមមានមុខងារ៨ក្នុងល្បះគឺ៖

### ១.១.២.២.១- មុខងារជាប្រធាន[8]

នៅខាងឆ្វេងកិរិយាសព្ទបង្គោល។

ឧ. <u>សំ</u>ដើរ។

[8] រ៉ា សោភា (២០១១) *ថ្នាក់ពាក្យ* ភ្នំពេញៈ ឯកសារប្រើប្រាស់ផ្ទៃក្នុង ទំព័រ១៨។

សំ ជា**ប្រធាន** នៃកិរិយា**ដើរ**។

**១.២.២.២- មុខងារជាកិរិយា**[9]

នៅខាងស្ដាំប្រធាន។

ឧ. មេឃ**ភ្លៀង**មិនរាំង។

**ភ្លៀង** ជាកិរិយារបស់ប្រធាន **មេឃ**។

**១.២.២.៣- មុខងារជាកម្មបទ**[10]

**ក. កម្មបទផ្ទាល់**

នៅជាប់ខាងស្ដាំកិរិយា( សកម្ម )បង្គោល។

ឧ. គោស៊ី**ស្មៅ**។

**ស្មៅ**ជាកម្មបទរបស់ប្រធាន**គោ** ដែលធ្វើកិរិយា **ស៊ី**។

**ខ. កម្មបទមិនផ្ទាល់**

នៅខាងស្ដាំកិរិយាបង្គោល។

ឧ. គោដើរលើភ្លឺស្រែស៊ី**ស្មៅ**។

**ស្មៅ**ជាកម្មបទមិនផ្ទាល់របស់ប្រធាន**គោ** ដែលធ្វើកិរិយា **ដើរ**។

**១.២.២.៤- មុខងារជាគុណនាម**[11]

នៅជាប់ខាងស្ដាំនាម ឬប្រធាន ឬនាមទី២ជាប់ខាងស្ដាំនាមទី១ គឺជាគុណនាម

ឧ. យុវជន**កម្ពុជា**។

**កម្ពុជា** ជាគុណនាម បញ្ជាក់លក្ខណៈឱ្យ**យុវជន**។

**១.២.២.៥- មុខងារជាគុណប្រធាន**[12]

នៅជាប់ខាងស្ដាំកិរិយាចំណាង **«ជា ក្លាយជា គឺជា ហាក់ជា ប្រែជា ដូចជា...»**

ឧ១. សំជា**និស្សិត**។

---

[9] *រ៉ា សោភា (២០១១) **ថ្នាក់ពាក្យ** ភ្នំពេញៈ ឯកសារប្រើប្រាស់ផ្ទៃក្នុង ទំព័រ១៧។*

[10] *រ៉ា សោភា (២០១១) **ថ្នាក់ពាក្យ** ភ្នំពេញៈ ឯកសារប្រើប្រាស់ផ្ទៃក្នុង ទំព័រ១៨។*

[11] *រ៉ា សោភា (២០១១) **ថ្នាក់ពាក្យ** ភ្នំពេញៈ ឯកសារប្រើប្រាស់ផ្ទៃក្នុង ទំព័រ១៧។*

[12] *សូ មុយឃៀង (២០១៦) **មេរៀនសម្ព័ន្ធវិទ្យា** ភ្នំពេញៈ ឯកសារប្រើប្រាស់ផ្ទៃក្នុង ទំព័រ១៨។*

**និស្សិត**ជាគុណប្រធាននៃប្រធាន**សំ**។

ឧ₂. ជីតាក្មេងកំព្រាក្លាយជា**<u>បញ្ញវន្ត</u>**មួយរូប។

**បញ្ញវន្ត**ជាគុណប្រធាននៃកន្សោមនាមប្រធាន**ជីតាក្មេងកំព្រា**។

**១.២.២.៦- មុខងារជាឧបបទ**[13]

នៅជាប់ខាងស្តាំនាម ជានាមទី២ដែលបញ្ជាក់ន័យឱ្យនាមទី១

ឧ₁. ប្រជាជន**<u>ខ្មែរ</u>** ចូលចិត្តពិសាទឹកត្នោតផ្អែម។

**ខ្មែរ**ជាឧបបទបញ្ជាក់ន័យឱ្យកាន់តែច្បាស់ នៃពាក្យ**ប្រជាជន**។

ឧ₂. ពូសំ**<u>ឪពុកនាងសីមា</u>** ជាកសិករ។

**ឪពុកនាងសីមា**ជាឧបបទបញ្ជាក់ន័យឱ្យកាន់តែច្បាស់ នៃឈ្មោះ**ពូសំ**។

**១.២.២.៧- មុខងារជាគុណកិរិយា**[14]

នៅខាងស្តាំជាប់កិរិយាបង្គោល

ឧ₁. សំទៅ**<u>ផ្សារ</u>**។

**ផ្សារ** ជាគុណកិរិយា បញ្ជាក់លក្ខណៈឱ្យកិរិយា **ទៅ**។

ឧ₂. នាង និងម្តាយនាងមក**<u>ភ្នំពេញ</u>**។

**ភ្នំពេញ** ជាគុណកិរិយា បញ្ជាក់លក្ខណៈឱ្យកិរិយា **មក**។

**១.២.២.៨- មុខងារជានាមរនាប់**

នៅខាងស្តាំគុណនាមចំនួន

ឧ. សាលារៀនមួយមាន២០**<u>បន្ទប់</u>**។

**បន្ទប់** ជានាមរនាប់បញ្ជាក់បន្ទប់ចំនួន២០។

**១.២.២.៩- មុខងារជាកម្មបំពេញបទ** [15]

នៅខាងស្តាំអាយតនិបាត

ឧ₁. ការមកដល់នៃ**<u>រទេះភ្លើង</u>**។

---

[13] ឈុន លិះ (២០០៧) *វេយ្យាករណ៍ខ្មែរ សម្រាប់គ្រប់ថ្នាក់* ភ្នំពេញៈ បណ្ណាគារបន្ទាយស្រី ទំព័រ៣២។

[14] វ៉ា សោភា (២០១១) *ថ្នាក់ពាក្យ* ភ្នំពេញៈ ឯកសារប្រើប្រាស់ផ្ទៃក្នុង ទំព័រ១៨។

[15] សូ មុយឃៀង (២០១៦) *មេរៀនសម្ព័ន្ធវិទ្យា* ភ្នំពេញៈ ឯកសារប្រើប្រាស់ផ្ទៃក្នុង ទំព័រ១៨។

**វទះភ្លើង** ជាកម្មបំពេញបទរបស់ **ការមកដល់**។

ឧ២. មួកមួយរបស់<u>**កម្មករម្នាក់**</u>។

**កម្មករម្នាក់** ជាកំពេញបទរបស់**មួកមួយ**។

### ១.២.២.១០- មុខងារជាពង្រីកមិនរណប[16]

ឧទហរណ៍៖ បងស្រីសំ និង**បងប្រុស**សំទៅស្រែ។ (បើថែម នៃ ចន្លោះបងប្រុស និងសំ។ សំជាកម្មបំពេញបទឱ្យ បងប្រុស។)

«បងស្រីសំ» ជាប្រធានរបស់កិរិយា **ទៅ**។

«បងប្រុសសំ» ក៏ជាប្រធានរបស់កិរិយា **ទៅ**ដែរ។

«និង» ជាឈ្នាប់សម្រាប់ចងកន្សោមនាមប្រធានទាំងពីរគឺ «បងស្រីសំ» និង«បងប្រុសសំ»

ល្បះនេះចេញមកពី

- បងស្រីសំទៅស្រែ។
- បងប្រុសសំទៅស្រែ។

រួមមក៖ បងស្រីសំ និងបងប្រុសសំទៅស្រែ។ គឺមាន «ពង្រីកមិនរណប» កាលណា**បន្ថែមមុខងារ**ដូចគ្នានឹង**មុខងារធាតុចាស់**(បងស្រីសំ)។

បើគេលប់**ធាតុចាស់**(បងស្រីសំ)និង**ឈ្នាប់**(និង)ចោល គេនឹងឃើញ**ទម្រង់ដំបូង**(បងស្រីសំទៅស្រែ)ត្រលប់មកវិញ។

## ៣- គុណនាម

គុណនាមជាពាក្យសម្រាប់បញ្ជាក់លក្ខណៈឱ្យនាម ឬប្រធាន។

ឧ. តូច ធំ ទាប ខ្ពស់ ធាត់ ស្គម ...។

### ៣.១- ថ្នាក់រងនៃគុណនាម

គុណនាមបែងចែកជាពីរគឺ

- គុណនាមប្រក្រតី
- គុណនាមកំណត់

[16] សូ មុយឃៀង (២០១៦) *មេរៀនសម្ព័ន្ធវិទ្យា* ភ្នំពេញៈ ឯកសារប្រើប្រាស់ផ្ទៃក្នុង ទំព័រ១៨។

### ៣.១.១- **គុណនាមប្រក្រតី**

ឧ. គោ**ខ្មៅ** និងគោ**ស**ស៊ីស្មៅលើវាល**ធំ**មួយ។

ពាក្យថា «ខ្មៅ ស ធំ» ជាគុណនាមប្រក្រតី ប្រាប់លក្ខណៈរបស់នាមដែលនៅឆ្វេងរបស់វា។

គុណនាមប្រក្រតីមានដទៃទៀត

| | | | |
|---|---|---|---|
| ខ្ពស់ | ទាប | ជិត | ឆ្ងាយ |
| វែង | ខ្លី | ស្លូត | កាច |
| ស្គម | ធាត់ | ថោក | ថ្លៃ |
| តូច | ធំ | ខ្លាំង | ខ្សោយ |

### ៣.១.១.១- **សម្ព័ន្ធសាស្ត្រគុណនាមប្រក្រតី**

**ក. ប្រភេទគុណនាម៖** គុណនាមប្រក្រតីបំពេញន័យរបស់នាម។ គុណនាមកំណត់សម្រាប់កំណត់ ឬកម្រិតដែនន័យរបស់នាម។

- នាម + គុណនាមប្រក្រតី + គុណនាមកំណត់៖

ឧ. **ទងត្រឡាច*ក្រង*នោះ** មើលទៅ**ល្អណាស់**។

**ខ. មុខងារគុណនាមប្រក្រតី៖**

- **មុខងារជាគុណបទ ដែលជាធាតុមួយនៃកន្សោមនាម**

**នៅជាប់ខាងស្តាំនាម**

ឧ. តុម្ហូល ប៊ិកក្រហម ផ្ទះបុរាណ...។

**មូល ក្រហម បុរាណ** ជាគុណនាមមាននាទីជាគុណបទនៃនាម **តុ ប៊ិក និងផ្ទះ**។

**នៅចន្លោះនាម និងកំណត់**

ឧ. ខោ អាវក្រហមនេះថ្មីស្អាត។

**ក្រហម** ជាគុណបទនៅចន្លោះនាម **អាវ** និងកំណត់ **នេះ**ដែលជាប់ខាងស្តាំគុណនាម។

**គុណនាមតែមួយ អាចជាគុណបទរបស់នាមច្រើនបាន**

ឧ. ខោ អាវក្រហមមួយបន្លាស់។

**ក្រហម** ជាគុណបទនៃនាមពីរគឺ **អាវ** និង**ខោ**។

- កាលណាគុណនាមប្រក្រតីនៅក្នុងកន្សោមកិរិយាដែលមានកិរិយា **ជា ហាក់ដូចជា ក្លាយជា ...** វានឹងក្លាយជាធាតុសំខាន់នៃកន្សោម

នៅជាប់ខាងស្ដាំកិរិយា **ជា ហាក់ដូចជា ក្លាយជា ...**

ឧ. វាលស្រែក្លាយជា**ខៀវ**ស្រងាត់។

គុណនាម **ខៀវ** ក្លាយជាធាតុសំខាន់នៃកន្សោម និងមាននាទីជាគុណប្រធាន នៃប្រធាន **វាលស្រែ**។

### ៣.១.១.២- រូបរាង និងន័យ

**ក. រូបរាង៖** គេចែកគុណនាមជាច្រើនថ្នាក់តាមរូបរាងរបស់វា។

- **គុណនាមកំណើត** ជាពាក្យមានកំណើតជាអ្នកបញ្ជាក់លក្ខណៈឱ្យនាមឬប្រធាន។ ដូចជា៖

ល្អ អាក្រក់ ពូកែ លឿន លឿង ជូ ប្រៃ...។

- **គុណនាមកម្លាយ៖** ពាក្យក្លាយពីពាក្យឫសជាគុណនាមកម្លាយ។ ដូចជា៖

កំពៀច សម្ងក់ កញ្ជោត សម្លឹក កញ្ចាស់...។

- **គុណនាមបន្សំ៖** ពាក្យកើតពីការផ្សំពាក្យនៅជាប់ខាងស្ដាំគេ ជាគុណនាមបន្សំ។ ដូចជា៖

ស្មើរ**ភ្លើង** ដូរ**អែម** សាប**មាត់** ទឹក**ក្ដៅ** ក្ដុំ**ភ្លើង**...។

**ក. ន័យ៖** គេចែកន័យរបស់គុណនាមជាច្រើនតាមន័យរបស់វា។

- **គុណនាមជីវចល និងអជីវចល៖** គុណនាមដែលអាចប្រើចំពោះតែនាមជីវចល គឺជាគុណនាមជីវចល។ ឯគុណនាមដែលប្រើចំពោះតែនាមអជីវចល គឺជាគុណនាមអជីវចល។

ឧ១. មនុស្ស**ដួល**។ មនុស្ស**ចាស់**។

**ដួល**ជាកិរិយាអកម្ម មានន័យជាគុណនាមជីវចល ប្រើចំពោះនាមជីវចល **មនុស្ស**។
**ចាស់**ជាគុណនាមប្រក្រតីមានន័យជាគុណនាមជីវចល ប្រើចំពោះនាមជីវចល **មនុស្ស**។

ឧ២. ឈើ**ដួល**។ ឈើ**ចាស់**។
**ដួល**ជាកិរិយាអកម្ម មានន័យជាគុណនាមអជីវចល ប្រើចំពោះនាមជីវចល **ឈើ**។

**ចាស់**ជាគុណនាមប្រក្រតីមានន័យជាគុណនាមអជីវចល ប្រើចំពោះនាមជីវចល **ឈើ**។

**ចំណាំ៖ គុណនាមអាចមានន័យចំ និងន័យធៀប កាលបើប្រើជាមួយនាមជីវចល និងអជីវចល**

**ឧ.** ស្លឹកឈើ**ស្រពោន**។ **ស្រពោន**មាន**ន័យចំ**។

មុខ**ស្រពោន**។ **ស្រពោន**មាន**ន័យធៀប**។

- **<u>គុណនាមថេរ និងអថេរ៖</u>** គុណនាមខ្លះសម្តែងសភាពស្ថិតស្ថេរ អចិន្តាយ: ឯខ្លះមិនភាពប្រែប្រួល មិនស្ថិតស្ថេរ។

ឧ១. តុនេះ**<u>ទាប</u>**។ តុនោះ**<u>ខ្ពស់</u>**។

គុណនាម **ទាប** និង**ខ្ពស់**ជាគុណនាមថេរ។

ឧ២. រុក្ខជាតិខែប្រាំង **<u>ក្រៀមស្រពោន</u>**។ លុះភ្លៀងមួយមេប្រែជា**<u>ស្រស់ស្រងាត់</u>**។

គុណនាម **ក្រៀមស្រពោន** និង**ស្រស់ស្រងាត់**ជាគុណនាមអថេរ។

- **<u>គុណនាមរូបី និងអរូបី៖</u>** គុណនាមខ្លះបង្ហាញលក្ខណៈសម្បត្តិរូបី ខ្លះអរូបី។

ឧ១. តុរាង**<u>មូល</u>**។ កៅអីរាង**<u>ជ្រុង</u>**។

**មូល** និង**ជ្រុង**ជាគុណនាមរូបី ដែលបង្ហាញលក្ខណៈរបស់តុ និងកៅអី។

ឧ២. សុខជាសិស្ស**<u>ពូកែ</u>** និងមានចរិត**<u>ស្មោះត្រង់</u>**។

**ពូកែ** និង**ស្មោះត្រង់**ជាគុណនាមអរូបី ដែលមិនអាចបង្ហាញលក្ខណៈឱ្យឃើញ ឬប៉ះបានទេ។

- **<u>គុណនាមសកម្ម និងអសកម្ម</u>**៖ គុណនាមខ្លះសកម្ម មានកម្មបំពេញបទនៅជាប់ជាមួយ។

ឧ១. សុខជាមិត្ត**<u>ស្និទ្ធ</u>**នឹងសៅ។

ឧ២. សៅជាមនុស្ស**<u>ស្មោះត្រង់</u>**នឹងមាតុភូមិ។

**ស្និទ្ធ** និង**ស្មោះត្រង់** ជាគុណនាមសកម្ម ព្រោះមាន **សៅ** និង**មាតុភូមិ**ជាកម្មបំពេញបទ។

ឧ១. សុខជាមិត្ត**<u>ល្អណាស់</u>**។

ឧ២. សៅជាមនុស្ស**<u>ស្មោះត្រង់</u>**។

**ល្អណាស់** និង**ស្មោះត្រង់** ជាគុណនាមអកម្ម ព្រោះគ្មានកម្មបំពេញបទ។

### ៣.១.១.៣- ឥន្លែង

ជាធម្មតាគុណនាមប្រក្រតីនៅខាងស្តាំជាប់នឹងនាម។

ឧ. មនុស្ស**<u>ល្អ</u>**កម្រនឹងរកបាន។ សៅជាក្មេង**<u>ឧស្សាហ៍</u>**ព្យាយាមចំពោះការងារ។

គុណនាមប្រក្រតី អាចនៅចន្លោះនាម និងកំណត់។

ឧ. ប៊ិក(ន.)**<u>ខៀវ</u>**នេះ(កំណត់ចង្អុល)។ គោ(ន.)**<u>ចាស់</u>**មួយ(កំណត់ចំនួន)នោះដើរទៅត្បូង។

### ៣.១.២- អំពីគុណនាមកំណត់

គុណនាមកំណត់ ជាគុណនាមសម្រាប់បង្ហាញភាពច្បាស់លាស់ ឬមិនច្បាស់លាស ជិតឆ្ងាយជាដើម។

#### ៣.១.២.១- នាទី

ក្នុងឧទាហរណ៍៖

- ផ្ទះ<u>នេះ</u>ល្អ។ **នេះ** ជាពាក្យប្រាប់ទីជិត(ច្បាស់លាស់)
- ផ្ទះ<u>មួយ</u>នៅទីនោះ។ **មួយ** ជាពាក្យប្រាប់សភាពទោល(មិនច្បាស់លាស់)
- ផ្ទះខ្ញុំនៅទីនេះ។ ខ្ញុំ ជាពាក្យប្រាប់ម្ចាស់វត្ថុ(ច្បាស់លាស់)

#### ៣.១.២.២- ថ្នាក់រងនៃគុណនាមកំណត់

**ក. គុណនាមចង្អុល៖** ជាគុណនាមសម្រាប់ចង្អុលបង្ហាញមនុស្សសត្វវត្ថុរុក្ខជាតិទីកន្លែង ក្នុងទីជិត និងទីឆ្ងាយ ក្នុងស្ថានភាពបែបណាមួយ ឬបង្ហាញអ្វីដែលគេទើបនឹងប្រាប់ ឬប្រុងនឹងប្រាប់។

- **ពាក្យ នេះ នោះ** នៅជាប់ខាងស្ដាំនាម គឺជា**គុណនាមចង្អុល** ។
  **ឧ**១. ផ្ទះ<u>**នេះ**</u> វាឈរអមផ្លូវលំ។ **នេះ** ជាគុណនាមចង្អុលទីនៃផ្ទះ(ជិត)។
  **ឧ**២. ផ្ទះ<u>**នោះ**</u> វាឈរអមផ្លូវលំ។ **នេះ** ជាគុណនាមចង្អុលទីនៃផ្ទះ(ឆ្ងាយ)។
- **បង្ហាញអ្វីៗដែលនៅជិតខ្លួន ឬអ្វីដែលគេបម្រុងនឹងចង្អុលប្រាប់**
  **ឧ.** ប៊ិក និងសៀវភៅ**នេះ** ជារបស់គាត់។

**នេះ** ជាគុណនាមចង្អុលបង្ហាញអ្វីៗដែលនៅជិតខ្លួន ឬអ្វីដែលគេបម្រុងនឹងចង្អុលប្រាប់។ វាអាចប្រាប់នាមនីមួយៗ និងនាមរួមគ្នាបាន។

- **បង្ហាញអ្វីៗដែលនៅឆ្ងាយ ឬបង្ហាញអ្វីៗដែលគេទើបនឹងប្រាប់**
  **ឧ.** ប៊ិក និងសៀវភៅ**នោះ** ជារបស់គាត់។

**នោះ** ជាគុណនាមចង្អុលបង្ហាញអ្វីៗដែលនៅឆ្ងាយពីខ្លួន ឬអ្វីដែលគេទើបនឹងតែប្រាប់ និង**បង្ហាញអ្វីៗដែលនៅឆ្ងាយ មើលទៅឃើញ**។ វាអាចប្រាប់នាមនីមួយៗ និងនាមរួមគ្នាបានដូចគ្នា។

- **កំណត់ចង្អុលអាចប្រើជាមួយកំណត់ដទៃទៀតបាន**

  **ឧ.** ប៊ិក និងសៀវភៅ**នោះ** ជារបស់គាត់**នេះ**។

**នេះ** ជាគុណនាមកំណត់ចង្អុលបង្ហាញអ្វីៗដែលនៅឆ្ងាយ។ **នោះ** គុណកំណត់នាមចង្អុលដែរ។ កំណត់ចង្អុលវានៅខាងចុងបំផុតនៃកន្សោមនាម វាជាកំណត់ច្បាស់លាស់។

**ខ. គុណនាមកម្មសិទ្ធិ(បុរិសៈ)៖** គុណនាមកម្មសិទ្ធិ(គុណនាមបុរិសៈ)ជាគុណនាមបង្ហាញម្ចាស់កម្មសិទ្ធិ។ វាទាក់ទងនឹងសព្វនាមបុរិសៈ។

- **បង្ហាញកម្មសិទ្ធិ ឬបុរិសៈ**

ឧ. ស្រូវ<u>គាត់</u>។ កំហុស<u>វា</u>។ ខ្ញុំបញ្ចប់ការងារ<u>ខ្ញុំ</u>រួចហើយ។

ពាក្យ **គាត់ វា ខ្ញុំ(គេ ពួកគេ យើង...)** ជាគុណមានកម្មសិទ្ធិ។

- **គុណនាមកម្មសិទ្ធិមានៈ**
    - **បុរសទី១ ៖** ខ្ញុំ អញ យើង(ពហុ) ...។
    - **បុរសទី២ ៖** ឯង អ្នក លោក ឯងទាំងអស់គ្នា(ពហុ)...។
    - **បុរសទី៣ ៖** វា គាត់ គេ ពួកគាត់(ពហុ)...។

**ចំណាំ៖** នាម + បុរិសៈ។ បុរិសៈនោះ គឺគុណនាមកម្មសិទ្ធិ។ គុណនាមកម្មសិទ្ធិនៅជាប់ខាងស្ដាំនាម ឬកន្សោមនាម។

**គ. គុណនាមសំណួរ៖** គុណនាមសំណួរប្រើសម្រាប់សួរឯកលក្ខណភាព (ច្បាស់លាស់ពុំអាចច្រឡំបាន)។

- **សួររកឯកលក្ខណភាព**
    - ហុច<u>**កណ្ដៀវមួយ**</u>មកខ្ញុំសិន។ (គុណនាមមិនច្បាស់)
    - កណ្ដៀវ<u>មួយ**ណា**</u>? (សួររកលក្ខណភាព)
    - កណ្ដៀវ<u>**ឯង**</u>។ (បង្ហាញកម្មសិទ្ធិ)
    - ចុះឯងត្រូវការកណ្ដៀវ<u>**ប៉ុន្មាន**</u>?(សួររកចំនួន)
- **ការប្រើប្រាស់គុណនាមសំណួរ**

| | | |
|---|---|---|
| **នាម** | + | **អ្វី អ្វីមួយ អ្វីខ្លះ...**<br>**ណា ណាមួយ ណាខ្លះ...**<br>**អី ស្អី ប៉ុន្មាន...** |

**ទីតាំង៖** គុណនាមសំណួរ ក៏ដូចជាគុណនាមកំណត់ដទៃទៀតដែរ វានៅខាងស្ដាំនាម។

**ចំណាំ៖** គុណនាមសំណួរ ជាគុណនាមកំណត់មិនច្បាស់លាស់។

**ឃ. គុណនាមចំនួន៖** គុណនាមចំនួនប្រើសម្រាប់បញ្ជាក់ថ្នាក់ឯកតា កម្រិត ចំនួនឯកតា ឬបរិមាណរបស់នាមឬប្រធាន(មនុស្ស សត្វ វត្ថុ រុក្ខជាតិ ទីកន្លែង។ល។)

គុណនាម ចំនួនមានពីរប្រភេទគឺ៖

- **ចំនួនរាប់ (បកតិសំខ្យា)**

**នៅជាប់ខាងស្ដាំនាម**

ឧ. ខ្ញុំបានឃើញរទេះ**មួយ**គ្រឿងនៅទីនោះ មានគោ**ពីរ**ក្បាល និងសុនក**មួយ**ក្បាលនៅឃាមម្ចាស់**បី**នាក់ ម្ដាយ ឪពុក និងកូន។

គុណនាមចំនួន **មួយ ពីរ បី...** ជាគុណនាមចំនួនបញ្ជាក់ចំនួននាម ប្រធាន ឬកម្មបទណាមួយ។

- **របាប់ចំនួនលេខ**
  **១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០**
  **១០ ២០ ៣០ ៤០ ៥០ ៦០ ៧០ ៨០ ៩០ ១០០**
  **១ ០០០ ១០ ០០០ ១០០ ០០០...**

នៅខាងឆ្វេងនាម និងខាងស្ដាំនាមអាចមានន័យខុសគ្នា អាចមានន័យដូចគ្នា

ឧ១. យកស្រូវ**បី**ល្អីមកត្រង់នេះ។ គុណនាមចំនួន **បី** បង្ហាញចំនួនស្រូវមានចំណុះបីដងនៃល្អី។

ឧ២.យកល្អី**បី**មកត្រង់នេះ។ គុណនាមចំនួន **បី** បង្ហាញចំនួនល្អី។

- **ចំនួនរៀប(បូរណសំខ្យា)**

**នៅជាប់ខាងស្ដាំនាម**

**ឧ.** និស្សិតជំនាន់**ទី៤** កម្រិត**ទី១** មានចំនួនកើនបីដងបើធៀបនឹងនិស្សិតជំនាន់**ទី៣** កម្រិត**ទី១**

**ទី៤ ទី១ ទី៣** ជាចំនួនរៀប។ ចំនួនរៀបបង្ហាញកំណត់រាប់ថែមពាក្យ «**ទី គម្រប់ លេខ ថ្នាក់ ជាន់...**»

| | | | | |
|---|---|---|---|---|
| **ទី** | + | **មួយ** | > | **ទី១** |
| **គម្រប់** | + | **ពីរ** | > | **គម្រប់ពីរ(ដង)** |
| **លេខ** | + | **បី** | > | **លេខបី** |
| **ថ្នាក់** | + | **បួន** | > | **ថ្នាក់(ទី)បួន** |
| **ជាន់** | + | **ប្រាំ** | > | **ជាន់(ទី)ប្រាំ** |

**សម្គាល់៖ គេអាចនិយាយ**

- ម៉ោង២ ម៉ោង៣ ជំពូក៤ មាត្រា៥...
- មួយដណ្ដប់(មួយ និងដប់) ពីរដណ្ដប់(ពីរ និងដប់)...
- បម្រែបម្រួលន័យតាមទីតាំងរបស់គុណនាមចំនួន និងនាមរនាប់
  - ម៉ោង៥ អញ្ជើញចូលរួមកម្មវិធីសិក្សាចំនួន ៥ម៉ោង។ ម៉ោង៥ គឺពេលវេលាម៉ោងទី៥ ឯ ៥ម៉ោងគឺចំនួនច្បាស់លាស់ មួយម៉ោងចំនួនប្រាំដង។

**ង. គុណនាមមិនច្បាស់៖** ជាគុណនាមប្រាប់សេចក្តីមិនជាក់លាក់។

នៅជាប់ខាងស្តាំនាម

ឧ. តើអ្នកចង់បានសៀវភៅ**អ្វី**? ចំណាងជើង**ដូចម្តេច**? សៀវភៅ**នីមួយៗ**ថ្លៃ២០០០៛។

**អ្វី ដូចម្តេច នីមួយៗ**ដែលនៅជាប់ខាងស្តាំនាម គឺជាគុណមានមិនច្បាស់។

- **ចំនួន ឬបរិមាណស្មើនឹងសូន្យ** គ្មាន..(ន.)..ណា គ្មាន..(ន.)..អ្វី គ្មាន..(ន.)..ណាម្នាក់ មិនមាន..(ន.)..អ្វីមួយទេ...។ ឧ. គ្មានសៀវភៅ**ណាមួយ**ទេ។
- **ចំនួន ឬបរិមាណស្មើនឹងឯកតា** ម្នាក់ៗ នីមួយៗ មួយៗ មួយក្បាលៗ ...។ មនុស្ស**ម្នាក់ៗ**ជាសត្វលោក។
- **ចំនួន ឬបរិមាណលើសពីមួយ** ច្រើន ខ្លះ ខ្លះៗ ផ្សេងៗ...។ មនុស្ស**ខ្លះ**ចូលចិត្តរៀន ជាងស្រាវជ្រាវ។
- **ចំនួន ឬបរិមាណសរុប(សំណុំ)** ទាំងអស់ ទាំងមូល ទាំងពួង ទាំអឡាយ គ្រប់ រាល់ ...។ គោ**ទាំងអស់**។
- **ការប្រៀបគ្នា** ដូចគ្នា ដូចដែល ដដែល ដទៃ ឯទៀត ដូចហ្នឹង...។ មនុស្ស**ឯទៀត**...។

### ៣.១.២.៣- កន្លែងនៃគុណនាមកំណត់

គុណនាមកំណត់ច្រើនតែនៅខាងស្តាំនាម ក្នុងកន្សោម។ គុណមានកំណត់ខ្លះអាចប្រើបានតែម្នាកឯង ឯខ្លះទៀតអាចប្រើបានជាមួយកំណត់ដទៃទៀតបាន។

ឧទាហរណ៍៖

- មនុស្ស**ម្នាក់ៗ**ត្រូវតែសិក្សារៀនសូត្រ។
- គោ**ពីរ**ក្បាលនេះដើរលើភ្លឺស្រែ។
- ចេកខ្ញុំ**ពីរស្និត**ទុំល្អណាស់។

**យើងអាចរៀបគុណនាមកំណត់បានដូចនេះ៖**

នាម + គុណនាមកម្មសិទ្ធិ + គុណនាមចំនួន + នាមរនាប់ + គុណនាមចង្អុល

| | | | | |
|---|---|---|---|---|
| គោ + | ខ្ញុំ + | បី | + ក្បាល | + នោះស៊ីស្មៅលើវាលស្រែ។ |
| ស្រែ + | ពូសុខ + | បី | + កន្លែង | + នៅជាប់បឹងទន្លេសាប។ |

### ៣.២- កំណើតគុណនាម

គុណនាមមានកំណើតចេញពី៖

### ៣.២.១- នាម (មាននាទីជាគុណនាម ឬប្រើជាគុណនាម)

| នាម | គុណនាម |
|---|---|
| ស៊ុបទ្រប់ | ឈើស៊ុបទ្រប់ |
| តំណាល | រឿងតំណាល |
| ត្រក | យុវជនត្រក |
| ខ្មែរ | ប្រជាជនខ្មែរ |
| ឈើ | តុឈើ |
| កែវ | ថ្មកែវ |

### ៣.២.២- គុណនាម

| គុណនាម | គុណនាម |
|---|---|
| ពៀច | កំពៀច |
| ចាស់ | កញ្ចាស់ |
| ខ្ចិល | កម្ចិល |
| ស្ទីក | សម្ទីក |
| ស្ទើង | សម្ទើង |
| លឿង | ល្មឿង |

### ៣.២.៣- កិរិយាសព្ទ

| គុណនាម | គុណនាម |
|---|---|
| ភូត | កំភូត |
| ភរ | កំភរ |
| ប្រទល់ | ព្រំប្រទល់ |
| រមួល | រាគរមួល |

### ៣.៣- កំណើតគុណនាម

កម្រិតគុណនាមមាន៣យ៉ាងគឺ

- កម្រិតវិជ្ជមាន
- កម្រិតទាក់ទង ឬប្រៀបធៀប
- កម្រិតដាច់ខាត ឬគ្មានទំហៀប

#### ៣.៣.១- កម្រិតវិជ្ជមាន

កម្រិតវិជ្ជមាននៃគុណនាម គឺជាការសម្តែងគុណភាព មនុស្ស សត្វ វត្ថុ ដែលកើតឡើង ដោយសារប្រើគុណនាមប្រក្រតីតែឯងប៉ុណ្ណោះ គឺជាកម្រិតវិជ្ជមាន(នៃការសម្តែងជាគុណនាម)៖

ឧទាហរណ៍៖

- សុខជាសិស្ស**សុភាពរាបសារ**។
- សៅជាកម្មករ**ស្លូតត្រង់**។
- សានជាកម្មករ**ជំនាញ**។

ពាក្យថា **សុភាពរាបសារ ស្លូតត្រង់ ជំនាញ** ជាគុណនាមកម្រិតវិជ្ជមាន។

#### ៣.៣.២- កម្រិតទំនាក់ទំនង ឬប្រៀបធៀប

កម្រិតទំនាក់ទំនង ឬប្រៀបធៀបមាននៃគុណនាម គឺជាការសម្តែងគុណភាពអាចកើតឡើង ដោយដាក់ឱ្យទាក់ទងគ្នារវាងមនុស្សម្នាក់ (សត្វ ឬវត្ថុមួយ) និងម្នាក់ទៀត(មួយនាក់ទៀត)លើចំណុច កម្រិតប្រពលភាពនៃគុណភាព គឺកម្រិតទាក់ទង(នៃការសម្តែងគុណភាព)ឬទំហៀប៖

ឧទាហរណ៍៖

- សុខជាសិស្ស**<u>សុភាពរាបសារជាង</u>**សំ ។(ទំហៀបផ្ទឹម)
- សៅជាកម្មករ**<u>ស្លូតត្រង់ដូច</u>**ឪពុក។(ទំហៀបផ្ទឹម)
- សានជាកម្មករ**<u>ជំនាញជាងគេ</u>**។(ទំហៀបផ្តាច់)

ពាក្យថា សុភាពរាបសារជាង ស្លូតត្រង់ដូច ជំនាញជាងគេ ជាគុណនាមកម្រិតទាក់ទង ឬគុណនាមទំហៀប។

#### ៣.៣.៣- កម្រិតដាច់ខាត(គ្មានទំហៀប)

កម្រិតដាច់ខាត ឬគ្មានទំហៀប សំដៅដល់គេប្រើប្រាស់គុណកិរិយា «ណាស់» សម្រាប់សម្តែង កម្រិតខ្ពស់ណាស់នៃគុណភាព។ កម្រិតបែបនេះគេហៅថា «កម្រិតបណ្តាច់» ឬ «បណ្តាច់»៖

ឧទាហរណ៍៖

- សុខជាសិស្ស**<u>ពូកែណាស់</u>**។
- សៅជាកីឡាករ**<u>ស្ទិតស្ទាញណាស់</u>**។

កម្រិតជាច់ខាតផ្សេងទៀតមាន៖

- កម្រិតជាច់ខាតមធ្យម៖ សានជាកសិករ**<u>ជាត់ល្មម</u>**។
- កម្រិតជាច់ខាតលើសលែង៖ គាត់ជាកម្មករ**<u>ជំនាញក្រៃលែង</u>**។

## ៤- សព្វនាម

សព្វនាមជាពាក្យសម្រាប់ជំនួសឱ្យនាម កន្សោមនាម ឬប្រធាន។ ឧ. ខ្ញុំ គេ គាត់ នាង យើង ...។

### ៤.១- នាទីរបស់សព្វនាម

នៅក្នុងល្បះ សព្វនាមដើរតួជាកន្សោមនាម។ សព្វនាមមានមុខងារ ដដូចកន្សោមនាមដែលវាជំនួស ប្រធាន កម្មបទ កម្មទេសកាល។ល។ សព្វនាមមាននាទី៤យ៉ាងគឺ៖

#### ៤.១.១- សព្វនាមអាចជំនួសកន្សោម ដែលគេបានសម្តែងរួចហើយ

ឧទាហរណ៍៖

ពូខ្ញុំកាប់ឧសក្នុងព្រៃ។ ពូខ្ញុំជួបនឹងខ្លាត្រីមួយ។

ពូខ្ញុំកាប់ឧសក្នុងព្រៃ **<u>គាត់</u>**ជួបនឹងខ្លាត្រីមួយ។

ពូខ្ញុំ**<u>ដែល</u>**កាប់ឧសក្នុងព្រៃ ជួបខ្លាត្រីមួយ។

ពាក្យថា **គាត់ ដែល** ជាពាក្យជំនួសឱ្យកន្សោមនាមប្រធាន**ពូខ្ញុំ**ដែលបាននិយាយរួចមកហើយ។

#### ៤.១.២- សព្វនាមពុំអាចជំនួសកន្សោមណាមួយ ដែលគេបានសម្តែងរួចហើយ

ឧទាហរណ៍៖

ខ្ញុំសួរខ្លួនខ្ញុំថា **<u>អ្នកណា</u>**មកដល់ព្រឹកមិញ(បុគ្គលណាមួយ)?

គ្មាន**<u>នរណា</u>**ខ្ជិលធ្វើការទេ (គ្មានបុគ្គលណាម្នាក់)។

ពាក្យថា **អ្នកណា នរណា** មិនបានជំនួសឱ្យកន្សោមណាមួយដែលគេបានសម្តែងរួចហើយទេ ប៉ុន្តែវាជាសព្វនាមដែល។

#### ៤.១.៣- សព្វនាមអាចមាននាទីជាអ្នកនាំមុខឃ្លា

មនុស្ស**<u>ដែល</u>**(វា គេ គាត់...)ខំរៀន តែងទទួលបាននូវចំណេះដឹងពិតប្រាកដ។

សុខ**<u>ដែល</u>**((វា គេ គាត់...)ទើបតែនឹងប្រលងជាប់នោះឥឡូវបានជាមន្ត្រីរាជការហើយ។

ពាក្យថា **ដែល** ជាសព្វនាមជំនួសឱ្យបុគ្គលណាម្នាក់ខិតខំរៀន និងជាអ្នកប្រលងជាប់នៅខាងមុខឃ្លា។

**៤.១.៤- សព្វនាមអាចបង្ហាញ(មនុស្សវត្តមាន)វត្តមានមនុស្ស ក្នុងស្ថានភាពប្រាស្រ័យទាក់ទងគ្នា**

ឧទាហរណ៍៖

នៅទីនេះ ខ្ញុំសប្បាយចិត្តណាស់។ ឯគេក៏សប្បាយចិត្តដូចខ្ញុំដែរ។

ពាក្យថា **ខ្ញុំ** ជាប្រធាននៃ **សប្បាយចិត្ត**។ វាពុំប្រើជំនួសពាក្យខាងដើម ឬខាងចុងណាទេ។

ពាក្យថា **គេ** ជាប្រធាននៃ **សប្បាយចិត្ត**ដែរ។ វាពុំប្រើជំនួសពាក្យខាងដើម ឬខាងចុងណាដែរ។ តែគេយើងអាចស្ដាប់យល់ន័យបាន។ ដែលបានសេចក្ដីថា **ខ្ញុំ** និង**គេ** បង្ហាញពីការចូលរួមប្រាស្រ័យទាក់ទងគ្នា(**សប្បាយចិត្ត**)ទាំងអស់គ្នា។

**៤.២- សម្ព័ន្ធសាស្ត្រ និងរូបសាស្ត្រនៃសព្វនាម**

**៤.២.១- សព្វនាមមានសម្ព័ន្ធសាស្ត្រដូចនឹងគុណនាម**

**៤.២.១.១- សព្វនាមប្រធាន**

នៅខាងឆ្វេងកិរិយា៖

- **<u>ចិត្តតាវា</u>**មានអំណាត់ណាស់។
- **<u>គាត់</u>**អាចតស៊ូធ្វើការបានរាល់ថ្ងៃ។
- **<u>វា</u>**ជាចៅរបស់គាត់។
- **<u>នេះ</u>**ជាស្រែរបស់គេ។
- **<u>នរណា</u>**ដើរលើភ្លឺស្រែគាត់នោះ ?

ពាក្យថា **ចិត្តតាវា គាត់ វា នេះ នរណា** ជាសព្វនាមប្រធាន។

**៤.២.១.២- សព្វនាមកម្ម**

នៅខាងស្ដាំកិរិយា៖

- គាត់ឃើញ**<u>គោគាត់</u>**រត់កាត់វាលស្រែ។
- គាត់ឃើញ**<u>វា</u>**រត់កាត់វាលស្រែ។
- ឯងឃើញ**<u>នរណា</u>**រត់កាត់វាលស្រែទេ ?
- ឯងឃើញ**<u>គេ</u>**មកទីនេះទេ ?
- ខ្ញុំឮ**គាត់**និយាយពីឯង។
- គេជិះ**<u>ម៉ូតូនាង</u>**ចេញទៅមុននេះ
- ពាក្យថា **គោគាត់ វា នរណា គេ គាត់ ម៉ូតូនាង** ជាសព្វនាមកម្ម។

##### ៤.២.១.២- សព្វនាមកម្មខ្លះ នៅខាងឆ្វេងកិរិយាមាននាទីជាកម្មដែរ

ឧទាហរណ៍៖

ពូសំចាប់ផ្ដើមធ្វើស្រែ <u>**ដែល**</u>គេបោះបង់ចោលយូរហើយ។

<u>**ដែល**</u> ជាកម្មបទផ្ទាល់របស់កិរិយា <u>**បោះបង់**</u>។ វានៅខាងឆ្វេងកិរិយាសព្ទ។

### ៤.២.២- សព្វនាមអាចមានរូបរាងប្លែកគ្នាតាមសមគួរ មិនសមគួរ ឋានៈ វណ្ណៈ ប្រភេទមនុស្ស វចនៈ ភេទ គ្រួសារ ក្រៅគ្រួសារជាដើម

ឧទាហរណ៍៖

- <u>**ខ្ញុំ**</u>ទៅរៀន។ (មនុស្សក្មេង)
- <u>**អញ**</u>មិនទៅទេ។ (មនុស្សវ័យស្មើ)
- <u>**វា**</u>ទៅស្រែហើយ។ (វ័យក្មេងជាង)
- <u>**គាត់**</u>ទៅស្រែដែរ។ (វ័យចាស់)
- <u>**វា**</u>បោលចោលគាត់។ (សត្វ)
- <u>**នាង**</u>និយាយប្រាប់ខ្ញុំ។ (ភេទស្រី)
- **អាត្មា**បួសយូរឆ្នាំហើយ។ (សង្ឃ)

ពាក្យថា **ខ្ញុំ អញ វា គាត់ អាត្មា** ជាសព្វនាមសព្វនាមអាចមានរូបរាងប្លែកគ្នាតាមសមគួរ ពុំសមគួរ ឋានៈស្រទាប់វណ្ណៈ ប្រភេទមនុស្ស អមនុស្ស វចនៈ ភេទ ក្នុងគ្រួសារ ក្រៅគ្រួសារ។

### ៤.៣- ថ្នាក់រងនៃសព្វនាម

ថ្នាក់រងនៃសព្វនាមអាចចែកជា៥គឺ៖ **សព្វនាមបុរិសៈ សព្វនាមចង្អុល សព្វនាមសំណួរ សព្វនាមឈ្នាប់ និងសព្វនាមមិនច្បាស់។**

#### ៤.៣.១- សព្វនាមកម្មសិទ្ធិ ឬសព្វនាមបុរិសៈ

##### ៤.៣.១.១- នាទីសព្វនាមកម្មសិទ្ធិ

សព្វនាមបុរិសៈចែកជាពីរគឺ ក្រុមបុរសទី១ ទី២ និងក្រុមបុរសទី៣

**ក. ក្រុមទី១៖** បុរសទី១ បុរសទី២ បង្ហាញនិយាយ និងអ្នករួមនិយាយ ក្នុងការសន្ទនាទៅវិញទៅមក។ គេអាចហៅថា «នាមបុរិសៈ» ព្រោះវាពុំប្រើជំនួសនាមណាមួយ ដែលគេនិយាយហើយ ឬមិនទាន់និយាយ។

ឧទាហរណ៍៖ ខ្ញុំ ឯង យើង អ្នក...។

**ខ. ក្រុមទី២៖** បុរសទី២ បង្ហាញមនុស្ស ឬអមនុស្សដែលគេសម្តែងរួចដោយដោយកន្សោមនាម ឬបង្ហាញអ្នកវត្តមាននៅពេលដែលគេកំពុងប្រាស្រ័យទាក់ទងគ្នា។

ឧទាហរណ៍៖ វា គាត់ គេ ពួកគាត់...។

**ទីតាំង៖** បើជាប្រធាន នៅខាងឆ្វេងកិរិយា បើជាកម្មបទនៅខាងស្តាំកិរិយា។

| សព្វនាម | គួរសមគោរព | គ្រួសារស្និទ្ធស្នាល | អ្នកធំ | អ្នកតូច | ស្មើគ្នា |
|---|---|---|---|---|---|
| ខ្ញុំ | + | + | + | + | |
| អញ | | + | | | + |
| គ្នា | | + | | | + |
| យើង | | | | | + |
| លោក | + | | + | + | |
| អ្នក | + | | + | | |
| ឯង | | + | | | + |
| គាត់ | + | | | + | |
| វា | | | | | |

## ៤.៣.២- សព្វនាមចង្អុល

### ៤.៣.១.១- នាទីសព្វនាមកម្មសិទ្ធិ

សព្វនាមសម្រាប់ចង្អុលឱ្យច្បាស់លាស់ឡើង ដោយបញ្ជាក់ស្ថានភាព (ជិត ឆ្ងាយ) ពេលវេលា ឬទីកន្លែង។

**ក. សព្វនាម នេះ នោះ( សព្. + នេះ , សព្.+នោះ )សម្រាប់តាងកន្សោមនាមដែលនិយាយរួចហើយ**

នៅជាប់ខាងស្តាំសព្វនាមបុរិសៈ ឬសព្វនាមកម្មសិទ្ធិ បុរសទី១ ទី២ និងទី៣

**ឧ.** តាសំមានគោច្រើន គាត់<u>**នេះ**</u>ចិត្តល្អណាស់។ វា<u>**នោះ**</u>ហើយកំពុងដើរស៊ីស្មៅ។

ពាក្យថា **នេះ នោះ**ជាសព្វនាមចង្អុល។

**ខ. សព្វនាមចង្អុលអាចពុំមានតាងកន្សោមនាមណាមួយទេ (អាស្រ័យឥរិយាបថប្រចាំថ្ងៃ)**

**ឧ.** (សុខចង្អុលនង្គ័ល និងរនាស់) អា<u>**នេះ**</u>ជានង្គ័ល ឯអា<u>**នោះ**</u>គឺរនាស់។

ពាក្យថា **នេះ នោះ**ជាសព្វនាមចង្អុល។

**គ. សព្វនាមចង្អុល(នេះ នោះ) រួមជាមួយ (គឺជា)**

- បង្កើតបានជាការណែនាំបង្ហាញ

ឧ. **នេះ**គឺជារបៀបធ្វើស្រែ។ **នោះ**ជារបៀបសាបព្រោះ ដកស្ទូង។

- បង្កើតបានជាការបង្ហាញព័ត៌មានអ្វីមួយ

ឧ. **នេះ**គឺជាឪពុករបស់សុខ។ **នោះ**ជាថ្នាក់រៀនរបស់គេ។

**៤.៣.៣- សព្វនាមសំណួរ**

**៤.៣.១.១- នាទីសព្វនាមសំណួរ** សព្វនាមសំណួរប្រើសម្រាប់៖

- ជំនួសកន្សោមនាមដែលជាចម្លើយនៃសំណួរ។
- បង្កើតល្បះសំណួរ។

សព្វមានសំណួរមានដូចជា៖ (សព្វ+សំនួនសួរ ឬសំនួនសួរ+សព្វនាម)

ក. សម្រាប់មនុស្ស៖ អ្នកណា? នរណា? រូបណា? ម្នាក់ណា? អង្គណា?...

ខ. សម្រាប់សត្វ៖ ស្អី? ស្អីខ្លះ? មួយក្បាលណា?...

គ. សម្រាប់វត្ថុ៖ អី? អ្វី? អ្វីមួយ? អ្វីខ្លះ?...

សព្វនាមសំណួរអាចជា៖

- **ជាប្រធាន៖** នៅខាងឆ្វេងកិរិយាបង្គោល

ឧ. **នរណាខ្លះ**ទៅស្រែ? **អ្នកណា**ស្គាល់ស្រែហ្នឹង?

- **ជាកម្មបទ៖** នៅខាងស្តាំកិរិយាបង្គោល

ឧ. យើងទៅរក**អ្នកណា**? នោះខ្ញុំឃើញ**ស្អី**អ៊ីចេះបោលលឿនដូចខ្យល់?

បញ្ជាក់លទ្ធភាពទីតាំងសព្វនាមសំណួរ

- មានសៀវភៅ១០ក្បាលនៅទីនេះ។
  - តើលោកត្រូវការសៀវភៅ<sup>ន.</sup> **មួយណា**?
  - តើលោកត្រូវការ<sup>កិ.</sup> **មួយណា**?
- មានសៀវភៅ៣នៅលើតុ។
  - តើលោកត្រូវការសៀវភៅ<sup>ន.</sup> **ប៉ុន្មាន**?
  - តើលោកត្រូវការ<sup>កិ.</sup> **ប៉ុន្មាន**?

### ៤.៣.៤- សព្វនាមឈ្នាប់

**៤.៣.១.១- នាទីសព្វនាមសំណួរ** ប្រើសម្រាប់ផ្លាស់កន្សោមនាម និងបង្កើតឈ្នោះរណប។ សព្វនាមឈ្នាប់មានតែមួយគត់ គឺ «**ដែល**»។

សំដឹកគោមួយនឹមទៅស្រែ។ គោមួយនឹមនេះធាត់ៗល្អណាស់។

មកជា  សំដឹកគោ<u>ដែល</u>ធាត់ៗល្អណាស់នេះទៅស្រែ។

ពាក្យថា **ដែល** ជាសព្វនាមឈ្នាប់។

សព្វនាមឈ្នាប់អាចប្រើជា៖

**ក. ប្រធាន**

**ឧ.** នេះជាកុមារ <u>**ដែល**</u>រៀនពូកែជាងគេ។ **ដែល** ជាប្រធានរបស់កិរិយា **រៀន**។

**ខ. កម្មបទ**

- **កម្មបទផ្ទាល់**

**ឧ.** សៀវភៅទាំងអស់ <u>**ដែល**</u>បងខ្ញុំទើបនឹងផ្ញើមកឱ្យខ្ញុំសុទ្ធតែល្អៗ។ **ដែល** ជាកម្មបទផ្ទាល់ជំនួសឱ្យសៀវភៅ រងអំពើកិរិយា**ផ្ញើ**។

- **កម្មបទមិនផ្ទាល់**

**ឧ.** បុរសម្នាក់<u>**ដែល**</u>បងកំពុងនិយាយជាមួយនោះជាកសិករ។ **ដែល** ជាកម្មបទមិនផ្ទាល់ជំនួស**បុរស** រងអំពើកិរិយា**និយាយ(ជាមួយ)**។

**គ. កម្មទេសកាល**

- **កម្មប្រាប់ទេស(កន្លែង)**

**ឧ.** កន្លែង<u>**ដែល**</u>មានផាសុកភាព ជាកន្លែង<u>**ដែល**</u>មានបរិស្ថានជុំវិញល្អ។

- **កម្មប្រាប់កាល(ពេល)**

**ឧ.** នៅពេលព្រឹក <u>**ដែល**</u>យើងអាចដើរបាន គឺព្រឹក<u>**ដែល**</u>ស្រទ្បះល្អ។

### ៤.៣.៥- សព្វនាមមិនច្បាស់

**៤.៣.១.១- នាទីសព្វនាមមិនច្បាស់**

សព្វនាមមិនច្បាស់ លាក់ទុកព័ត៌មានមួយផ្នែកដែលពុំចង់ ឬពុំអាចប្រាប់បាន។ ជាតុនៃព័ត៌មានដែលលាក់ទុកដោយសព្វនាមមិនច្បាស់សម្តែងឯកលក្ខណៈ ពហុភាព ឬបរិមាណ។

សព្វនាមមិនច្បាស់មានៈ

– **ទោលៈ** ម្នាក់ នរណាមួយ អ្នកណាម្នាក់ អ្នកណាមួយ...

ឧ. ពូសុខមានកូន៣នាក់ ដែល**<u>ម្នាក់</u>**បានក្លាយជាគ្រូបង្រៀន។

– **លើសពីមួយៈ** ច្រើនគ្នា ច្រើននាក់ ពីរបីនាក់ ខ្លះ អ្វីខ្លះ ស្អីខ្លះ...

ឧ. មាន**<u>ច្រើនគ្នាណាស់</u>** ដែលមកសិក្សានៅភ្នំពេញ។

– **សូន្យៈ** គ្មានម្នាក់ គ្មាននរណាសោះ គ្មានអ្វីមួយ ពុំមានដទៃទៀតឡើយ...

ឧ. គ្មាន**<u>នរណាម្នាក់</u>**អាចធ្វើកិច្ចការនេះបានទេ។

– **សណ្ឋៈ** ម្នាក់ៗ នីមួយៗ ទាំងអស់ ទាំងមូល ទាំងស្រុង ទាំងព្រម...

ឧ. សិស្សប្រឹងប្រែងរៀនសូត្រត្រៀមប្រលង **<u>ម្នាក់ៗ</u>**សុទ្ធតែជាសិស្សពូកែ។

– **ឯកលក្ខណភាពៈ** អាដូចគ្នា(នោះ) អ្នកកន្លៀត(ឯទៀត) ខ្លះទៀត ម្នាក់ទៀត.គ្នា

ឧ. ខ្ញុំយកសៀវភៅវេយ្យាករណ៍ និងអក្សរសិល្ប៍ ឯគាត់យក**<u>អាដូចគ្នា</u>**ហ្នឹងដែរ។

## ៥- កិរិយាសព្ទ

កិរិយាសព្ទជាសម្ដីសម្ដែងអំពើ។

## ៥.១- សញ្ញាណកិរិយា

ក្នុងល្បះនីមួយៗកិរិយាជាបង្គោលនៃធាតុដទៃទៀត វាជាធាត់ស្នូលនៃល្បះ។

### ៥.១.១- កិរិយាសញ្ញាណ

កិរិយាសព្ទខ្លះប្រាប់យើងអំពីអ្វីមួយ។ វារំឭកយើងឱ្យឃើញសញ្ញាណផ្សេងៗៈ

– **សកម្មភាពខាងផ្លូវកាយប្រកបដោយចលនា**

ឧទាហរណ៍ៈ

– កសិករ<u>កាប់គាស់</u>ដី។
– សំ<u>ជញ្ជូន</u>ឈើដាក់ក្រោមដើមឈើ។
– យាយសុំ<u>ត្បាញ</u>ហូលផាមួង។

ពាក្យថា **កាប់គាស់ ជញ្ជូន ត្បាញ** ជាកិរិយាសព្ទបង្ហាញសកម្មភាពខាងផ្លូវកាយប្រកបដោយចលនា។

– **សកម្មភាពខាងផ្លូវកាយគ្មានចលនា**

ឧទាហរណ៍ៈ

- គោ**ដេក**លើភ្លឺស្រែ។
- សំ**អង្គុយ**ក្រោមដើមកកោះ។
- ធីតា**មើល**កោះត្រល់ពីលើភ្នំបូកគោ។

ពាក្យថា **ដេក អង្គុយ មើល** ជាកិរិយាសព្ទបង្ហាញសកម្មភាពខាងផ្លូវកាយប៉ុន្តែគ្មានចលនា។

- **សកម្មភាពខាងប្រាជ្ញា បេះដូង ចន្ទះ**

ឧទាហរណ៍៖

- សិស្សសាលា**ខំ**សិក្សារៀនសូត្រ។
- គ្រូ**ព្យាយាម**មេរៀនដល់សិស្ស។
- យើង**រិះរក**មធ្យោបាយសិក្សាថ្មីៗ។

ពាក្យថា **ខំ ព្យាយាម រិះរក** ជាកិរិយាសព្ទបង្ហាញសកម្មភាពខាងប្រាជ្ញា បេះដូងឬចន្ទះ។

- **អ្វីៗទាំងអស់ដែលមនុស្ស សត្វ វត្ថុ បង្កើតឡើង ឬទទួលរង**
  - ខ្យល់**បក់**ស្លឹកឈើលាន់ប្រាវៗ។
  - ទូរសព្ទ**រោទិ៍**ក្រឹងៗពេញបន្ទប់។
  - គាត់ឮ**សំឡេង**ទូរសព្ទរោទិ៍។

ពាក្យថា **បក់ រោទិ៍ សំឡេង** ជាកិរិយាសព្ទបង្ហាញអ្វីៗទាំងអស់ដែលមនុស្ស សត្វ វត្ថុ បង្កើតឡើង ឬទទួលរង។

### ៥.១.២- កិរិយាចំណាង

កិរិយាចំណាង ជាកិរិយាដែលចងល្បះមួយ និងល្បះមួយទៀតដែលមានកិរិយាចំណាង«**ជា ហាក់ដូចជា ដូចជា ...** »។

ស្ថិតក្នុងកន្សោមកិរិយា៖ កកិ→កិ(ជា)+កន

ឧទាហរណ៍៖

សំ**ជា**សិស្ស គេ**ហាក់ជា**សិស្សពូកែ ដែលមានលោកសុខ**ជា**គ្រូបង្រៀន។

### ៥.១.៣- កិរិយាជំនួយ ឬជំនួយ

ជំនួយកិរិយាប្រើសម្រាប់បង្គ្រប់ន័យសេចក្ដីរបស់កិរិយាសព្ទបង្គោលណាមួយក្នុងល្បះ។ កិរិយាជំនួយមាន៖

### ៥.១.៣.១- កិរិយាជំនួយបំពេញ

កិរិយាជំនួយបំពេញជាកិរិយាបង្គ្រាប់ន័យឱ្យកិរិយាបង្គោលលើចំណុចពីរគឺ៖ **លទ្ធផលនៃអំពើ** និង**លទ្ធភាពសម្រេចអំពើ**។

**ឧទាហរណ៍លទ្ធផលនៃអំពើ៖**

- សុខ**មើលឃើញ**ភ្នំខ្ពស់ពីចម្ងាយ។

ពាក្យថា **មើល** ជាកិរិយាបង្គោល **ឃើញ**ជាលទ្ធផលនៃការមើល។

**ឧទាហរណ៍លទ្ធភាពសម្រេចអំពើ៖**

- ស្រូវមួយបាវនោះសុខអាច**លើករួច**។

ពាក្យថា **លើក** ជាកិរិយាបង្គោល **រួច** ជាលទ្ធភាពនៃការសម្រេចអំពើ។

### ៥.១.៣.២- កិរិយាជំនួយទិសដៅ

កិរិយាជំនួយទិសដៅប្រើប្រាស់ជាមួយកិរិយាបង្គោល សម្រាប់ប្រាប់ទិសដៅ ឬទិស នៃអំពើរបស់កិរិយាបង្គោល ។ ឧ. ទៅ មក ចុះ ឡើង ឱ្យ យក ...។

ឧទាហរណ៍៖

- ឱ្យខ្ញុំសុំសៀវភៅមួយក្បាល**មក**។
- គាត់ដើរ**មក**ហើយទេតើ។

ពាក្យថា **មក** ជាកិរិយាបង្គោល **សុំ** និង**ដើរ**ជាកិរិយាជំនួយទិសដៅ។

### ៥.១.៣.៤- កិរិយាសព្ទខាងដើម

កិរិយាសព្ទខាងដើម នៅខាងឆ្វេងកិរិយាសព្ទបង្គោល( កិរិយា ឬគុណនាមកិរិយា )សម្រាប់ប្រាប់តម្លៃអាការភាព( ម៉ូត) តម្លៃទិដ្ឋភាព ឬកាល ឬក៏លក្ខណៈនៃអំពើ។ ឧ. ចង់ ចូលចិត្ត ប៉ង ប្រាថ្នា អាច បាន មាន ធ្លាប់ ប្រញាប់...។

ឧទាហរណ៍៖ គាត់**ចង់**ធ្វើស្រែ និងធ្វើចម្ការផង ដើម្បីជីវភាពផង គាត់**ចូលចិត្ត**ធ្វើផង។

ខ្ញុំមិន**ចូលចិត្ត**ដើរលេងទេ តែ**អាច**ដើរលេងជាមួយបាន។

### ៥.១.៣.៤- ពាក្យដើមកិរិយា

ពាក្យដើមកិរិយា( កិរិយាខាងដើមមានកិរិយានុគ្រោះ និងពាក្យពុំមែនកិរិយាមានកិរិយានុគ្រោះ )ប្រើជាកិរិយាបង្គោលសម្រាប់សម្តែងគុណលក្ខណៈរបស់កិរិយានោះ។

ឧទាហរណ៍៖

- ជិត៖ មេឃ**ជិត**ភ្លៀងហើយ។ ខ្ញុំក៏**ជិត**ទៅផ្ទះហើយដែរ

  ស្រូវ**ជិត**ទុំហើយ។ កសិករ**ជិត**រវល់នឹងការច្រូតកាត់ម្តងដើមឆ្នាំនេះ។
- ក៏៖ ឯងទៅ ខ្ញុំ__ក៏__ទៅ ប្រសិនបើឯងមិនទៅ ខ្ញុំ__ក៏__នៅតែទៅដដែល។

  ឪពុកខ្ញុំគាត់ចូលចិត្តសម្លកកូរណាស់ ឯម្តាយ__ក៏__ចូលចិត្តណាស់ដែរ។
- កាន់តែ ពុំ មិន ទេ ...៖

  ការសិក្សា__**កាន់តែ**__ចម្រើន មនុស្ស__**មានតែ**__មានការអភិវឌ្ឍ។

  ការសិក្សាគ្រាន់តែចម្រើន ឯមនុស្ស__**សុទ្ធតែ**__អភិវឌ្ឍ ភាពស្ថិតស្ថេរ__**ពុំ**__ស្ថិតស្ថេរឡើយ។
- នឹង៖ គាត់__**នឹង**__ទៅ ឯខ្ញុំ__**នឹង**__មក ដូចនេះយើង__**នឹង**__ជួបគ្នា។
- ជួយ៖ (ជួយ+ឈ្មោះបញ្ញា) __**ជួយ**__ភ្ជួរដីឱ្យខ្ញុំផងថ្ងៃនេះ ចាំខ្ញុំ__**ជួយ**__ទៅសងដៃវិញថ្ងៃស្អែក។
- សូម សុំ៖ (សូម សុំ+ឈ្មោះបញ្ញា) __**សូម**__និយាយម្តងទៀត។ __**សូម**__ស្តាប់គាត់និយាយ។ __**សុំ**__កុំរំខានគាត់។
- គួរ៖ (គួរ+ឈ្មោះបញ្ញា) __**គួរ**__សិក្សារៀនសូត្រ __**ពុំគួរ**__ខ្ជិលច្រអូសឡើយ។
- ចូរ៖ (ចូរ+ឈ្មោះបញ្ញា) __**ចូរ**__ស្តាប់បណ្តាំចាស់ទុំ __**ចូរ**__កុំប្រហែសឡើយ។

#### ៥.១.៥- គុណនាមកិរិយា

គុណនាមមួយចំនួន អាចប្រើជាស្នូល(កិរិយា)នៃឈ្មោះដូចជា៖ ល្អ ធំ តូច ខ្ចី ថ្លៃ ថោក ទុំ ក្រ ខ្សត់ អាក្រក់ ល្អ ពីរោះ...។

ឧទាហរណ៍៖

- កុមារនេះ__**ល្អ**__ មានភាព**ធំ**ជាត់លូតលាស់លឿន ហើយច្រៀង__**ពីរោះស្តាប់**__ទៀត។
- ស្រូវនេះកំពុងតែ**ខ្ចី** ស្រូវមួយថ្នាលនោះពុំ**ទុំ**សោះ បើយ៉ាងនេះ__**ខ្សត់**__អង្ករ កសិករកំពុងតែ__**ក្រ**__ផង។
- ក្របីនេះមានស្នែង__**តូច**__ស្អាត អានោះវិញស្នែង__**អាក្រក់មើល**__ណាស់ តែដំណើរវា__**ល្អមើល**__ទៅវិញ។

### ៥.២- ថ្នាក់សម្ព័ន្ធ

កិរិយាសព្ទអាចបែងចែកជាថ្នាក់សម្ព័ន្ធ៦យ៉ាងគឺ៖

#### ៥.២.១- កិរិយាសុទ្ធ

កិរិយាសុទ្ធជាកិរិយាសម្តែងនូវអំពើរបស់ប្រធានដែលធ្វើដោយខ្លួនឯងផ្ទាល់។ ឧ. ដេក ដើរ ខាំ ស៊ី លើក សែង ហុត ចាក់ ចាប់...។

ឧទារហរណ៍៖ គោ__**ស៊ី**__ស្មៅក្នុងស្រែ ឯសត្វក្របី__**ដេក**__ក្នុងទឹកត្រពាំង។

ពាក្យថា **ស៊ី** និង**ដេក** សម្តែងអំពើរបស់ប្រធាន **គោ** និង**ក្របី** ដែល**ស៊ី** និង**ដេក**ដោយខ្លួនឯង។

### ៥.២.២- កិរិយាហេតុ

កិរិយាហេតុជាកិរិយាសម្តែងនូវអំពើរបស់ប្រធានដែលធ្វើឡើងគ្រាន់តែជាដើមចមប៉ុណ្ណោះ។ ឧ. ផ្តេក ផ្តួល រំលំ បង្រៀន បន្ស៊ី បញ្ច្រាប បង្គាប់ ...។

ឧទាហរណ៍៖ មីងសំ**ផ្តេក**កូនលើអង្រឹង មុននឹងទៅ**បង្រៀន**សិស្សនៅសាលា។

ពាក្យថា **ផ្តេក** និង**បង្រៀន** សម្តែងអំពើរបស់ប្រធាន**មីងសំ** ដែល**ផ្តេក**ឱ្យកូនគាត់ដេក និងបង្រៀនឱ្យកូនសិស្សរៀន។

#### ៥.២.២.១- កំណើតរបស់កិរិយាហេតុ

**ក- កើតពីកិរិយាសុទ្ធ៖ ធ្វើឱ្យ ញ៉ាំងឱ្យ នាំឱ្យ នាំមកនូវ + កិរិយាសុទ្ធ**

ឧ. ចំណេះវិជ្ជា**ធ្វើឱ្យ**យុវជនមានភាពក្លាហាន និង**ញ៉ាំងឱ្យ**គេមានសេចក្តីថ្លៃថ្នូរ។

**ខ- កម្លាយកិរិយាសុទ្ធ+ផ្នត់កម្លាយ**

| **កិរិយាសុទ្ធ** | **កិរិយាហេតុ** |
| --- | --- |
| សាយ | បន្សាយ |
| សុទ្ធ | បន្សុត |
| លាយ | រំលាយ |
| ដោះ | រំដោះ |
| សឹក | ផ្សឹក |

**គ- កើតពីគុណនាម**

| **គុណនាម** | **កិរិយាហេតុ** |
| --- | --- |
| អាប់ | ផ្អាប់ |
| ទុំ | បន្ទុំ |
| ឱប | ផ្អោប |
| ក្តៅ | កម្តៅ |
| រាប | ពង្រាប |

### ៥.២.៣- កិរិយាសកម្ម

កិរិយាសកម្មជាកិរិយាដែលត្រូវការកម្មបទ។

ឧទាហរណ៍៖ គោ**ស៊ី**ស្មៅជាចំណី ឯមាន់**សសិត**លើបង្កងយ៉ាងរំភើយ។

ពាក្យថា **ស៊ី** ជាកិរិយាសុទ្ធសកម្ម ដែលមានកម្មបទផ្ទាល់គឺ **ស្មៅ**។ ឯ កិរិយា **សសិត** ជាកិរិយាហេតុអកម្ម ព្រោះគ្មានកម្មបទ។

**៥.២.២.១- កំណើតរបស់កិរិយាសកម្ម**

**ក- កើតពីកិរិយាសកម្ម**

| **កិរិយាសកម្ម** | **កិរិយាសកម្ម** |
|---|---|
| ជូន | បញ្ជូន |
| ដឹង | ប្ដឹង |
| យល់ | ពន្យល់ |
| ថែម | បន្ថែម |

**ខ- កើតពីកិរិយាសកម្ម**

| **កិរិយាអកម្ម** | **កិរិយាសកម្ម** |
|---|---|
| ហើរ | បង្ហើរ |
| ហោះ | បង្ហោះ |
| ស្លាប់ | សម្លាប់ |
| រីក | ពង្រីក |

**៥.២.៤- កិរិយាអកម្ម**

កិរិយាអកម្មជាកិរិយាដែលមិនត្រូវការកម្មបទ។

ឧទាហរណ៍៖

បក្សីមួយក្បាល**ហើរ**លើមេឃ ឯសត្វសេក**ទុំ**លើបង្គង។

ពាក្យថា **ហើរ** និងទុំ ជាកិរិយាអកម្ម ព្រោះគ្មានកម្មបទ។

**កំណត់សម្គាល់ កិរិយាតែមួយអាចជាកិរិយាសកម្មផង និងជាកិរិយាសកម្មផង**

មានដូចជាពាក្យ លូត លាស់ ឆេះ រោល ដុត ...។

**១**. លាស់៖ ឈើ**លាស់**ស្លឹក។ **លាស់** ជាកិរិយាសកម្ម មាន**ស្លឹក**ជាកម្មបទ។

ស្លឹកឈើ**លាស់**ខ្ចី។ **លាស់** ជាកិរិយាអកម្ម ព្រោះគ្មានកម្មបទ។

## ៦- គុណកិរិយា ឬកិរិយាវិសេសន៍

គុណកិរិយាគឺជាពាក្យសម្រាប់សម្ដែងលក្ខណៈរបស់កិរិយាសព្ទ គុណនាម ឬគុណកិរិយា។

ឧ. ដើរលឿន ដេកយឺត(យូរ) ជំខ្លាំង ក្រហមទុំ លឿនណាស់ យឺតក្រៃ...។

### ៦.១- ថ្នាក់របស់គុណកិរិយា

គុណកិរិយាមាន៥ថ្នាក់គឺ

#### ៦.១.១- គុណកិរិយាយបំណែប

គុណកិរិយាបំណែប ជាពាក្យប្រាប់បំណែប(បែប)របស់កិរិយាសព្ទ។ ឧ. លឿន យឺត ឆាប់ រហ័ស សន្សឹមៗ តិចៗ...។

**នៅជាប់ខាងស្ដាំកិរិយាសព្ទ ឬគុណនាម ឬគុណកិរិយា**

ឧទាហរណ៍៖ គោមាឧធំណាស់ដែរ តែដើរយឺតៗ អ្នកបរទេះស្រែកជេញឮៗ។

ពាក្យថា **ណាស់ យឺតៗ ឮៗ** ជាគុណកិរិយាបំណែបនៃពាក្យ **ធំ ដើរ ស្រែកជេញ**។

#### ៦.១.២- គុណកិរិយាយកន្លែង

គុណកិរិយាកន្លែង ជាពាក្យប្រាប់កន្លែងរបស់កិរិយាសព្ទ។ ឧ. ខាងលើ ខាងក្រោម ខាងក្រោយ ខាងឆ្វេង ខាងស្ដាំ ខាងនេះ ខាងនោះ...។

**នៅជាប់ខាងស្ដាំកិរិយាសព្ទ**

ឧទាហរណ៍៖ សុខទៅឆ្វេង សៅទៅស្ដាំ ឯឯងទៅនេះ ហើយឯងនោះទៅខាងនោះ។

ពាក្យថា **ឆ្វេង ស្ដាំ នេះ ខាងនោះ** ជាគុណកិរិយាកន្លែងនៃកិរិយា**ទៅ**។

#### ៦.១.៣- គុណកិរិយាយកាល

គុណកិរិយាកាល ជាពាក្យប្រាប់កាលរបស់កិរិយាសព្ទ។ ឧ. ឆ្នាំមុន ម្សិលមិញ ថ្ងៃមុន ថ្ងៃនេះ ថ្ងៃមិញ ឥឡូវនេះ ពេលក្រោយ ឆ្នាំក្រោយ ...។

ឧទាហរណ៍៖ ស្អែកសុភាពនឹងទៅស្រុកកំណើត ឯធីតាទៅខានស្អែក។

ពាក្យថា **ស្អែក ខានស្អែក** ជាគុណកិរិយាកាលនៃកិរិយា **នឹងទៅ ទៅ**។

#### ៦.១.៤- គុណកិរិយាយបរិមាណ

គុណកិរិយាបរិមាណ ជាពាក្យប្រាប់កម្រិតនៃកិរិយាសព្ទ។ ឧ. ណាស់ ពេក ច្រើន តិច...។

ឧទាហរណ៍៖ គាត់មកដល់យឺតពេក ដូចនេះចំណូលខាតក្រាស់ដែរ។

ពាក្យថា **ពេក ក្រាស់**ជាគុណកិរិយាបរិមាណប្រាប់កម្រិតរបស់គុណកិរិយា **យឺត** និងកិរិយា **ក្រាស់**។

### ៦.១.៥- គុណកិរិយាសំណួរ

គុណកិរិយាសំណួរ ប្រើសម្រាប់សួររកកាល បំណែប ហេតុផលជាដើម។ ឧ. ហេតុអ្វី...? ដូចម្ដេចបានជា...? អង្កាល់?...។

- **សួររកហេតុផល៖**
  - **ហេតុអ្វី**បានជាគាត់ឈប់រៀន?
  - **ហេតុដូចម្ដេច**បានជាគាត់មានគ្រោះថ្នាក់?
- **សួររកកាល៖**
  - សុខទៅស្រុក**អង្កាល់**?
  - **អង្កាល់**គាត់ត្រឡប់មកវិញ
- **សួររកបែបផែន៖**
  - តើឯងយល់**ដូចម្ដេច**?
  - ចុះគាត់មើលឃើញ**ម៉េច**?

## ៦.២- ថ្នាក់របស់គុណកិរិយា

គុណកិរិយាអាចនៅខាងដើម ចន្លោះ(ក្នុង) និងចុងល្បះ។

### ៦.២.១- នៅខាងដើមល្បះ

គុណកិរិយានៅខាងដើមល្បះ

- **ស្អែក**គាត់ចេញដំណើរទៅវិញហើយ។
- **សព្វថ្ងៃ**វិទ្យាសាស្ត្រជឿនលឿនណាស់។

### ៦.២.១- នៅចន្លោះ(ក្នុង)ល្បះ

គុណកិរិយានៅខាងដើមល្បះ

- គាត់ទៅវិញ**ថ្ងៃស្អែក**នេះហើយ។
- វិទ្យាសាស្ត្រ**សព្វថ្ងៃ**ជឿនលឿនណាស់។

### ៦.២.១- នៅចុងល្បះ

គុណកិរិយានៅខាងដើមល្បះ

- គាត់ទៅវិញ**ថ្ងៃស្អែក**។
- វិទ្យាសាស្ត្រជឿនលឿនណាស់**សព្វថ្ងៃ**។

## ៧- ចំណងធ្នាក់ ឬធ្នាក់

ចំណងធ្នាក់ ឬធ្នាក់ គឺជាពាក្យសម្រាប់ចងកន្សោមពាក្យដើម្បីបង្កើតកន្សោមមានធ្នាក់។ ឧ. ក្បែរ ជិត នឹង ក្នុង ជាមួយ ដល់ ទៅកាន់ របស់...។ កន្សោមមានធ្នាក់កើតមកពី ធ្នាក់ និងកន្សោម។

ឧទហរណ៍៖ យើងជិះរត់យន្ត<u>លើ</u>ផ្លូវនេះហើយ ទីតាំងយើងទៅជិតដល់ហើយដែរ។

យើងដើរកម្សាន្ត<u>លើ</u>ភ្នំបូកគោ<u>ក្បែរ</u>ជ្រោះពពកវិល។

ពាក្យថា **លើ** ជាធ្នាក់ចងកន្សោមកិរិយា **ជិះរថយន្ត** នឹងកន្សោមនាម **ភ្នំបូកគោ**។

### ៧.១- កន្សោមមានធ្នាក់

កន្សោមមានធ្លាក់(កមធ) ជាកន្សោមនាម ឬកន្សោមកិរិយា ឬកន្សោមទាំងឡាយណាដែលមានធ្នាក់នៅជាមួយចងកន្សោមនឹងកន្សោម។

កន្សោមមានធ្នាក់ មានធាតុកន្សោម និងធ្នាក់។

**ធ្នាក់** + **កន្សោម** = **កន្សោមមានធ្នាក់**។ ឧ. គោដើរ<u>**ក្បែរ**</u><u>ភ្លឺស្រែ</u>។

### ៧.២- បម្រើបម្រាស់ធ្នាក់

ធ្នាក់អាចប្រើជា៖

- **ភ្ជាប់កិរិយាសព្ទទៅនឹងនាម៖**

ឧទាហរណ៍៖

សុខនិយាយ<u>**ជាមួយ**</u>សំ។ ឯសំនិយាយ<u>**ទៅកាន់**</u>សុខវិញយ៉ាងសុភាពរាបសារ។

ពាក្យថា **ជាមួយ** ភ្ជាប់ កិរិយា **និយាយ** ទៅនឹងនាម**សំ**។ ឯពាក្យថា **ទៅកាន់** ភ្ជាប់កិរិយា **និយាយ**ទៅនឹងនាម**សុខ**។

- **ភ្ជាប់នាមទៅនឹងនាម៖**

សុខ<u>**នឹង**</u>សំនិយាយទៅកាន់ពូសៅជាកូន<u>**របស់**</u>តាសយ។

ពាក្យថា **នឹង** ភ្ជាប់ នាម **សុខ** ទៅនឹងនាម **សំ**។ ឯពាក្យថា **របស់** ភ្ជាប់នាម **កូន** ទៅនឹងនាម**តាសយ**។

**កំណត់សម្គាល់៖** នាមខ្លះអាចប្រើក្នុងមុខងាររបស់ធ្នាក់

**ចន្លោះ៖** ផ្ទះខ្ញុំនៅ<u>**ចន្លោះ**</u>សាលារៀន និងវាលស្រែ។

**កណ្តាល៖** សាលារៀនយើងសង់<u>**កណ្តាល**</u>ភូមិ។

**ខាង៖** គាត់ពូកែ<u>**ខាង**</u>កីឡាបាល់ទាត់។

## ៨- ចំណាចឈ្នាប់ ឬឈ្នាប់

### ៨.១- ឈ្នាប់ចង

**ឈ្នាប់ចង** គឺជាពាក្យចំណងសម្គាល់ទំនាក់ទំនងគ្នារវាងល្បះ និងល្បះ ឬរវាងធាតុផ្សេងៗក្នុងល្បះ។ ឧ. និង និងហើយ ហើយនិង ហើយ ឬ ឬក៏ ឬជា តែ ប៉ុន្តែ...។

ឧទាហរណ៍៖

- ពូសៅលីចបកាប់ **និង**ចបជីក។
- សុខជាមនុស្សឧស្សាហ៍ធ្វើការ **តែ**ខ្ជិលរៀនបន្តិច។

ឈ្នាប់ចងមានជាលក្ខណៈផ្សេងៗគ្នាដូចជា៖

- **បូកចូលគ្នា៖** និង ហើយ ហើយនិង ព្រមទាំង ...
- **បំបែកពីគ្នា៖** ឬ ឬក៏ ឬជា ...
- **ជំទាស់៖** តែ ប៉ុន្តែ ...

**កំណត់សម្គាល់៖**

- **ឈ្នាប់ចង** នៅខាងដើមល្បះ
  - គាត់ធ្វើខុស **ប៉ុន្តែ**គាត់ពុំហ៊ានសារភាព។
  - បងចូលចិត្តរៀន **តែ**ប្អូនចូលចិត្តកីឡា។
- **ឈ្នាប់ចង** នៅខាងដើមធាតុនៃល្បះ
  - ធីតាទើបតែចេញពីរៀន **ហើយ**នាងជួយការងារផ្ទះយ៉ាងល្អ។
  - តើអ្នកចូលចិត្តអានសៀវភៅ **ឬ**ចូលចិត្តស្តាប់ **ឬ**ចូលចិត្តមើលជាសាច់រឿង ?

### ៨.១- ឈ្នាប់ឃ្លា

**ឈ្នាប់ឃ្លា** គឺជាពាក្យចំណង សម្រាប់សម្គាល់ទំនាក់ទំនងរវាងឃ្លា និងឃ្លាផង និងសម្រាប់បង្កើតឃ្លាណេបថែមទៀតផង។ ឧ. ថា ព្រោះ ពីព្រោះ ដើម្បី ដើម្បីនឹង បើ ប្រសិនបើ លុះ លុះណា កាលណា ទោះ ថ្វីដ្បិត ថ្វីដ្បិតតែ...។

សិក្សាល្បះ៖

ម្តាយសុខប្រាប់សុខថា គាត់ទៅផ្សារមួយសន្ទុះ។

យើងឃើញថា **ម្តាយសុខប្រាប់សុខ** ជាល្បះមួយ ឯ **គាត់ទៅផ្សារមួយសន្ទុះ**ជាល្បះមួយទៀត។

យើងឃើញថាល្បះតាំងពីរ ភ្ជាប់ដោយឈ្នាប់ឃ្លា «**ថា**» ដើម្បីភ្ជាប់ឱ្យ ៖

- **ម្តាយសុខប្រាប់សុខ** ជាកន្សោមប្រធាន

- **ថា** មានមុខងារជា**ឃ្លារណោបកម្មបទ**
- **គាត់ទៅផ្សារមួយសន្ទុះ** ជាកន្សោមនាមកម្មបទ។

ឈ្នាប់ឃ្លាមានជាលក្ខណៈផ្សេងៗគ្នាដូចជា៖

– សម្រាប់ប្រើក្នុងឃ្លារណោបកម្មបទ ឬគុណប្រធាន៖
  - ថា៖ ខ្ញុំយល់ថា គេមានជំនឿយ៉ាងមុតមាំណាស់។

    ខ្ញុំពុំយល់ថា គេមានជំនឿយ៉ាងនេះសោះ។
  - ជា៖ ខ្ញុំពុំដឹងជា គេមានជំនឿយ៉ាងនេះសោះ។

– សម្រាប់ប្រើក្នុងឃ្លារណោបកម្មទេសកាល៖
  - **ហេតុ៖** ព្រោះ ពីព្រោះ មូលហេតុ...
  - **ចំណង៖** ដើម្បី ដើម្បីតែ ដើម្បីនិង...
  - **បំណើ៖** បើ ប្រសិនបើ ប្រសិនបើជា...
  - **កាល៖** លុះ ល្ងក លុះណាតែ...
  - **ទំនាស់៖** ទោះបី ថ្វីដ្បិត ទោះបើជា ក៏ដោយ...

## ៩. ឧទានសព្ទ

ឧទានសព្ទ គឺជាពាក្យសម្រាប់គ្រាប់សូរធម្មជាតិ ឬជាពាក្យសម្រាប់សម្តែងចំណាប់អារម្មណ៍ សភាពភ្ញាក់ផ្អើល។ ឧ. យី! អើ! អឺៗ, វ៉ូ! យូ! , រឹង! ប្រុច! ប្រុយ!...

### ៩.១- គ្រាប់សូរ

- ផ្គរលាន់គ្រឹម! គ្រឹម!
- ខ្យល់បក់ហ៊ូ! ហ៊ូ!

### ៩.២- សូរឧទានឡើង

- **អូ!** ឯងមកហើយហ្អី?
- **យី!** ចំជាធ្វើបានស្អាតណាស់!

### ៩.៣- គ្រាប់សភាពកិរិយាសព្ទ

- ទន្សាយបោលរឹង!
- ឆ្កែដេញទន្សាយប្រុយកន្ទុយឆ្កឹង!

## ផ្នែកទី៣៖ កន្សោមពាក្យ

### ១- អំពីកន្សោមពាក្យ

#### ១.១- កន្សោមពាក្យ

កន្សោមពាក្យ ជាបណ្តុំពាក្យមិនមានលទ្ធភាពជាឃ្លា មាននាទីច្បាស់លាស់ ជាចំណែកនៃឃ្លា និងល្បះ។

#### ១.២- ប្រភេទកន្សោមពាក្យ

កន្សោមពាក្យមានច្រើនប្រភេទដូចជា៖ កន្សោមនាម កន្សោមកិរិយា កន្សោមគុណនាម កន្សោមគុណកិរិយា និងកន្សោមមានធ្នាក់។

**កន្សោមនាមខ្មែរ** ជាតុបង្គោលគឺនាមជាតុទី១។ ឯជាតុរណប គឺជាតុទី២ និងជាតុបន្តខាងស្តាំ។

ឧទាហរណ៍៖

- តុល្អ «តុ» ជាជាតុបង្គោល ឯ «ល្អ» ជាជាតុរណប
- តុនេះល្អ «តុ» ជាជាតុបង្គោល ឯ «នេះ» និង«ល្អ»ជាជាតុរណប។

**កន្សោមកិរិយា**ខ្មែរយើង ជាតុបង្គោលគឺកិរិយាទី១។ ឯជាតុរណប គឺជាតុទី២(គុណកិរិយាកម្ម)

ឧទាហរណ៍៖

- សំ**ដើរលឿន**។
- សុខ**ដើរយឺត**។
- កសិករ**ធ្វើស្រែចម្ការ**។
- គាត់**រៀបចំនង្គ័លនោស់**។

**កន្សោមគុណនាម** គុណនាមជាជាតុទី១ គុណកិរិយាជាជាតុទី២។

ឧទាហរណ៍៖

- កសិករដាំដំណាំបាន**ល្អណាស់**។
- ទោះមានការលូតលាស់យឺត តែមានផល**ល្អប្រសើរ**។

**កន្សោមគុណកិរិយា** គុណកិរិយាទី១ជាជាតុបង្គោល គុណកិរិយាទី២ ជាជាតុរណប។

ឧទាហរណ៍៖

- គោបោល**លឿនណាស់**។
- ខ្យល់**គ្រដាក់ខ្លាំងអស្ចារ្យ**។

## ២- កន្សោមនាម

### ២.១- ធាតុនៃកន្សោមនាម

ជាធាតុដែលចាត់ទុកថាជាកន្សោមនាម។

ឧទាហរណ៍៖

- **ក្រុមទី១ មានធាតុមួយ និងពីរ៖**

សៀវភៅជារបស់សំ។ វាសំខាន់ណាស់សម្រាប់សំ។

សៀវភៅនេះជារបស់សំ។

- **ក្រុមទី២ មានធាតុច្រើន៖**

សៀវថ្មីនេះជាសិស្សល្អ គេបានរាល់ថ្ងៃវាបានពិន្ទុល្អ។

សៀវភៅក្បែរតុឈើ។

ពូសុខឪពុករបស់សំ អញ្ជើញមកហើយ។

សៀវភៅដែលនៅលើតុ ជារបស់សំ។

**សង្ខេប៖**

- **ក្រុមទី១**
  - ជាតុតែមួយ
    សៀវភៅ ជាកន្សោមនាមប្រធាន។
    វា (ជាសព្វនាមជំនួសឱ្យសំ) ជាកន្សោមនាមប្រធាន។
  - ជាតុពីរ
    សៀវភៅនេះ ជាកន្សោមនាមប្រធាន។
- **ក្រុមទី២**
  - ជាតុច្រើន
    សៀវភៅថ្មីនេះ ជាកន្សោមនាមប្រធាន។
- **ការកើតឡើងនៃកន្សោមនាម**
  - ជាតុជានាម

    ឧ. សៀវភៅនេះ។

  - ជាតុជាគុណនាម

៤. សៀវភៅ<u>**នេះ**</u>។

- <u>**កន្សោមនាមពង្រីកបានដោយសារៈ**</u>
  - គុណនាមប្រក្រតី (គុ) មាននាទីជាគុណបទ
  - កន្សោមមានថ្នាក់ (កមថ) មាននាទីជាកម្មបំពេញបទ
  - កន្សោមនាម (កន) មាននាទីឧបបទ
  - ឃ្លារណប

ពាក្យ ឬកន្សោមពាក្យសម្រាប់ធ្វើមានឱ្យរីក ហៅថា «ពង្រីក»នៃនាម(ព=ពង្រីក)។ ពង្រីកបែបនេះ ហៅថា «ពង្រីករណប»

**សន្និដ្ឋានៈ**

យើងអាចសន្និដ្ឋានបានថា កន្សោមមានរូបរាងពីរយ៉ាងគឺៈ

- **រូបរាងតូច**
  - <u>**សៀវភៅ**</u> ជា**នាមអសាធារណ៍**
  - <u>**វា**</u> ជា**សព្វនាម**
  - នាម(សៀវភៅ)+គុណមានកំណត់(នេះ)
- **រូបរាងរីក ឬពង្រីករូបរាង**
  - នាម(សៀវភៅ)+គុណមានប្រក្រតី(ថ្មី)
  - នាម(សៀវភៅ)+កន្សោមមានថ្នាក់(ក្បែរតុឈើ)
  - នាម(ពូសុខ)+កន្សោមនាម(ឪពុករបស់សំ)
  - នាម(សៀវភៅ)+ឃ្លារណប(ដែលនៅលើតុ)
- **កន្សោមនាម នាមអាចរីកបានដូចនេះៈ**
  - **កន → ន + ព + កំ**
  - **ព → កគុ(កន្សោមគុណនាម)**
  - **កគុ → គុ + កគុណ(កន្សោមគុណកិរិយា)**
  - **កគុណនាម → គុណ + គុណ(គុណកិរិយា)**

**៤. ចេកទុំល្អណាស់មួយស្និតនេះ**ជាបង្អែមល្អក្រៃពេក។

យើងបំបែកកន្សោមនាមខាងលើដូចនេះ







- **ចេកទុំល្អណាស់មួយស្និតនេះ** ជា**កន្សោមនាមប្រធាន** នៃកិរិយា «**ជា**»។
- **ទុំល្អណាស់** ជា**កន្សោមគុណនាម** ជា**គុណបទ**នៃប្រធាន «**ចេក**»។
- **ល្អណាស់** ជា**កន្សោមគុណកិរិយា** បញ្ជាក់លក្ខណៈឱ្យគុណនាម «**ទុំ**»។
- **ណាស់** ជា**គុណកិរិយា ឬកិរិយាវិសេស** បញ្ជាក់លក្ខណៈឱ្យគុណនាម«**ល្អ**»។

## ២.២- ពង្រីកនៃកន្សោមនាម

### ២.២.១- ពង្រីករណប

កន្សោមនាមអាចកើតឡើងដោយនាមតែមួយ។ ធម្មតានាមត្រូវមានកំណត់នៅជាមួយ។ លើសពីនេះទៅទៀតកន្សោមនាមអាចកើតឡើងដោយនាមមួយ និងកន្សោមនាមមួយដទៃទៀត ដែលជារណបរបស់នាមនោះ៖

កន្សោមនាមអាចពង្រីកដោយ «ពង្រីករណប»ដូចខាងក្រោម៖

- គុណនាម ឬកន្សោមគុណនាម( គុណបទ )
- កន្សោមមានធ្នាក់( កម្មបំពេញបទ )
- កន្សោមនាម( ឧបបទ )
- ឃ្លារណប។

### ២.២.១.១- គុណនាមប្រក្រតី

គុណនាម ឬកន្សោមគុណនាមប្រក្រតី ពង្រីករបស់កន្សោមនាមក្នុងល្បះ។

ឧ. ចេកទុំល្អណាស់មួយស្និតនេះ ជាបង្អែមល្អក្រៃពេក។

កន្សោមគុណនាម «ទុំល្អណាស់» ជាគុណបទរបស់កន្សោមនាម «ចេក» ក្នុងល្បះខាងលើ។

«ទុំ» ជាគុណនាម ឯ«ល្អណាស់»ជាកន្សោមគុណកិរិយាបញ្ជាក់ន័យឱ្យ«ទុំ»។

### ២.២.១.២- កម្មបំពេញបទ

កម្មបំពេញបទ ជាកម្មទាំងឡាយណាសម្រាប់បំពេញជាកម្មបទរបស់ប្រធាន។

ឧទាហរណ៍៖ ឆ្មា**<u>របស់បងសំ</u>**...។

ក្នុងកន្សោមនាម **«ឆ្មារបស់បងសំ»**

**«ឆ្មា»** ជាកន្សោមនាមបង្គោល។

**«របស់បងសំ»** ជាពង្រីករបស់នាម។

សង្កេតឃើញថា៖ ក្នុងល្បះ**«ឆ្មា»** និង **«ឆ្មារបស់បងសំ»** មានមុខងារជាកន្សោមនាមដូចគ្នា។

**ក- សំណង់និងមុខងារ**

ឧទាហរណ៍៖ សួនបន្លែ**<u>នៃផ្ទះចាស់មួយ</u>**

មួកមួយ**<u>របស់កម្មករម្នាក់</u>**

យើងសង្កេតឃើញថា

- កន្សោមនាម «**សួនបន្លែនៃផ្ទះចាស់មួយ**» មានកន្សោមពីរគឺ «**សួនបន្លែ**»ជាធាតុបង្គោល ឯ «**នៃផ្ទះចាស់មួយ**» ជាពង្រីករបស់ធាតុបង្គោល។ ពង្រីកនេះបំពេញសេចក្ដីសេចក្ដីរបស់ធាតុបង្គោលឱ្យកាន់តែច្បាស់ឡើង ដូចនេះ ពង្រីកនោះ ជាកម្មបំពេញបទរបស់«**សួនបន្លែ**»។
- កន្សោម**នាម** «**មួកមួយរបស់កម្មករម្នាក់**» មានកន្សោមពីរគឺ«**មួកមួយ**» ជាធាតុបង្គោល ឯកន្សោម«**របស់កម្មករ**»ជាកម្មបំពេញបទ។
- ពាក្យថា «**នៃ របស់** »ជាធ្នាក់សម្រាប់ធ្វើឱ្យទាក់ទងគ្នារវាងធាតុបង្គោលភ្ជាប់ទៅនឹងនាមដោយសារធ្នាក់«**នៃ របស់**» ។ គេប្រើវាសម្រាប់បង្ហាញឱ្យជាក់លាក់នូវមនុស្ស សត្វ វត្ថុ ដែលសម្ដែងឡើងដោយនាម។ វាកម្រិតភាពជាក់លាក់របស់នាម ដោយប្រាប់ជាពិសេសនូវម្ចាស់កម្មសិទ្ធិ។

**ខ- នាមនីយកម្ម**

**ឧទាហរណ៍៖**

| **ល្បះ(ល)** | | **កន្សោមនាម(កន)** |
|---|---|---|
| សុខមានដៃពីរ | → | ដៃពីររបស់សុខ |
| រទេះភ្លើងមកដល់ | → | ការមកដល់នៃរទេះភ្លើង |
| សុខសប្បាយចិត្ត | → | សេចក្ដីសប្បាយចិត្តរបស់សុខ |

**យើងសង្កេតឃើញថា**

**ល្បះ(ល)** **កន្សោមនាម(កន)**

ល → កន១ + កកិ កន → កន២ + ពង្រីក

កន១ → រទេះភ្លើង មកដល់(កន១) ⇨ ជាធាតុបង្គោល

កកិ → មកដល់ នៃរទេះភ្លើង ⇨ ពង្រីក

- កន្សោមនាម ប្រធាននៃល្បះប្ដូរជាពង្រីក
- កន្សោមកិរិយានៃល្បះប្ដូរជាធាតុបង្គោល

កន១ → ពង្រីក

កកិ → កន២

ដូចនេះកម្មរបស់នាមមួយចំនួនបានមកអំពីនាមនីយកម្ម គឺការប្ដូរឈ្មោះជាកន្សោមនាម។

ឧទាហរណ៍នេះ៖ ឧទ្យានមួយនៃទីក្រុងធំមួយ...។

កន → កន +ពង្រីក

កន → ន + កំ

កន → កមធ

កន → ធ + កន

កន → ន + ពង្រីក




### ២.២.១.៣- ឧបបទ

ឧទាហរណ៍៖

សុខ <u>**មិត្តខ្ញុំ**</u>ប្រឹងរៀនណាស់។

អាលុក <u>**ឆ្កែសំ**</u>ដេញខាំកណ្ដុរ។

វិបី <u>**នរោត្តម**</u>ស្អាតជាងគេ។

ក្នុងនាទីជាឧបបទនេះ គឺៈ ពាក្យថា «មិត្តខ្ញុំ» ជាឧបបទនៃពាក្យ «សុខ» ជាមនុស្សតែមួយ

ពាក្យថា «ឆ្កែសំ» ជាឧបបទនៃពាក្យ «អាលុក» ជាសត្វតែមួយ

ពាក្យថា «នរោត្តម» ជាឧបបទនៃពាក្យ«វិថី» ជាកន្លែងតែមួយ

យើងសង្កេតឃើញថា នាមឧបបទ ប្រើសម្រាប់បញ្ជាក់ន័យរបស់នាមមួយទៀតដោយសម្តែងមនុស្ស សត្វ ឬវត្ថុដូចគ្នា។ ឧបបទ អាចក្លាយជាគុណប្រធានបានដែរ។

### ២.២.១.៤- ឃ្លារណាប

គេអាចពង្រីកនាម ដោយបន្ថែម«ឃ្លារណាប»។

ឧទាហរណ៍ៈ សិស្ស **<u>ដែលខំរៀន</u>** តែងតែប្រលងជាប់

កសិករ **<u>ដែលអស់កម្លាំង</u>** អង្គុយដោយស្ងៀមស្ងាត់។

លះ សិស្សដែលខំរៀនតែងតែប្រលងជាប់។




យើងសង្កេតឃើញថា

- ឃ្លារណា «ដែលខំរៀន» ប្រើជាគុណនាម បញ្ជាក់ន័យឱ្យ «សិស្ស»។ ឃ្លារណាបបែបនេះជាប់ជិតស្និទ្ធនឹងនាម។ **ដែលខំរៀន** ជាប់ជិតស្និទ្ធនឹង **សិស្ស** ដែលបំពេញនាទីជាប្រធាននៃកិរិយា **តែងតែប្រលង**។
- ឃ្លារណាប «ដែលអស់កម្លាំង» ប្រើជាគុណនាមបញ្ជាក់ន័យឱ្យ «កសិករ»។ វាជាធាតុមួយនៃកន្សោមនាម។

ដូចនេះ«ឃ្លារណប» ជាពង្រីកនៃធាតុបង្គោលក្នុងកន្សោមនាម។ ពង្រីកបែបនេះសម្រាប់បញ្ជាក់ន័យរបស់ធាតុបង្គោល។

**២.២.២.១- កន្សោមនាម +ឈ្នាប់+កន្សោមនាម**

ឧទាហរណ៍៖ បងប្រុសសំ និងបងស្រីសំទៅស្រែ។

យើងឃើញថា «បងប្រុសសំ» និង«បងស្រីសំ» ជាកន្សោមនាមប្រធានរបស់កិរិយា «ទៅ»។ ហើយមាន«និង» ជាឈ្នាប់សម្រាប់ចងកន្សោមទាំងពីរឱ្យជាប់គ្នា។

ដូចនេះ «ពង្រីកមិនរណប» កាលណាមុខងារជាតុបន្ថែមដូចគ្នានឹងមុខងារជាតុចាស់។ បើគេលុបជាតុចាស់ និងឈ្នាប់ចោល គេនឹងឃើញទម្រង់ដំបូងត្រលប់មកវិញ។

**២.២.២.២- កន្សោមនាមរីក +ឈ្នាប់+កន្សោមនាមរីក**

កនរីក → កន + ព.រណប គឺ

កនរីក → កន + កម្មបំពេញបទ

កនរីក → កន + គុណបទ

កនរីក → កន + ឧបបទ

កនរីក → កន + ឃ្លារណប

**ក- កូនរបស់ពូសុខនិងកូនរបស់ពូសៅ ទៅសាលា។**

ចេញមកពីល្បះខាងក្រោមនេះ

- កូនរបស់ពូសុខទៅសាលា។
- កូនរបស់ពូសៅទៅសាលា។

យើងមានកន្សោមនាមរីក«កូនរបស់ពូសុខ» និង «កូនរបស់ពូសៅ»មានមុខងារដូចគ្នាគឺជាប្រធានរបស់កិរិយា«ទៅសាលា»។

**ខ- គាត់ទិញបន្ទាត់ក្រហមមួយ និងប៊ិកក្រហមមួយ។**

ចេញពីល្បះខាងក្រោមនេះ

- គាត់ទិញបន្ទាត់ក្រហមមួយ។
- គាត់ទិញប៊ិកក្រហមមួយ។

យើងមានកន្សោមនាមពង្រីក«បន្ទាត់ក្រហម» និង«ប៊ិកក្រហម»មុខងារជាកម្មបទ។

**គ- ជួយមើលអាវស និងសំពត់ក្រហម ដែលខ្ញុំទើបនឹងទិញនេះ។**

- ខ្ញុំទើបនឹងទិញអាវសមួយ
- ជួយមើលអាវសនេះ

→ **ជួយមើលអាវសដែលខ្ញុំទើបនឹងទិញនេះ។**

- ខ្ញុំទើបនឹងទិញសំពត់ក្រហមមួយ
- ជួយមើលសំពត់ក្រហមនេះ

→ **ជួយមើលសំពត់ក្រហមដែលខ្ញុំទើបនឹងទិញនេះ។**

យើងមានកន្សោមនាមពង្រីក« អាវសដែលខ្ញុំទើបនឹងទិញ» «សំពត់ក្រហមដែលខ្ញុំទើបនឹងទិញ» មាននាទីជាកម្មបទ។

ឧទាហរណ៍ទាំង៤នេះ បង្ហាញឱ្យឃើញថា ជាតុបន្ថែមសុទ្ធតែមានមុខងារ(ប្រធាន និងកម្មបទ...) ដូចគ្នានឹងជាតុចាស់។

### ២.២.២.៣- កន្សោមនាម +ឈ្នាប់+ពង្រីកនៃកន្សោម

ក្នុងល្បះ៖

- កុមារនេះឧស្សាហ៍ និងឈ្លាសវៃណាស់។
- សៀវភៅថ្មីដែលគេចូលចិត្តអាន បានផ្ដល់ចំណេះដឹងថ្មីដល់ខ្លួនគេ។
- សុខជាកសិករ និងជាស្វាមីដ៏ល្អក្នុងគ្រួសារ។

យើងលុបជាតុបន្ថែម(ពង្រីកមិនរណប)ដោយគ្មានធ្វើឱ្យទម្រង់ល្បះផ្លាស់ប្ដូរឡើយ៖

- កុមារនេះឧស្សាហ៍~~និងឈ្លាសវៃ~~ណាស់។ → កុមារនេះឧស្សាហ៍ណាស់។
- សៀវភៅថ្មី~~ដែលគេចូលចិត្តអាន~~ បានផ្ដល់ចំណេះដឹងថ្មីដល់ខ្លួនគេ។
  → សៀវភៅថ្មីបានផ្ដល់ចំណេះដឹងថ្មីដល់ខ្លួនគេ។
- សុខជាកសិករ ~~និងជាស្វាមី~~ដ៏ល្អ និងឆ្លាតវៃ។ → សុខជាកសិករដ៏ល្អ និងឆ្លាតវៃ។

**ជាតុបន្ថែម(ពង្រីកមិនរណប)មានមុខងារ(គុណបទ)កម្មបំពេញបទ (ឧបបទ)ដូចគ្នានឹងពង្រីកចាស់។**

កំណត់សំគាល់៖ «ពង្រីកមិនរណប» ជួនកាលភ្ជាប់ទៅនឹងជាតុចាស់ ដោយដាក់បន្តបន្ទាប់ពុំមានឈ្នាប់ទេ។

ឧទាហរណ៍៖ ឪពុកម្ដាយខ្ញុំទៅស្រែ។ មិនត្រូវការចាំបាច់ដាក់ ឈ្នាប់ «និង»។

គាត់ដឹកគោដៃម្ខាង កណ្ដៀតកញ្ជើដៃម្ខាងទៀត។ មិនត្រូវការចាំបាច់ដាក់ ឈ្នាប់ «និង»។

កុមារ រៀនពូកែច្រើនតែមានឥរិយាបថល្អ។ មិនត្រូវការចាំបាច់ដាក់ ឈ្នាប់ «ដែល»។

## ២.៣- មុខងារកន្សោមនាមក្នុងល្បះ

នៅក្នុងល្បះកន្សោមនាមមានមុខងារច្រើនយ៉ាង៖

### ២.៣.១- មុខងារជាប្រធាន ឬកន្សោមនាមប្រធាន

ប្រធាន ឬកន្សោមនាមប្រធាន ជាកន្សោមពាក្យនៅខាងឆ្វេងកិរិយាសម្រាប់ចង្អុលបង្ហាញមនុស្ស សត្វវត្ថុនានាដែលធ្វើអំពើ ឬដែលប្រកបដោយសភាពលក្ខណៈបែបណាមួយ។

ឧ. **កម្មករចំណាស់ម្នាក់**លើកឥដ្ឋដំរ។

**គ្រូបង្រៀនទាំងអស់**ជាសសរទ្រូងនៃការអប់រំ។

**សម្តីគាត់**និយាយមកកាន់យើង។

**យើងអាចតាងល្បះដូចតទៅ៖**

**ក- តាងជាប្រអប់**

ល → កម្មករចំណាស់ម្នាក់លើកឥដ្ឋដំរ។

ល → គ្រូបង្រៀនទាំងអស់ជាសសរទ្រូងនៃការអប់រំ។







**ខ- ចង្កោម ឬមែកជាង**

ល → កម្មករចំណាស់ម្នាក់លើកឥដ្ឋដំរ។

ល → គ្រូបង្រៀនទាំងអស់ជាសសរទ្រូងនៃការអប់រំ។






### ២.៣.២- មុខងារជាកម្មបទ ឬកន្សោមនាមកម្មបទ

មុខងារជាកម្មបទ បែងចែកជាពីរគឺ កម្មបទផ្ទាល់ និងកម្មបទមិនផ្ទាល់

ឧ. ជីតាកំពុងអាន<u>**សៀវភៅគណិតវិទ្យា**</u>។

សំដើរទិញសៀវភៅឱ្យ<u>**ប្អូន**</u>។

<u>**យើងអាចតាងល្បះដូចតទៅ៖**</u>

**ក- តាងជាប្រអប់**

ល → ជីតាកំពុងអានសៀវភៅគណិតវិទ្យា។

ល → សំដើរទិញសៀវភៅឱ្យប្អូន។

ល្បះ(ល)




ល្បះ(ល)




**ខ- ចង្កោម ឬមែកជាង**

ល → ជីតាកំពុងអានសៀវភៅគណិតវិទ្យា។




ល → សំដើរទិញសៀវភៅឱ្យប្អូន។



### ២.៣.៣- មុខងារជាគុណប្រធាន ឬកន្សោមនាមគុណប្រធាន

កន្សោមនាមគុណប្រធាន គឺជាកន្សោមនាមដែលជាធាតុរបស់កិរិយានៅជាប់នឹងកិរិយាសម្រាប់បង្ហាញឯកលក្ខណភាពនៃប្រធាន ឬសកម្មភាពលក្ខណភាពនៃប្រធាន។

ឧទាហរណ៍៖ សុខជា<u>**កសិករ**</u>។

បងរបស់សុខជា<u>**កម្មករដ៏ប្រសើរ**</u>។

<u>**យើងអាចតាងល្បះដូចតទៅ៖**</u>

**ក- តាងជាប្រអប់**

ល → សុខជាកសិករ។ ល → បងរបស់សុខជាកម្មករដ៏ប្រសើរ។

ល្បះ ល្បះ







**ខ- ចង្កោម ឬមែកធាង**

ល → សុខជាកសិករ។ ល → បងរបស់សុខជាកម្មករដ៏ប្រសើរ។






## ៣- កន្សោមគុណនាម និងកន្សោមគុណកិរិយា

### ៣.១- កន្សោមគុណនាម(កគុ)

កន្សោមគុណនាមជាកន្សោមពាក្យដែលមានគុណនាមជាបង្គោល ហើយត្រូវគេប្រើបញ្ជាក់លក្ខណៈឱ្យនាម។

#### ៣.១.១- នាទី

ឧទាហរណ៍៖ សានជាកសិករល្អ។

គាត់មានគោធាត់ៗ។

កុមារជាសិស្សឧស្សាហ៍និងឆ្លាតវៃនេះ ប្រលងជាប់លេខមួយ។

ពាក្យថា «**ល្អ ធាត់ៗ ជាឧស្សាហ៍និងឆ្លាតវៃ**» ជាកន្សោមគុណនាមប្រើបញ្ជាក់ន័យសេចក្ដីដល់ប្រធាននៅខាងឆ្វេងកិរិយាបង្គោលជា។

#### ៣.១.២- ទម្រង់

កគុ → គុ(គុណនាម) ឧ. សំជាក្មេង**ឆ្លាត**។

កគុ → គុ + គុណ(គុណកិរិយា) ឧ. សំជាក្មេង**ឆ្លាតវៃ**។

កគុ → គុ + គុណ+ គុណ ឧ. សំជាក្មេង**ឆ្លាតវៃណាស់**។

កគុ → គុ +កមធ ឧ. សំជាក្មេង**ឆ្លាតនៃថ្នាក់**។

### ៣.២- កន្សោមគុណកិរិយា(កគុណ)

កន្សោមគុណនាម ជាកន្សោមពាក្យដែលមានកិរិយា គុណនាម និងគុណកិរិយាជាបង្គោល ប្រើសម្រាប់បញ្ជាក់លក្ខណៈឱ្យកិរិយា គុណនាម និងគុណកិរិយា។

#### ៣.២.១- នាទី

ឧទាហរណ៍៖ សុខដើរ**លឿន**។

ទោចភ្ញំយំ**ឭៗ**។

សំរៀន**ពូកែខាងអក្សរសាស្ត្រខ្មែរ**។

ពាក្យថា «**លឿន ឭៗ ពូកែខាងអក្សរសាស្ត្រខ្មែរ**» ជាកន្សោមគុណកិរិយា ប្រើសម្រាប់បញ្ជាក់លក្ខណៈឱ្យកិរិយា គុណនាម និងគុណកិរិយា។

#### ៣.២.២- ទម្រង់

កគុណ → គុណ(គុណកិរិយា) ឧ. សំរៀន**ឆ្លាត**។

កគុណ → គុណ + គុណ(គុណកិរិយា) ឧ. សំរៀន**<u>ឆ្លាតណាស់</u>**។

កគុណ → គុណ+ គុណ+ កន ឧ. សំរៀន**<u>ពូកែណាស់ផ្នែកភាសាខ្មែរ</u>**។

កគុណ → គុណ +កមធ ឧ. សំរៀន**<u>លឿនខាងអំណាន</u>**។

កគុណ → គុណ +កមធ+ គុណ+ កន ឧ. សំរៀន**<u>ពូកែខាងអំណានជាងសុខ</u>**។

## ៤- កន្សោមមានធ្នាក់

កន្សោមនាមដែលនៅខាងក្រោយកិរិយាមានពីរយ៉ាងគឺ៖

- កន្សោមនាម(កមបទផ្ទាល់ ឬកបផ)
- កន្សោមមានធ្នាក់(កមធ)

កន្សោមមានធ្នាក់ មានមុខងារពីរយ៉ាងគឺ៖

- កម្មបទមិនផ្ទាល់(កបម)
- កម្មបទទី២ ឬក២

### ៤.១- កម្មបទមិនផ្ទាល់(កបម)

កម្មបទមិនផ្ទាល់គឺជាកន្សោមមានធ្នាក់ដែលជាជាតុកន្សោមកិរិយាសម្រាប់បញ្ចប់សេចក្តីរបស់កិរិយា។

#### ៤.១.១- នាទី

ឧទាហរណ៍៖ ពូសុខធុញ**<u>នឹងការងារ</u>**។ គាត់តែងនិយាយ**<u>អំពីផលវិបាក</u>**។

គាត់ដើរ**<u>ក្បែរផ្លូវធំ</u>**។

យើងមានកន្សោម «**នឹងការងារ អំពីផលវិបាក ក្បែរផ្លូវធំ**» ជាកន្សោមមានធ្នាក់ភ្ជាប់នឹងកិរិយាសព្ទ។

### ៤.២- កម្មបទទី២ (ក២)

កម្មបទទី២ គឺជាកន្សោមនាមដេលជាជាតុរបស់កន្សោមកិរិយាហើយវាភ្ជាប់ទៅនឹងកិរិយាដោយធ្នាក់។

#### ៤.២.១- នាទី

ឧទាហរណ៍៖ សុខឱ្យសៀវភៅមួយក្បាលដល់សៅ។

បងវាផ្ញើសំបុត្រពីរច្បាប់ដល់ខ្ញុំ។

យើងមានកម្មបទពីរគឺ កម្មបទទី១ (ផ្ទាល់) «**សៀវភៅ សំបុត្រ**» និងកម្មបទទី២(មិនផ្ទាល់)គឺ «**សៅ ខ្ញុំ**» ដែលមានធ្នាក់នៅជាប់នឹងកន្សោមនាមគឺ «**ដល់**»។

## ៤.៣- កម្មទេសកាល

### ៤.៣.១- នាទី

ឧទាហរណ៍៖ ពេល**ព្រលឹមស្រាងៗ**អ្នកភ្ជួរ និងរាស់ទៅដល់ស្រែ**មុនអ្នកស្ទូង**។

អ្នកស្ទូង**កណ្ដាប់នៅដៃ** ស្ទូងស្រូវដោយរីករាយ និងប្រញាប់ប្រញាល់។

អ្នកជញ្ជូនកណ្ដាប់ដើរកាត់**ទួលមួយកន្លែង**។

យើងឃើញថា៖

- កន្សោម «**ព្រលឹមស្រាងៗ មុនអ្នកស្ទូង**» ជាកម្មប្រាប់កាល។
- កន្សោម « **កណ្ដាប់នៅដៃ** » ជាកម្មប្រាប់បែបបទនៃកិរិយា ភ្ជួរ ឈរ ស្ទូង។
- កន្សោម « **ទួលមួយកន្លែង** » ជាកម្មកន្លែងនៃកិរិយា។

<u>សម្គាល់៖ កម្មទេសកាល</u>

១- កម្មទេសកាលកន្លែង ឬកម្មកន្លែងសម្រាប់ប្រាប់ទីកន្លែងរបស់កិរិយា

២- កម្មទេសកាលកាល ឬកម្មកាលសម្រាប់ប្រាប់ពេលវេលានៃអំពើ

៣- កម្មទេសកាលបំណែប ឬកម្មបំណែប សម្រាប់ប្រាប់បែបបទរបស់អំពើ

៤- កម្មទេសកាលហេតុ ឬកម្មហេតុសម្រាប់ប្រាប់ហេតុនៃអំពើ

៥- កម្មទេសកាលបំណង ឬកម្មបំណង សម្រាប់ប្រាប់បំណងនៃអំពើ

៦- កម្មទេសកាលប្រើដើម្បី៖

- បញ្ជាក់សេចក្ដីរបស់កិរិយា
- បញ្ជាក់សេចក្ដីរបស់នាម។

## ផ្នែកទី៤៖ ល្បះ

### ១.ល្បះជាអ្វី?

#### ១.១- និយមន័យ

ល្បះគឺជាបន្សំរវាងកន្សោមពាក្យនិងកន្សោមពាក្យ។ វាមានន័យគ្រប់គ្រាន់ ស្តាប់បាន។

ក.ឧទាហរណ៍

- សុខចូលចិត្តម្ហូបខ្មែរ។
- បងវាចូលចិត្តម្ហូបខ្មែរ។
- មាវាចូលចិត្តម្ហូបខ្មែរ។
- សុខតែសៀវភៅនេះ
- សុខមើលក្តារខៀន។
- ស្តាប់លោកគ្រូ។

ខ.ពិនិត្យឧទាហរណ៍

ឧទាហរណ៍ខាងលើបង្ហាញឱ្យឃើញថា

- ក្រុមពាក្យនីមួយៗ បញ្ចប់ដោយសញ្ញា(។)
- ក្នុងក្រុមពាក្យមួយខណ្ឌៗ សង្កាត់ពាក្យពីរកន្លែងអាចផ្លាស់បាន នឹងសង្កាត់ពាក្យដទៃទៀត ដែលមានលក្ខណៈសមស្រប ដូចជាសង្កាត់ពាក្យកន្លែងទី១ «សុខ» អាចផ្លាស់គ្នានឹង «បងវា»ឬមាវា»។

សង្កត់ពាក្យកន្លែងទី២ «ចូលចិត្តម្ហូបខ្មែរ» អាចផ្លាស់គ្នានឹង «តែងសៀវភៅនេះ» ឬ«មើលក្តារខៀន»...។

សង្កាត់ពាក្យមួយកន្លែងៗ ដូចនេះហៅថា «កន្សោមពាក្យ»។ ហើយកន្សោមពាក្យនេះចែកជា៖

- កន្សោមនៅខាងឆ្វេងហៅថា កន្សោមនាម
- កន្សោមនៅសល់ហៅថា កន្សោមកិរិយា។

❖ ល្បះកើតឡើងដោយសារកន្សោមនាម និងកន្សោមកិរិយា។

ល → កន + កកិ

**កំណត់សម្គាល់៖** កន្សោមកិរិយាអាចកើតឡើងដោយ៖

កកិ → កិ + កន

ឧទាហរណ៍ ៖ សុកទិញសៀវភៅមួយ។

ល → កន + ចំណង + កន

ឧទាហរណ៍ ៖ សំប្រទះនឹងខ្លា។ («នឹង» ជាពាក្យចំណង)

កកិ → កិ(ជា) + កន

ឧទាហរណ៍ ៖ សៅជាសិសស្ស។

កកិ → ∅ + កន (∅ = គ្មានកិរិយា)

ឧទាហរណ៍ ៖ តុនេះពណ៌ឈាមជ្រូក។

**១.២- ធាតុនៃឈ្មោះ**

❖ ឈ្មោះបង្កើតឡើងដោយកន្សោមនាមប្រធាន និងកន្សោមកិរិយាសព្ទ។

ទម្រង់ ៖ ល → កនប្រ + កកិ (កន្សោមនមប្រធាននៅខាងឆ្វេងកិរិយា)

កិរិយា ជាកិរិយាអកម្ម

| ឧទាហរណ៍ | |
|---|---|
| កន្សោមនាម | កន្សោកិរិយា |
| ប្រធាន | កិរិយាអកម្ម |
| ក្អែក<br>មាន់<br>កុមារម្នាក់ | បូល<br>រងាវ<br>រត់ |

❖ ឈ្មោះកើតឡើងដោយកន្សោមនាមប្រធាន និងកន្សោមកិរិយាដែលមានកន្សោមនាមកម្មបទផ្ទាល់នៅជាមួយ។

ទម្រង់ ៖ ល → កនប្រ + កកិ

កកិ → កិ + កន

កន្សោមនាម ជាប្រធាននៅខាងឆ្វេងកិរិយា។

កិរិយា ជាកិរិយាសកម្ម។

កន្សោមនាម ជាកម្មបទផ្ទាល់នៅខាងស្តាំកិរិយា។

| ឧទាហរណ៍ | | |
|---|---|---|
| កន្សោមនាម | កន្សោមកិរិយា | |
| ប្រធាន | ប្រធាន | កិរិយាអកម្ម |
| កសិករ<br>អ្នកចម្ការ<br>អ្នកក្រុង | លី<br>មាន់<br>កុមារម្នាក់ | នង្គ័ល<br>ទូក<br>បន្លែ |

❖ ល្បះកើតឡើងដោយកន្សោមនាមប្រធាន និងកន្សោមកិរិយាដែលមានកន្សោមកម្មបទមិនផ្ទាល់នៅជាមួយ។

ទម្រង់ ៖ ល → កនប្រ + កកិ

កកិ → កិ + កមជ

កមជ → ចំណងធ្នាក់ + កន

- កន្សោមនាមប្រធាន នៅខាងឆ្វេងកិរិយា។
- កិរិយា ជាកិរិយាសកម្ម។
- កន្សោមនាមមានធ្នាក់ «កមជ» នៅខាងស្តាំកិរិយា។
- កន្សោមនាមមានធ្នាក់ ជាកម្មបទមិនផ្ទាល់។

| ឧទាហរណ៍ | | | |
|---|---|---|---|
| កន្សោមនាម | កន្សោមកិរិយា | | |
| ប្រធាន | កិរិយាសកម្ម | កន្សោមមានធ្នាក់ | |
| | | ធ្នាក់ | កន្សោមនាម |
| បង | និយាយ | ជាមួយ | ប្អូន |
| តាសំ | និយាយ | ពី | អតីតកាលគាត់ |
| នាសុភី | ជួប | នឹង | មិត្តរបស់នាង |
| កុមារសំ | ទុកចិត្រ | លើ | ចំណេះវា |

❖ ល្បះកើតឡើងដោយកន្សោមនាមប្រធាន និងកន្សោមកិរិយាដែលមានកន្សោមនាមកម្មបទផ្ទាល់ផងកន្សោមនាមកម្មបទមិនផ្ទាល់ផង។

ទម្រង ៖ ល → កនប្រ + កកិ

កកិ → កិ + កន + កមជ

កមជ → ធ្នាក់ + កន

- កន្សោមនាមប្រធាន នៅខាងឆ្វេងកិរិយា។
- កិរិយា ជាកិរិយាសកម្ម។
- កន្សោមនាមកម្មបទផ្ទាល់ នៅខាងស្តាំជាប់នឹងកិរិយា។
- កន្សោមនាមកម្មបទមិនផ្ទាល់ នៅខាងស្តាំជាប់នឹនកម្មបទផ្ទាល់។

| ឧទាហរណ៍ | | | | |
|---|---|---|---|---|
| កន្សោមនាម | កន្សោមកិរិយា | | | |
| ប្រធាន | កិរិយាសកម្ម | កន្សោមនាម | កន្សោមមានធ្នាក់ | |
| | | | ធ្នាក់ | កន្សោមនាម |

| | | | | |
|---|---|---|---|---|
| សំ<br>មារា<br>លោកគ្រូ<br>ប្រធានក្រុម | ប្រាប់<br>ឱ្យ<br>ឱ្យ<br>ប្រគល់ | ដំណឹង<br>ប៊ិកមួយ<br>ដំបូន្មាន<br>ភារកិច្ច | ដល់<br>ចំពោះ<br>ដល់<br>ចំពោះ | ពូវា<br>ប្អូនវា<br>និស្សិត<br>កូនក្រុម |

❖ ល្បះកើតឡើងដោយកន្សោមនាមប្រធាន និងកន្សោមកិរិយាដែលមានកន្សោមនាមគុណប្រធាននៅជាមួយ។

ទម្រង់ ៖ ល → កនប្រ + កកិ

កកិ → កិជា + កន

- កន្សោមនាមប្រធាន នៅខាងឆ្វេងកិរិយា។
- កិរិយាក្រមជា ដូចជា «ជា ក្លាយជា ប្រែជា ដូចជា.....»។
- កន្សោមនាមគុណប្រធាន នៅខាងស្តាំកិរិយា។

| ឧទាហរណ៍ | | |
|---|---|---|
| កន្សោមនាម | កន្សោមកិរិយា | |
| ប្រធាន | ក្រុមកិរិយា«ជា» | កន្សោមនាម |
| ថ្ងៃអាទិត្យ<br>សុភី<br>ប្អូនឯង<br>បុប្ផា<br>កុមារនេះ | ជា<br>ជា<br>នឹងក្លាយជា<br>ប្រែជា<br>ហាក់ដូចជា | ថ្ងៃសម្រាក<br>ប្អូនស្រីខ្ញុំ<br>មនុស្សល្អម្នាក់<br>នារីម្នាក់<br>ពើសបន្តិច |

❖ កំណត់សម្គាល់ ៖ ល្បះខ្លះកើតឡើងដោយកន្សោមនាមប្រធាន និងកន្សោមកិរិយាដែលមានតែកន្សោមនាមមួយហើយគ្មានកិរិយា។

| ឧទាហរណ៍ | | |
|---|---|---|
| កន្សោមនាម | កន្សោមកិរិយា | |
| ប្រធាន | កិរិយា | កន្សោមនាម |
| សៀវភៅនេះ<br>សៀវភៅនោះ<br>បងខ្ញុំ | ∅<br>∅<br>∅ | ពណ៌ស<br>ពណ៌ខ្មៅ<br>អាយុ៥០ឆ្នាំ |

### ១.៣- ប្រភេទល្បះ

ល្បះមាន ៤ប្រភេទគឺ ៖

- ល្បះបញ្ជាក់
- ល្បះបញ្ជា

- ល្បះសំណួរ
- ល្បះឧទាន

### ១.៣.១- ល្បះបញ្ជាក់

ល្បះបញ្ជាក់ទុកដូចជា «ល្បះបាត» នៃល្បះឯទៀត ព្រោះល្បះដទៃទៀតចេញពីល្បះបញ្ជាក់។ ល្បះបញ្ជាក់ងាយមាន៖

- កន្សោមនាមប្រធានចាំបាច់
- កន្សោមកិរិយា ចាំបាច់ដែលមានកិរិយា និងកន្សោមកម្មបទ ឬកិរិយា «ជា» និងគុណនាមប្រធាន ។
- កន្សោមមានជ្នាក់ (កម្មទេសកាល) បន្ទាប់បន្សំ។

ក្នុងល្បះបញ្ជាក់ ប្រធាននៅខាងឆ្វេងកិរិយា ឯកម្មបទនៅខាងស្តាំកិរិយា។

ឧទាហរណ៍៖ - សុខសំពះឪពុកម្តាយ។

- សំដាំពោត។

- គាត់វាយវា។

### ១.៣.២- ល្បះបញ្ជា

ល្បះបញ្ជាសម្រាប់បើដើម្បី៖

- បង្គាប់ ៖ ទៅ! ចូរអ្នកទៅចុះ!
- ឱ្យដំបូន្មាន៖ ចូរអ្នកប្រយ័ត្នគ្រោះថ្នាក់។
- ធ្វើសំណូមពរ៖សូមឱ្យមិត្តបានសុខ។
- អង្វរ៖ សូមបងអភ័យទោស។

ក្នុងល្បះបញ្ជា មានប្រើពាក្យ ៖

- ចូរ នៅដើមល្បះបញ្ជា (អ្នកធំទៅអ្នកតូច)
- សូម នៅដើមល្បះបញ្ជា (អ្នកតូចទៅអ្នកធំ)
- សុំ នៅដើមល្បះបញ្ជា (អ្នកធំនិយាយទៅកាន់អ្នកតូច)

### ១.៣.៣- ល្បះសំណួរ

ល្បះសំណួរសម្រាប់សួរទៅអ្នកប្រាស្រ័យជាមួយ៖

- សុកទៅផ្សារឬទេ?
- តើឯងទៅបម្រើម្តាយឯងឬទេ?
- បដិវត្តន៍យើងបានជ័យជំនះនៅថ្ងៃណា?

ល្បះសំណួរចែកជា៖

**ក. ល្បះសំណួរទាំងមូល**

ល្បះសំណួរទាំងមូលគឺជាល្បះណាដែលសួរទៅលើល្បះទាំងអស់។ ចម្លើយមានពីរគឺ បាទ/ចាស ឬទេ។ ល្បះសំណួរអាចកើតឡើងដោយសារះ

- ល្បះបញ្ជាក់មានសំនៀងសួរ ( ? )
  សុកទៅស្រែ ?
  វាដាំកូនដូង ?
- តើ+ល្បះបញ្ជាក់
  តើសុកទៅស្រែ ?
  តើវាដាំកូនដូង ?
- ល្បះបញ្ជាក់+ឬទេ ?
  សុកទៅស្រែឬទេ ?
  វាដាំកូនដូងឬទេ ?

**ខ. រីឯសិល្បះសំណួរផ្នែកវិញ** គឺជាល្បះណាដែលសួរទៅលើធាតុណាមួយនៃល្បះ។

ចម្លើយជាកន្សោមនាម។ ល្បះសំណួរផ្នែកកើតឡើងដោយះ

- ប្រើសព្វនាមសំណួរះ វាជានរណា ?
- ប្រើគុនាមសំណួរះ ឯងទៅថ្ងៃណា ?
- ប្រើគុណកិរិយាសំណួរះ ហេតុអ្វីវានជាវាទៅស្រែ ?

**គ. ល្បះសំណួរមានប្រើច្រើនយ៉ាងដូចជាះ**

- ល្បះសំណួរបែប«បញ្ជាក់»
- ល្បះសំណួរបែប «ឬទេ»
- ល្បះសំណួរបែប «ដណ្ដឹងឹ»
- ល្បះសំណួរពេញ និងល្បះសំណួរមិនពេញ។
  ឯចម្លើយវិញក៏មានច្រើនណាស់ដែរដូចជាះ
- ល្បះចម្លើយស្រប
- ល្បះចម្លើយមិនស្រប
- ល្បះចម្លើយវែង
- ល្បះចម្លើយខ្លី។

**គ.១- ល្បះសំណួរបែបបញ្ជាក់**

ល្បះនេះសម្រាប់សួរបញ្ជាក់សេចក្ដី ព្រោះអ្នកសួរដឹងពុំច្បាស់ះ

| សំណួរ | ចម្លើយ«បាទ» | ចម្លើយ «ទេ» |
|---|---|---|
| ពីរកញ្ចប់<br>វត្ថុហ្នឹង | បាទ! ពីរកញ្ចប់<br>បាទ! វត្ថុហ្នឹង | ទេ! ១កញ្ចប់។<br>ទេ! មិនមែនវត្ថុហ្នឹងទេ។ |

**គ.២- ល្បះសំណួរបែប«ឬទេ»**

| សំណួរ | ចម្លើយស្រប«បាទ» | ចម្លើយមិនស្រប «ទេ» |
|---|---|---|
| គាត់ស្ដាប់បានឬទេ?<br>អ្នកយល់ឬទេ? | បាទ! គាត់ស្ដាប់បាន។<br>បាទ! ខ្ញុំយល់ហើយ។ | ទេ! គាត់ស្ដាប់ពុំបានទេ។<br>ទេ! ខ្ញុំមិនយល់ទេ។ |

**គ.៣-ល្បះសំណួរបែប«ដណ្ដឹង»**

សំណួរនេះសម្រាប់ដណ្ដឹងសួរដោយអ្នកសួរពុំដឹងសោះឧ៖

| សំណួរ | ចម្លើយ«ខ្លី» | ចម្លើយ «វែង» |
|---|---|---|
| អ្នកណាធ្វើមុន?<br>ឯងហៅអ្នកណា? | ខ្ញុំ។<br>បងសំ។ | ខ្ញុំធ្វើមុន។<br>ខ្ញុំហៅបងសំ។ |

### ១.៣.៤- ល្បះឧទាន

ល្បះឧទាន ជាល្បះប្រើសម្រាប់សម្ដែងមនោសញ្ចេតនា ឬចំណាប់អារម្មណ៍ភ្លាមៗ។ វាមានសំនៀងពិសេសប្លែកពីល្បះសំណួរ។ ល្បះឧទានបញ្ចាក់ដោយសញ្ញាឧទាន(!)។

ឧទាហរណ៍៖

- ពូឯងអីក៏ប្រសប់អ្វីម្ល៉េះ!
- ឱ នារីនេះណាស់តើ

➢ ល្បះឧទានប្រើ «អីក៏....ម្ល៉េះទេ!

➢ ប្រើ«...............អ្វីម្ល៉េះទេ!»

ស្រូវឆ្នាំនេះល្អអ្វីម្ល៉េះទេ!

➢ ប្រើ «ណាស់ន៎! ណាស់តើ! អស្ចារ្យណាស់! ពេកកន្លង!»

- រូបចម្លាក់នេះសមពេកណាស់!
- រូបចម្លាក់នេះសមពេកណាស់!
- កុមារនេះចេះគួរសមណាស់តើ!

➢ ប្រើពាក្យឧទានខាងដើមល្បះ

- ឱ! រូបអើយ!

➢ ប្រើពាក្យ«អើយ»

- ឱ! រូបខ្ញុំអើយ!
- ញអើយអញ!

➢ ប្រើសញ្ញាឧទាន(!)

- ទ័ពយើងបានជោគជ័យហើយ!

## ២- ប្រភេទរង (ឬទម្រង់) នៃល្បះ

ល្បះនីមួយៗ មានរូបរាងបីយ៉ាងគឺ

- ល្បះស្រប ឬល្បះមិនស្រប
- ល្បះក័ត្តុ ឬល្បះកម្ម
- ល្បះធម្មតា ឬល្បះសង្កាត់

### ២.១- ល្បះស្រប និងល្បះមិនស្រប

ល្បះស្របប្រាប់អំពើអ្វីមួយដែលកើតឡើងពិតៗ។ ល្បះមិនស្របប្រាប់អំពើអ្វីមួយដែលពុំមានកើតឡើងទេ។

#### ២.១.១- ល្បះបញ្ជាក់

ល្បះបញ្ជាក់ស្រប ល្បះបញ្ជាក់មិនស្រប

ខ្ញុំទៅសាលារៀន។ ខ្ញុំមិនទៅសាលារៀន

| ល្បះបញ្ជាក់ស្រប | ល្បះបញ្ជាក់មិនស្រប |
|---|---|
| ខ្ញុំទៅសាលារៀន។ | ល្បះបញ្ជាក់មិនស្រប។ |
| ខ្ញុំចង់ទៅស្រែ។ | ខ្ញុំមិនចង់ទៅស្រែទេ។ |
| វានឹងទៅភ្នំពេញ។ | វានឹងមិនទៅភ្នំពេញទេ។ |
| គាត់នៅមើលឃើញ។ | គាត់នៅមើលមិនទាន់ឃើញ។<br>គាត់លែងមើលឃើញ។ |
| វាយកទៅបឹង។ | វាមិនទៅបឹងទេ។ |
| នោះគឺវា។ | នោះមិនមែនវាទេ។<br>នោះមិនគឺវាទេ។ |
| នោះជាកុក។ | នោះមិនមែនជាកុកទេ។ |
| មានមនុស្ស។ | គ្មានមនុស្ស។ |
| គាត់ចូលប្រជុំហើយ។ | គាត់មិនទាន់ចូលប្រជុំ។ |
| វារកឃើញហើយ។ | វារកពុំទាប់ឃើញទេ។ |

សង្កេតៈ ដើម្បីបង្កើតល្បះបញ្ជាក់មិនស្របគេត្រូវថែមល្បះបញ្ជាក់ស្របនូវពាក្យសម្រាប់បង្កើតភាពមិនស្របៈ

- មិន.........ទេឬ ពុំ..........ទេ
- មិនមែន......ទេឬ ពុំមែន......ទេ
- មិនទាន់.....ទេ ពុំទាន់.......ទេ។

○ តែកិរិយា

- គឺ ប្រើ «មិន គឺ...........ទេ» (ក៏បាន)
- ជា ប្រើ «មិនមែនជា.......ទេ»
- មាន ប្រើ «គ្មាន...........ទេ»។
- «មិន» ប្រើនៅខាងដើមកន្សោមកិរិយា
  ប្រើនៅចន្លោះ «នឹង» និង កិរិយា
  ប្រើនៅខាងឆ្វេងកិរិយាបំពេញ។
- «ទេ» ប្រើនោខាងចុះល្បះ។

**២.១.២- ល្បះបញ្ជា**

| ល្បះបញ្ជាក់ស្រប | ល្បះបញ្ជាក់មិនស្រប |
|---|---|
| បាញ់ទៅ។ | កុំបាញ់។ |
| ទៅរៀនចុះ។ | ចូរអ្នកកុំឱ្យវាទៅអី។ |
| ចូរអ្នកឱ្យវាទៅចុះ។ | ចូរអ្នកកុំឱ្យវាទៅអី។ |
| សុំឱ្យវាទៅផង។ | សុំកុំឱ្យវាទៅអី។ |
| យកវាមកណា។ | កុំយកវាមកណា។ |
| យកមកវ៉ី។ | កុំយកមកវ៉ី។ |
| ឯងត្រូវទៅ។ | ឯងមិនត្រូវទៅទេ។<br>ឯងត្រូវកុំទៅអី។ |

សង្កេតៈ ក្នុងល្បះមិនស្របគេប្រើៈ

«កុំ............អី»

«មិន............ទេ»

«កុំ..............វ៉ី»។

- «កុំ»នៅដើមកន្សោមកិរិយា
- «កុំ»នៅខាងស្តាំកិរិយាជំនួយ «សុំ» «ត្រូវ»....។
- «មិន» នៅខាងស្តាំកិរិយាជំនួយ «ត្រូវ».......។

❖ ក្នុងភាសាខ្មែរ ល្បះបញ្ជាគេអាចប្រើប្រធានក៏បានដែរ ដូចជាៈ

ឯងមិនត្រូវដើរលេងហួសហេតុពេកទេ។

ចូរអ្នកខំប្រឹងបំពេញភារកិច្ចបដិវត្តឱ្យបានល្អ។

**២.១.៣- ល្បះសំណួរ**

| ល្បះបញ្ជាក់ស្រប | ល្បះបញ្ជាក់មិនស្រប |
|---|---|
| តើឯងទៅផ្ទះឬទេ ? | តើឯងមិនទៅផ្ទះទេឬ ? |
| តើឯងចង់ទៅស្រែឬទេ ? | តើឯងមិនចង់ទៅស្រែទេឬ ? |
| តើឯងនឹងចេញទៅស្ពែកឬទេ ? | តើឯងមិនចេញទៅស្ពែកទៅឬ ? |
| តើវាមើលឃើញឬទេ ? | តើវាមើលមិនឃើញទេឬ ? |
| នោះគឺជាសញ្ជាជាតិឬទេ ? | នោះមិនគឺសញ្ញាជាតិទេឬ ? |
| មានគ្នាច្រើនឬទេ ? | គ្មានគ្នាច្រើនទេឬ ? |
| ឯងបានភ្ជួរហើយឬនៅ ? | ឯងមិនបានភ្ជួរទេឬ ? |
| ឯងឱ្យវាទៅដែរ ឬទេ ? | វាមិនចាំបាច់ទៅទេឬ ? |

សង្កេត៖

(១) «ឬទេ» ប្រើនៅខាងចុងល្បះសំណួរស្រប។

«ទេឬ» ប្រើនោខាងចុងល្បះសំណួរមិនស្រប

(២) **«សំណួរភ្ជាប់» ៖ ក្នុងភាសាខ្មែរយើង គេមានប្រើ**

សំណួរភ្ជាប់ក្នុងល្បះសំណួរ៖

- មេឃចង់ភ្លៀងអ៊ីចឹងមែនទ ?
- មេឃចង់ភ្លៀងមែនទេ ?
- ស្រូវឆ្នាំនេះល្អណាស់មែនទេ ?

ចំពោះសំណួរភ្ជាប់ «មិនមែន» គេអាចឆ្លើយថា «មែនហើយ» ក៏បាន «ពុំមែន» ក៏បាន។

ប៉ុន្តែអ្នកសួរចង់ឱ្យឆ្លើយថា «មែន» ព្រោះគេអាចដឹងច្បាស់រួចទៅហើយ (ថាពិត)

(៣) **សំណួរភ្ជាប់៖ ដទៃទៀត**

- ជួយខ្ញុំផងបានទេ ?
- កុំឡូឡាឮទេ ?
- ត្រូវខំរៀនស្តាប់បានទេ ?

សំណួរភ្ជាប់បែបនេះសម្រាប់បញ្ជាក់សេចក្តីខាងដើម និងបង្ខំអ្នកឱ្យស្តាប់ឱ្យធ្វើតាម។

(៤) **ក្នុងល្បះសំណួរគេអាចប្រើពាក្យ«តើ»ក៏បាន មិនប្រើក៏បាន។**

### ២.១.៤- ល្បះឧទាន

- ល្បះឧទានស្រប

ពួឯងអីក៏លូង់ម្ល៉េះទេ!

ឃោបលឯងល្អណាស់តើ!

យីអើ! ថ្ងៃនេះគំនិតឯងចម្លែកណាស់ន៎!

- ល្បះឧទានមិនស្រប

ពូឯងអីក៏មិនលូង់សោះអ៊ីចេះ

យីអើ! ថ្ងៃនេះ គំនិតឯងក៏មិនចម្លែកសោះអ៊ីចឹង!

## ២.២- ល្បះកត្តុនិងល្បះកម្ម

### ២.២.១- ល្បះបញ្ជាក់

- ល្បះបញ្ជាក់

សំវាយឆ្កែនោះ។

គេបានចម្ការនេះ។

យើងគោរពឪពុកម្ដាយយើង។

- ល្បះបញ្ជាក់កម្ម

ឆ្កែនេះត្រូវសំវាយ។

ឆ្កែនេះត្រូវវាយដោយសំ។

ឆ្កែនេះសំវាយ។

ចម្ការនេះត្រូវគេបាន។

ឪពុកម្ដាយយើងត្រូវយើងគោរព។

### ២.២.២- ល្បះសំនួរ

- ល្បះសំណួរក័ត្តុ

តើសំវាយឆ្កែនេះដែរឬទេ?

តើគេបានចម្ការនេះឬទេ?

- ល្បះសំណួរកម្ម

តើឆ្កែនេះត្រូវសំវាយឬទេ?

តើចម្ការនោះត្រូវគេបានឬទេ?

**២.២.៣- ល្បះឧទាន**

- ល្បះឧទានកត្តុ

ឱ! គេឆ្លាក់រូបនេះល្អអ្វីម្ល៉េះទេ!

ឱ! គេវាយឆ្មាខ្ញុំខ្លាំម្ល៉េះទេ!

- ល្បះឧទានកម្ម

ឱ! រូបនេះត្រូវគេឆ្លាក់ល្អអ្វីម្ល៉េះទេ!

ឱ! ឆ្មាខ្ញុំត្រូវគេវាយខ្លាំងម្ល៉េះទេ!

**២.៣- ល្បះធម្មតា និងល្បះសង្កត់**

ល្បះធម្មតាគឺជាល្បះមិនសង្កត់។ ល្បះសង្កត់គឺល្បះដែលគេនិយាយសង្កត់ទៅលើជាតុនាមួយ ដើម្បីពន្លេចឡើងឱ្យឃើញច្បាស់។ ល្បះសង្កត់កើតឡើងដោយះ

ក. ដាក់ពាក្យសំខាន់ដែលគេចង់បញ្ជាក់នៅដើមល្បះ៖

- **ល្បះធម្មតា**

ពីម្សិលមិញ ខ្ញុំប្រាប់សុខឱ្យទៅស្រែ។

- **ល្បះសង្កត់**

ខ្ញុំប្រាប់សុខឱ្យទៅស្រែ។

សុក ខ្ញុំប្រាប់វាឱ្យទៅស្រែ។

ពីម្សិលមិញនេះ ខ្ញុំប្រាប់សុកឱ្យទៅស្រែ។

ខ.ថែមពាក្យ «គឺ...ដែល»....ឬ

«គឺ...នេះហើយ ដែល»

ឧទាហរណ៍៖

គឺខ្ញុំដែលប្រាប់សុកឱ្យទៅស្រែ។

គឺសុកនេះហើយដែលខ្ញុំប្រាប់ឱ្យទៅស្រែ។

គឺម្សិលមិញនេះហើយដែលខ្ញុំប្រាប់សុកឱ្យទៅស្រែ។

គឺស្រែនោះហើយដែលខ្ញុំប្រាប់សុកឱ្យទៅ។

**គ.សង្កេតទី១**

ល្បះខ្លះអាចជា ល្បះកត្តុផង មិនស្របផង សង្កត់ផងះ

គឺសំនេះហើយដែលគេមិនវាយវា។

ឬល្បះកម្មផង និងមិនស្របផង សង្កត់ផង ៖

គឺចោរនេះហើយដែលមិនត្រូវគេវាយស្លាប់ដូចចោរដទៃ។

**ឃ. សង្កេតទី២**

ល្បះទោនីមួយៗអាចមានកម្មទេសកាលច្រើនដូចជា៖

- **កម្មកាល**

ពេល៖

ខែក្រោយគាត់នឹងទៅលេងស្រុកកំណើត។

រយៈពេល៖

តែក្នុងរយៈពេលដ៏ខ្លី កងទ័ពយើងវាយឈ្នះខ្មាំង។

- **កម្មកន្លែង**
    - គាត់ទៅស្រុកកំណើត។ (កន្លែងដែលគេទៅកាន់)
    - សំមកពីស្រែ។(កន្លែងដែលគេចាកចេញ)
    - ឆ្មាលោតតាមបង្អួច។(កន្លែងដេលគេឆ្លងកាត់)
- **កម្មហេតុ**
    - ស្រូវល្អព្រោះប្រើជី។
    - វាបានជោគជ័យក្នុងការងារ ព្រោះសេចក្ដីព្យាយាម។
    - ដោយសារតែចរិយាល្អរបស់វា សំទទួលបានសេចក្ដីរាប់អានពីគ្រប់មជ្ឈដ្ឋាន។
- កម្មបំណែប
    - សំធ្វើការដោយយកចិត្តទុកដាក់។
    - គាត់ភ្ជួរដីអំណាត់ក្រៃលែង។
    - កងទ័ពយើងវាយខ្មាំងដោយក្លាហាន។
- **កម្មមធ្យោបាយ ឬកម្មឧបករណ៍**
    - យើងដូសបាយនឹងវែកត្រលោក។
    - ខ្មែរយើងបរិភោគបាយដោយសមស្លាបព្រា។
    - គាត់ឆ្លងកាត់ទន្លេដោយទូក។
- **កម្មបំណង**
    - យើងសាងសងសាលារៀនសម្រាប់កូនចៅ។
    - យុវជនយើងខំរៀនដើម្បីអនាគត និងប្រទេសជាតិ។
- **កម្មប្រៀបធៀប**

- វាយំដូចក្មេង។
- សំធ្វើការដូចមនុស្សចាស់។

- **កម្មសហ**
  - គាត់ដើរលេងជាមួយគ្រួសារគាត់។
  - វាធ្វើការជាមួយមិត្តភក្តិវា។
- **កម្មលើកលែង**
  - គេទៅស្រែទាំងអស់គ្នាលើកលែងតែសុខ។
  - យើងទៅសាលាលើកលែងតែអ្នកឈឺ។
- **កម្មតម្លៃ**
  - សៀវភៅនេះថ្លៃ២០០០៛។
  - តុនេះថ្លៃ៥០០០០៛។
- **កម្មប្រភព**
  - វាចេញមកពីគ្រួសារកសិករ។
  - រូបនេះដកស្រង់ចេញពីរូបអង្គរ។
- **កម្មរង្វាស់**
  - ផ្ទះនោះមានកម្ពស់២០ម។
  - រូបនេះមានប្រវែង១០ម។
- **កម្មទម្ងន់**
  - ជីតាមានទម្ងន់៤២គីឡូក្រាម។
  - ស្រូវនេះមានទម្ងន់៥តោន។
- **កម្មរង្វាល់**
  - ធុងនេះមានចំណុះ២០ល។
  - ដប់នេះមានចំណុះ១ល។
- **កម្មរូបធាតុ**
  - អាគារសិក្សាខ្ញុំសង់ពីឈើ។
  - ផ្ទះខ្ញុំសង់ពីថ្ម។
- **កម្មទំនាស់**
  - សំប្រឹងធ្វើការទោះបីជួបនឹងការលំបាក។
  - វាបន្តការសិក្សាទោះក្រ។
- **កម្មបំណើ**
  - គេនឹងបានជោគជ័យបើខំប្រឹង។
  - ស្រែកហៅខ្ញុំក្នុងករណីចាំបាច់។

## ៣- ប្រភេទល្បះ

ល្បះមាន ៣បែបគឺ៖

- ❖ ល្បះទោល
- ❖ ល្បះផ្សំ
- ❖ ល្បះក្រង

### ៣.១- ល្បះទោល

#### ៣. ១.១- ទម្រង់មូលដ្ឋាននៃល្បះទោល

ល្បះទោលមានទម្រង់បាត (មូលដ្ឋាន) ៥យ៉ាង៖

- ល → កន១+កិ

  ឧទាហរណ៍៖ ក្មេងយំ។

- ល → កន១+កិ(ជា)+កន២

  ឧទាហរណ៍៖ សុកជាកសិករ។

- ល → កន១+កិ+កន២

  ឧទាហរណ៍៖ សំដឹកគោ។

- ល → កន១+កិ(ជា)+កន២

  ឧទាហរណ៍៖ ក្មេងយំ។

- ល → កន១+កិ+កមធ

  ឧទាហរណ៍៖ សុកនិយាយជាមួយសំ។

- ល → កន១+កិ+កន២+កមធ

  ឧទាហរណ៍៖ បូផាឱ្យសៀវភៅមួយដល់ខ្ញុំ។

ទម្រង់ល្បះទាំងបួនបែបខាងលើនេះ ជាទម្រង់បាត ហើយអាចមានកន្សោមកម្មទេសកាលបន្ថែមទៀត។

ឧទាហរណ៍៖ សំតែងតែគោរពឪពុកម្ដាយវារាល់ពេលចេញទៅសាលា។

(រាល់ពេលចេញទៅសាលា = កម្មកាល)

#### ៣.១.២- ប្រភេទនៃល្បះទោល

ល្បះទោមាន៤ប្រភេទ៖

- ល្បះបញ្ជាក់
- ល្បះបញ្ជា
- ល្បះសំណួរ

- ល្បះឧទាន។

### ៣.២- ល្បះផ្សំ

ល្បះផ្សំ គឺជាល្បះដែលកើតឡើងពីឃ្លាច្បង(ឃ្លាគោល/ល្បះគោល) និងឃ្លារណប(ល្បះរណប) ហើយភ្ជាប់គ្នាដោយសារឈ្នាប់ឃ្លា។ ឃ្លាអាចមានន័យគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់។

ល្បះទោលមាន «កនប្រ កិ កន និង កមធ ជាធាតុសំណង់ណាមួយ(នៃល្បះ)ជាល្បះ ឬក្នុងធាតុសំណង់មួយមានធាតុពង្រីកជាល្បះ។

យើងអាចពោលបានថា ល្បះផ្សំមាន «ឃ»៖

- «ឃ» ជាធាតុរបស់ «ល»
- «ឃ» ជាធាតុពង្រីករបស់៖
    - «កន» របស់ «ល»
    - «កកិ» ឬ«កិ»របស់«ល»

ឧទាហរណ៍ ៖ ល្បះទោល






### ៣.២.១ - បែបនៃល្បះផ្សំ

#### ៣.២.១.១- ល្បះផ្សំបែបទី១

ក. តាងល្បះជាប្រអប់




ខ. តាងល្បះជាមែកធាង




#### ៣.២.១.២- ល្បះផ្សំបែបទី២

ក. តាងល្បះជាប្រអប់



**ខ. តាងល្បះជាមែកធាង**




ឧទាហរណ៍ខាងលើបញ្ជាក់ថា ក្នុងល្បះផ្សំមាន៖

ក.បញ្ជាក់(កថាមិនផ្ទាល់)៖

- ឃ្លារណប បែប **កន** ឬ **ឃ្លានាម**
- ឃ្លារណប បែប **កគុ** ឬ **ឃ្លាគុណនាម**
- ឃ្លាទេសកាល

## ៣.២.២ - ឃ្លានាម

### ៣. ២.២.១- ប្រភេទនៃឃ្លានាម

ឃ្លានាម គឺជាឃ្លារណបដែលផ្លាស់កន្សោមនាម។ ឃ្លានាមសមមូលនឹងល្បះ។

ក. បញ្ជាក់(កថាមិនផ្ទាល់)៖

- ខ្ញុំនិយាយអីចេះ ៖ សំនឹងទៅដល់ស្រែស្អែក។
- ខ្ញុំនិយាយថា សំនឹងទៅដល់ស្រែស្អែក។

ខ. សំណួរ(កថាមិនផ្ទាល់)

- គាត់សួរឯងអ៊ីចឹង៖ ឯងទៅណា។
- គាត់សួរឯងថា ឯងទៅណា។

គ. បញ្ជា(កថាមិនផ្ទាល់)

- ខ្ញុំប្រាប់អ៊ីចេះ៖ ចូរឯងរកចបមួយ។
- ខ្ញុំប្រាប់ថា ចូរឯងរកចបមួយ។

### ៣. ២.២.២- មុខងារនៃឃ្លានាម

ឃ្លានាមមានមុខងារដូចជាកន្សោមនាមដែរ៖

### ៣. ២.២.២.១- ប្រធាន

- មិត្តខ្ញុំត្រូវរបួសយ៉ាងធ្ងន់នាំឱ្យខ្ញុំស្លុតចិត្ត។
- លោកគ្រូនិយាយមួយៗនាំឱ្យយើងស្រួលស្តាប់ណាស់។

(ល្បះទី១ អ្វីមួយនាំឱ្យខ្ញុំស្លុតចិត្ត

ល្បះទី២ មិត្តខ្ញុំត្រូវរបួសយ៉ាងធ្ងន់

ល្បះទី៣ មិត្តខ្ញុំត្រូវរបួសយ៉ាងធ្ងន់នាំឱ្យខ្ញុំស្លុតចិត្តណាស់។)

### ៣. ២.២.២.២- គុណប្រធាន

- ការពិតនោះគឺ (ថា) សាមគ្គីជាកត្តាជ័យជំនះ។
  (ការពិតនោះ គឺដូចនេះ ៖ សាមគ្គីជាកត្តាជ័យជំនះ)
- យោបល់ខ្ញុំគឺ (ជា) ស្រែយើងឆ្នាំនេះនឹងបានផលលើសឆ្នាំទៅ។

### ៣. ២.២.២.៣- កម្មបទផ្ទាល់

- គេប្រកាសអ្វីមួយ៖ ទឹកជំនន់ឡើងខ្លាំងណាស់។
  →គេប្រកាសថា ទឹកជំនន់ឡើងខ្លាំងណាស់។

### ៣. ២.២.២.៤- កម្មបទមិនផ្ទាល់

- គាត់គិតដល់អ្វីមួយ៖ ថ្ងៃប្រឡងជិតមកដល់ហើយ។
  →គេប្រកាសថា ថ្ងៃប្រឡងជិតមកដល់ហើយ។

**ឃ្លានាមអាចជាកម្មរបស់នាម ឬកម្មរបស់គុណនាមកិរិយា៖**

**១- កម្មរបស់នាម**

- យោបល់ថា យើងនឹងបានជោគជ័យនាំឱ្យយើងក្លាហាន។
  គំនិតថា ខ្លួននឹងប្រឡងជាប់ ធ្វើឱ្យសំសប្បាយចិត្តនឹងការរៀនណាស់។

**២- កម្មរបស់គុណនាមកិរិយា**

- សំសប្បាយចិត្តនឹងយើងបានរង្វាន់។
  វាព្រួយនឹងឪពុកវាមានជំងឺ។

### ៣.២.២.៣- ឃ្លានាមសំណួរមិនផ្ទាល់

ឃ្លានាមសំណួរមិនផ្ទាល់ជាឃ្លារណបអចលត៍ ហើយជាពង្រីករបស់កិរិយាសព្ទនៃល្បះ។ សំណួរមិនផ្ទាល់ ជាឃ្លានាមកើតឡើងដោយមានពាក្យដូចជា៖

- កាលណា ដូចម្តេច ឯណា អង្កាល ហេតុដូចម្តេច នរណា អ្វី.....នៅជាមួយនឹងកិរិយាបែប ប្រាប់ ដឹង មិនដឹង។

សំណួនមិនផ្ទាល់ មាន២យ៉ាងគឺ៖

**៣. ២.២.៣.១- សំណួរមិនផ្ទាល់ទាំងមូល**

សំណួរមិនផ្ទាល់ទាំងមូលសួរលើឃ្លាទាំងមូល។

ឧ.គាត់សួរខ្លួនឯងថា តើគាត់ទៅធ្វើការមែនឬទេ។

គាត់សួថា ស្រូវនេះ ជារបស់គាត់មែបឬទេ។

**៣. ២.២.៣.២- សំណួរមិនផ្ទាល់ផ្នែក**

សំណួរនេះឋិតនៅលើធាតុសំណង់ណាមួយនៃឃ្លារណបះ

ក. លើ កន ប្រធាន

ឧ. គាត់ចង់ដឹងថា មិត្តមួយណារកឯង។

អ្វីកើតឡើងនៅទីនោះ។

នរណាដើរមកនោះ។

ខ. លើ កន គុណប្រធាន

ឧ. វាពុំដឹងថា សំជានរណា។

សុកជាមនុស្សបែបណា។

ប្រធានយើងជាបងមួយណា។

គ. លើ កន កម្មបទផ្ទាល់

ឧ. ប្រាប់ខ្ញុំមើលថា ឯងធ្វើកំហុសអ្វីខ្លះ។

ឯងធ្វើអ្វី។

បងឯងទិញអ្វីខ្លះ។

ឃ. លើ កន កម្មបទផ្ទាល់

ឧ. វាចង់ដឹងថា ឯងនិយាយអំពីអ្វី។

វានិយាយនឹងនរណា។

គាត់គិតដល់អ្វី។

ង. លើ កន កម្មភ្ជាក់ងារ

ឧ.ខ្ញុំមិនដឹងថា វាត្រូវនរណាសម្លាប់។

វាត្រូវនរណាវាយ។

ច. លើ កន កម្មនៃគុណនាមកិរិយា

ឧ. គាត់សួរថា ឯងព្រួយនឹងអ្វី។

វាសប្បាយនឹងអ្វី។

ឆ. លើ កន កម្មទេសកាល

ឧ. វាចង់ដឹងថា វានៅទីណា។

ហេតុអ្វីវាមិនទៅស្រែ។

កាលណាវាទៅស្រែ។

### ៣.២.២.៤- គំនូសតាងល្បះ

**ក.គំនូសតាងដោយប្រអប់**




**ខ.គំនូសតាងមែកធាង**

ល→ គាត់សង្ឃឹមថា យើងនឹងបានសុភមង្គល។



### ៣.២.៣- ឃ្លាគុណនាម (ពង្រីករបស់នាម)

ឃ្លាគុណនាមជាឃ្លារណបអចល័តភ្ជាប់ទៅនឹងកន្សោមនាម ដោយសារសព្វនាមឈ្នាប់។ ឃ្លាគុណនាមសមមូលនឹងកន្សោមគុណនាម។ វាមាននាទីសម្ដែងគុណរបស់កន្សោមនាម។

ឃ្លាគុណនាមមាន ២យ៉ាងគឺ៖

#### ៣. ២.៣.១- ឃ្លាគុណនាមគុណបទ

ឃ្លាគុណនាមគុណបទនៅជាប់នឹងនាមដើម្បីបំពេញសេចក្ដីឱ្យនាមនោះ។គឺពុំអាចលុបឃ្លាគុណនាមគុណបទបានទេ។ បើគេលុបឃ្លាគុណបទ គេមុខជាពុំអាចយល់ន័យនៃល្បះនោះឡើយ៖

ឧ.យុវជនដែលខំជួយអម្បាញ់មិញ ជាមិត្តរួមអាវុធរបស់ខ្ញុំ។

(បើយើងលុបឃ្លាគុណនាម យើងបាន «យុវជនជាមិត្តរួមអាវុធរបស់ខ្ញុំ» ឃ្លាស្ដាប់ឃ្លាស្ដាប់ពុំបាន) គេអាចស្គាល់ឃ្លាគុណនាមគុណបទ ដោយសារគេអាចប្ដូរនាមយោង (នាមនៅដើមឃ្លាគុណនាមគុណបទ) នឹងពាក្យ «អ្នក អ្វី....»។

ដូចនេះ ល្បះផ្សំខាងលើ អាចសរសេរថា «អ្នកដែលខំជួយអម្បាញ់មិញ ជាមិត្តរួមអាវុធរបស់ខ្ញុំ»។

#### ៣.២.៣.២- ឃ្លាគុណនាមឧបបទ

ឃ្លាគុណនាម ឧបបទអាចលុបបានដោយគ្មានធ្វើឱ្យល្បះប្រែប្រួលឡើង។ វាពុំមានផ្ដល់ន័យចាំបាច់ដល់ឃ្លាច្បងឡើយ៖

- សុភាដែលខ្ញុំស្គាល់យូរហើយ ជាមិត្តដ៏ល្អរបស់ខ្ញុំ។
  ឃ្លាគុណនាមឧបបទអាចផ្លាស់នឹងល្បះដាក់ភ្ជាប់នឹងល្បះទី១៖
  →សុភាជាមិត្តដ៏ល្អរបស់ខ្ញុំ ហើយខ្ញុំស្គាល់វាយូរហើយ។

❖ កំណត់សម្គាល់

១.ឃ្លាគុណនាម អាចជាពង្រីករបស់កន្សោមនាមប្រធាន ឬកន្សោមនាមកម្មបទរបស់ល្បះ៖

- វារកទិញរទេះ ដែលត្រូវនឹងគោធំៗរបស់វា។
- សំដែលជាមិត្តតែម្នាក់របស់ខ្ញុំ អាចជួយដោះស្រាយបញ្ហាខ្ញុំបាន។

២. ឃ្លាគុណនាមខ្លះអាចសមមូលនឹងកម្មទេសកាល៖

➢ ហេតុ៖ បងខ្ញុំ **ដែលឈឺ** សម្រាកការងារ (ព្រោះឈឺ)។
➢ ទំនាស់៖ ឪពុកខ្ញុំ **ដែលឈឺ** នៅតែធ្វើការ (ទោះឈឺ)។
➢ បំណើះ មនុស្ស **ដែលធ្វើការនេះបានល្អ** ជាវីរជន (បើគាត់ធ្វើការនេះបានល្អ)។

៣. សព្វនាម ឈ្នាប់ «ដែល» ឋិតនៅខាងដើមឃ្លាគុណនាមជានិច្ច។

### ៣.២.៣.៣- គំនូសតាងល្បះ

ល → សំមើលចបកាប់ដែលឪពុកវាទើបនឹងទិញ។

ក- គំនូសតាងដោយប្រអប់




**ខ- គំនូសតាងដោយចង្កោម**

**ល₁ → លោកគ្រូបានអប់រំនិស្សិតដែលរៀននៅសាកលវិទ្យាល័យ។**



ល$_២$ → **សំមើលចបកាប់ដែលឪពុកវាទើបនឹងទិញ។**




### ៣.២.៤- ឃ្លាទេសកាល

#### ៣.២.៤.១- ឃ្លាទេសកាល

ឃ្លាទេសកាល សមមូលនឹងកន្សោមនាមមានធ្នាក់កម្មទេសកាល (ក្នុងល្បះទោល)។ ដូចនេះនៅក្នុងល្បះ៖

ពូសំទៅចម្ការ នៅ**ម៉ោង៦ព្រឹក**។

*កន្សោមនាមមានធ្នាក់កម្មទេសកាល*

បើគេផ្លាស់កន្សោមនាមមានធ្នាក់ «នៅម៉ោង៦ព្រឹក» នឹងល្បះ គេបានល្បះផ្សំមាន «ឃ្លាទេសកាល»៖

ពូសំទៅចម្ការ **កាលណាកវិយារបស់គាត់ជាំបាយរួចហើយ**។

ឃ្លាទេសកាល

ឃ្លាទេសកាលជាធាតុនៃល្បះ។

#### ៣.២.៤.២- មុខងារនៃឃ្លាទេសកាល

មុខងារនៃឃ្លាទេសកាលស៊ីគនានឹងមុខងារនៃកន្សោមនាមមានធ្នាក់ទេសកាលដែរ។

### ៣.២.៤.២.១- ឃ្លាទេសកាលប្រាប់កាល ឬឃ្លាកាល

ឃ្លាកាលស៊ីគ្នានឹងកន្សោមនាមមានធ្លាក់ទេសកាលប្រាប់កាល។ វាផ្ដើមដោយឈ្នាប់ឃ្លា(ឬឈ្នាប់រណប)៖ កាលណា កាលដែល ដល់ លុះ ដល់កាលណា ដល់ពេលដេល ពេលដែល ពេលកាល គ្រាដែល លុះតែ លុះត្រាតែ ទាល់តែ មុននឹង ទំរាំ ក្រោយ ក្រោយពី តាំងពី.........។

ឃ្លាកាលសម្រាប់ប្រាប់ពេលដេលកើតឡើងមុន ក្រោយ ឬជាមួយគ្នានឹងពេលនៃឃ្លាច្បង៖

**ក.១ អំពើនៃឃ្លាច្បងកើមុនអំពើនៃឃ្លារណប**

ទេសកាលបែនេះផ្ដើមដោយឈ្នាប់ឃ្លា៖ មុនពេល ទម្រាំ ទម្រាំតែ រហូត រហូតដល់ ទាល់តែ ទាល់តែដល់....៖

- <u>មុនពេលខ្ញុំសម្រេចចិត្ត</u> ខ្ញុំគិតហើយគិតទៀត។
- គាត់មើលសៀវភៅ <u>ទម្រាំម្ដាយគាត់មកដល់</u>។
- នៅទីនេះ <u>រហូតដល់គាត់ត្រឡប់មកវិញ</u>។
- វានៅចាំចម្ការ <u>ទាល់តែដល់សណ្ដែកល្មមបេះ</u>។

**ក.២ អពើនៃឃ្លាច្បងកើតក្រោយអំពើនៃឃ្លារណប**

ទេសកាលបែបនេះផ្ដើមដោយឈ្នាប់ឃ្លា៖ *តាំងពី ក្រោយពេលដែល បន្ទាប់អំពីពេល ....។*

- <u>តាំងពីគាត់ឈឺ</u> វាពុំដែលដើរលេងសោះ។
- <u>ក្រោយពេលដែលបដិវត្តបានជ័យជំនះ</u> ប្រជាជនបានសេចក្ដីសុខ។
- <u>ក្រោយពេលខ្ញុំគិតហើយគិតទៀត</u> ខ្ញុំក៏សម្រេចចិត្ត។

ក.៣ អំពើនៃឃ្លាច្បងនិងឃ្លារង កើតឡើងជាមួយគ្នា

ទេសកាលបែបនេះផ្ដើមដោយឈ្នាប់ឃ្លា៖ *នៅពេលដែល ដំណាលគ្នានឹងពេល...។*

- ពូសំលីនង្គ័លទៅស្រែនៅ <u>ពេលដែលកូនគាត់បរគោទៅស្រែដែរ</u>។
- វាចេញទៅសាលារៀន <u>ដំណាលគ្នានឹងពេលបងវាចេញទៅចម្ការ</u>។
- <u>នៅពេលដែលមេទាហើរចុះដី</u> កូនទាក៏រត់ស្រទៅរកមេវា។

កំណត់សម្គាល់៖

១.គេអាចប្រើ «កិរិយានាម» ជំនួសឃ្លាកាល កាលណាប្រធាននៃឃ្លាច្បងនិងប្រធាននៃឃ្លា កាលជាបុគ្គលតែមួយ៖

- គាត់គិត មុនគាត់និយាយ។

  មុននិយាយ។

២. គេអាចប្រើ «កិរិយាគុណនាម» ជំនួសឃ្លាកាលក៏មាន៖

- ក្នុងពេលដែលវាសើចរកមិត្តវា វាក៏ចាប់ដៃមិត្តវាយ៉ាងណែនដែរ។
- សើចរកមិត្តវាផង វាចាប់ដៃមិត្តវាយ៉ាងណែនបណ្ដើរ។
- សើចរកមិត្តវាបណ្ដើរ វាចាប់ដៃមិត្តយ៉ាងណែនបណ្ដើរ។

**៣.២.៤.២.២- ឃ្លាទេសកាលបំណង ឬឃ្លាបំណង**

ឃ្លាបំណងស៊ីគ្នានឹងកន្សោមនាមមានធ្នាក់ប្រាប់បំណង។ វាផ្ដើមដោយឈ្នាប់ឃ្លា៖ *ដើម្បី ឱ្យ ដើម្បីកុំឱ្យ ដើម្បីនឹង ខ្លាចឱ្យ កុំឱ្យ មិនឱ្យ...។*

- យើងប្រយុទ្ធគ្មានខ្លាចស្លាប់ ដើម្បីប្រទេសជាតិយើងបានឯករាជ្យនិងសេរីភាព។
- សុំនិយាយឱ្យខ្លាំងៗ ដើម្បីឱ្យយើងទាំងអស់គ្នាស្ដាប់ឮ។
- ដើរប្រយ័ត្នប្រយែង ខ្លាចបន្លាមុតជើង (ដើម្បីកុំឱ្យបន្លាមុតជើង ឬកុំឱ្យបន្លាមុតជើង)។
- ចូរឯងនិយាយយ៉ាងណាមួយ ឱ្យគេយល់បញ្ហានេះទាំងអស់គ្នា។

កំណត់សម្គាល់៖

១. គេប្រើ «កិរិយានាម» ជំនួសឃ្លាបំណង កាលនាឃ្លារណបមានប្រធានដូចគ្នានឹងឃ្លាច្បង៖

- គាត់ធ្វើការ ដើម្បីគាត់ចិញ្ចឹមឪពុកម្ដាយគាត់។
  ដើម្បីចិញ្ចឹមឪពុកម្ដាយគាត់។

២. បំណងអាចសម្ដែងឡើងដោយកន្សោមនាម៖

- ប្រយុទ្ធដើម្បីជាតិ។
- កាសែតសម្រាប់កុមារ។
- គាត់មកមើលប្អូន(កិរិយានាម)។
- វាធ្វើនេះក្នុងបំណងល្អ។

**៣.២.៤.២.៣- ឃ្លាទេសកាលហេតុ ឬឃ្លាហេតុ**

ឃ្លាហេតុស៊ីគ្នានឹងកន្សោមនាមមានធ្នាក់ប្រាប់ហេតុនៃអំពើក្នុងឃ្លាច្បង។ វាផ្ដើមដោយឈ្នាប់ឃ្លា « ពីព្រោះ ព្រោះ ដោយហេតុ ដោយហេតុតែ ហេតុតែ ដោយសារ ព្រោះតែ ត្បិត៖

- ឯងត្រូវតែរុំខ្លួនឱ្យជិត ព្រោះមេឃត្រជាក់ខ្លាំង។
- គេត្រូវសម្រួលការ ដោយសារកិច្ចការនេះត្រូវធ្វើដោយបន្ទាន់។
- ដោយលេសថាវាឈឺ ទើបវាពុំធ្វើអ្វីទាំងអស់។

គេអាចប្រើដូចនេះ៖

- ព្រោះមេឃត្រជាក់ខ្លាំង ទើបឯងត្រូវរុំខ្លួនឱ្យជិត។
- ដោយសារតែកិច្ចការនេះត្រូវធ្វើបន្ទាន់ ទើបគេត្រូវសម្រួលទម្រង់ការ។

- វានៅទីនោះពុំមែនដោយសារទីនោះមានខ្យល់ល្អទេ តែដោយសាទីនោះជាភូមិកំណើតរបស់វា។

**កំណត់សម្គាល់៖**

១. គេប្រើ «កិរិយានាម» ជំនួសឃ្លាហេតុ កាលណាឃ្លារណប និងឃ្លាច្បងមានប្រធនដូចគ្នា៖

- វាមិនធ្វើការអ្វីសោះ ព្រោះឈឺ។
- គាត់ហេវហត់ខ្លាំង មកពអំពីធ្វើការច្រើន។

២. ហេតុអាចសម្តែងឡើងដោយកន្សោមនាម៖

- វាញ័រដោយរងារ។
- វាប្រឡងជាប់ ព្រោះសេចក្តីព្យាយាម។

### ៣.២.៤.២.៤- ឃ្លាទេសកាលទំនាស់ ឬឃ្លាទំនាស់

ឃ្លាទំនាស់សម្រាប់ចង្អុលបង្ហាញអំពើទំនាស់ឬផ្ទុយនឹងអំពើក្នុងឃ្លាច្បង។ វាផ្តើមដោយឈ្នាប់ឃ្លា « ទោះបី ទោះតែ ថ្វីត្បិត សូម្បី»៖

- ទោះបីវាឈឺក្បាល វានៅតែបន្តការងាររបស់វាតទៅទៀត។
  (វាឈឺក្បាល ប៉ុន្តែវានៅតែធ្វើការ)
- ទោះបីមេឃភ្លៀងយ៉ាងណាក៏ដោយ កសិករក៏នៅតែដកសំណាបញាប់ដៃដដែល។
- ថ្វីត្បិតតែយើងរៀនចេះច្រើន តែយើងត្រូវគោរពប្រជាជន។

កំណត់សម្គាល់៖

១.គេប្រើ «យ៉ាងណាក៏ដោយ....(ក៏)» បន្ថែមលើឈ្នាប់ឃ្លាដើម្បីបញ្ជាក់ឱ្យរឹតតែដឹងច្បាស់៖

- ទោះឯងប្រើកម្លាំងយ៉ាងណាក៏ដោយ ឯងពុំអាចសម្រេចបំណងទេ។
- ទោះគាត់ក្រយ៉ាងណាក៏ដោយ ស្មារតីតស៊ូរបស់គាត់នៅរឹងប៉ឹងជានិច្ច។

២. គេអាចប្រើ «កិរិយានាម» កាលណាមានប្រធានដូចគ្នា៖

- ទោះបីក្រ គាត់តែងរក្សាស្មារតីបដិវត្តបានល្អជានិច្ច។

៣. កន្សោមអាចសម្តែង «ទំនាស់»។

- ខ្ញុំត្រូវតែទៅ ទោះឧបសគ្គក៏ដោយ។
- យើងត្រូវតែប្រយុទ្ធ ទោះចក្រពត្តិក៏ដោយ។

៤. បើពាក្យ «.....នរណាក៏ដោយ....ក៏....»

- ទោះគាត់ជានរណាក៏ដោយ ខ្ញុំក៏ពុំខ្លាចគាត់ដែរ។
- ទោះនរណាក៏ដោយ(ទោះអ្វីក៏ដោយ) ខ្ញុំក៏ពុំញញើតដែរ។

៥. ល្បះទោលក៏អាចបញ្ជាក់ទំនាស់បានដែរ៖

- ឯងធ្វើតាមឯងចង់ ឱ្យតែយើងបានល្អ។
- វាដើរចេញទៅ ដោយគ្មាននរណាចាប់ភ្លឹកឡើយ។

**៣.២.៤.២.៦- ឃ្លាទេសកាលបន្ថែម ឬឃ្លាបន្ថែម**

- ថែមលើវាឧស្សាហ៍ វាមានប្រាជ្ញាទៀត។
- ជាមួយនឹងវាខ្ជិល វាល្ងង់ថែមទៀត។

**៣.២.៤.២.៧- ឃ្លាទេសកាលលើកលែង ឬឃ្លាលើកលែង**

- វាមានគុណសម្បត្តិសព្វគ្រប់ លើកលែងតែវាខ្ជិលបន្តិច។
- គាត់ស្គាល់គ្រប់កន្លែង លើកលែងតែកន្លែងណាមានព្រៃភ្នំ។

**៣.២.៤.២.៨- ឃ្លាទេសកាលវិបាក ឬឃ្លាវិបាក**

ឃ្លាវិបាកសម្រាប់ប្រាប់អំពើដែលជាវិបាកនៃអំពើសម្ដែងឡើងក្នុងឃ្លាច្បង។ វាផ្ដើមដោយឈ្នាប់ឃ្លា « ទាល់តែ រហូតដល់ ដល់ រហូត»។

ឧទាហរណ៍៖

- គាត់ខំធ្វើការ រហូតដល់គាត់ខ្យល់ចាប់។
- វានៅតែក្នុងផ្ទះ រហូតវាឈឺ។
- រឿងនេះអច្ឆរិយៈហួសហេតុ ទាល់តែគេជឿគ្រប់គ្នា។

**កំណត់សម្គាល់៖**

១. «វិបាក»អាចសម្ដែងដោយកន្សោម៖

- គាត់ត្រូវបួសដល់ស្លាប់។
- វាផឹកកាផេទាល់តែឆ្អែត។
- វាឃ្លានបានជាយំ។

២. ល្បះដាក់បន្តគ្នា៖

- វាដើរលឿន ខ្ញុំពុំអាចតាមទាន់ទេ។
- វានិយាយតិចពេក គេស្ដាប់មិនឮសោះ។

**៣.២.៤.២.៩- ឃ្លាទេសកាលប្រៀបធៀប ឬឃ្លាប្រៀបធៀប**

ឃ្លាប្រៀបធៀបចង្អុលបង្ហាញទំនាក់ទំនង៖ ដូចគ្នា ស្មើគ្នា ផ្សេងគ្នា ឬសមាមាត្រនឹងគ្នារវាងអំពើដែលឃ្លារណបសម្ដែងលើង និងអំពើដែលឃ្លាច្បងសម្ដែងឡើង។

វាផ្ដើមដោយឈ្នាប់ឃ្លា«ដូច ដូចជា ស្មើគ្នានឹង ប៉ុនគ្នានឹង ដូចគ្នានឹង...»៖

- ខ្ញុំស្រលាញ់ប្រទេសខ្ញុំ ដូចអ្នកឯងស្រឡាញ់ប្រទេសអ្នកឯងដែរ។
- នាងតូចនេះយោលកូនក្រមុំ ដូចជាម្ដាយយោលទារក។

- វាគោរពឪពុកម្ដាយវា ស្មើគ្នានឹងវាស្រឡាញ់គាត់។

**កំណត់សម្គាល់៖**

១.កន្សោមប្រាប់ «ការប្រៀបធៀប»៖

- វាមានប្រាជ្ញាដូចបងវា(ដូចបងវាប្រាជ្ញា)។
- គាត់ស្រឡាញ់នំដូចផ្លែឈើ(ដូចគាត់ស្រឡាញ់ផ្លែឈើ)។
- វាពូកែជាងមិត្តវា(ជាងមិត្តវាពូកែ)។

### ៣.២.៤.២.១០- ឃ្លាទេសកាលបំណើ ឬឃ្លាបំណើ

ឃ្លាបំណើសម្រាប់បង្ហាញលក្ខខ័ណ្ឌណាដែលអាចនាំឱ្យកើតឡើងនូវអំពើក្នុងល្បះច្បង(ល្បះគោល)។ វាផ្ដើមដោយចំណងឃ្លា«បើ បើសិន បើសិននា បើសិនណាជា ប្រសិន ប្រសិនបើ ក្នុងលក្ខខណ្ឌ...»៖

- បើមិត្តខ្ញុំមកយើងលេងបាល់។
  (បច្ចុប្បន្នទម្លាប់៖ នៅគ្រប់ពេលដេលមិត្តខ្ញុំមកយើងលេងបាល់(រាល់ដង))
- បើឯងប្រឡងជាប់ យើងនឹងសប្បាយទៅហើយ។

**កំណត់សម្គាល់៖**

១.សង្កេត

| | ឃ្លាបំណើ | ឃ្លាច្បង |
|---|---|---|
| យថាភាពក្នុងបច្ចុប្បន្ន | បើ+ប្រ+កិ | ប្រ+កិ |
| អតថភាពក្នុងបច្ចុប្បន្ន | បើ+ប្រ+កិ | ប្រ+នឹង+កិ |
| អតថភាពក្នុងអតីត | បើ+ប្រ+បាន+កិ | ប្រ+នឹង+បាន+កិ |

| ក | ខ | គ |
|---|---|---|
| ខ្ញុំនិយាយថា | បើវាមក | យើងនឹងលេងបាល់ |

បើធៀបនឹក ក នឹង ខ,គ សម្ដែងអនាគត

២.សង្កេត

| ខ | គ | ក |
|---|---|---|
| បើវាបានប្រឡងជាប់ | យើងនឹងបានសប្បាយ | ខ្ញុំនិយាយ |

បើធៀបនឹង «ខ»,«គ» សម្ដែងអនាគត។ តែបើធៀបនឹង «ក» វិញ«ខ» និង «គ» ជាអតីតរបស់ «ក» អំពើ «ខ» និង «គ» ពុំបានសម្រេចទេ។

៣. ប្រើពាក្យយ៉ាងខ្លីសម្គាល់ឃ្លាបំណើ៖

- ដើរឱ្យលឿន បើពុំដូចនោះទេឯងនឹងទៅពុំទាន់រថភ្លើងទេ។
  (បើពុំនេះទេ/បើមិនអ៊ីចឹងទេ)

៤. ឃ្លាបំណើកប់៖

- កុំរកអី ឯងរកពុំឃើញទេ (បើឯងរកវា ឯងរកវាពុំឃើញទេ)។

៥. ពាក្យសម្ដែង «បំណើ»៖

- ក្នុងករណីឈឺ ឯងទៅមន្ទីរពេទ្យ។
- ក្នុងករណីរវល់ ឯងពុំបាច់មកទេ។
- ក្នុងលក្ខខណ្ឌផ្សេងពីនេះ ឯងរួចខ្លួន។

*ក្នុងករណីឈឺ ក្នុងករណីរវល់ ក្នុងលក្ខខណ្ឌផ្សេងពីនេះ* ជាកន្សោមមានធ្នាក់កម្មទេសកាលប្រាប់បំណើ។ ប៉ុន្តែបើ *ក្នុងករណីឯងឈឺ ក្នុងករណីឯងរវល់* វិញ ជាឃ្លាទេសកាលប្រាប់បំណើ។

### ៣.២.៤.៣- គំនូសតាងល្បះ



### ៣.២.៥- កថាផ្ទាល់ និងកថាមិនផ្ទាល់

កាលណាគេនិយាយនឹងនរណាម្នាក់ គេតែងប្រើតំហា សេចក្ដីបញ្ជាក់ពីអ្វីមួយ( ល្បះបញ្ជាក់) ឬដែលសម្ដែងមនោសញ្ចេតនាភ្លាមៗ (ល្បះឧទាន)៖

- សំមកនេះ។ ឯងស្រឡាញ់គោនេះទេ?
- គោនេះស្អាតណាស់។ រូបវាសង្ហារអីម្ល៉េះទេ!

តំហាសេចក្ដីទាំងនេះ បង្កើតជា «កថា» ហើយ«កថា»នេះកំណត់ដោយចំណុចតម្រុយ៖

- ធៀបនឹងអ្នកនិយាយ «ខ្ញុំ» និងអ្នកនិយាយជាមួយ«ឯង វា»។
- ធៀបនឹងកន្លែងដែល «ខ្ញុំ» នៅ( ទីនេះ ទីនោះ)។
- ធៀបនឹងពេលដែល «ខ្ញុំ» និយាយ( ម្សិល ថ្ងៃនេះ ស្អែក)។

កថាមានពីរយ៉ាងសំខាន់គឺ ៖

- កថាផ្ទាល់ (រចនាបថផ្ទាល់)
- កថាមិនផ្ទាល់(រចនាបថមិនផ្ទាល់)

#### ៣.២.៥.១- កថាផ្ទាល់ (ឬរចនាបថផ្ទាល់)

កថាផ្ទាល់ គឺជាបែបបទម្យ៉ាងនៃការលើកយកសម្ដីអ្នកណាមកនិយាយឡើងវិញ។ កថាផ្ទាល់លើកសម្ដីទាំងស្រុងរបស់អ្នកណាម្នាក់ មកនិយាយឡើងវិញ ឱ្យបានដដូចសម្ដីដែលអ្នកនោះបាននិយាយរួចមកហើយ។ គេស្ដាប់ឮយ៉ាងណា គេលើកយកមកនិយាយយ៉ាងនោះ៖ ទាំងពេលវេលា បុរសនៃសព្វនាម។ កថាផ្ទាល់ឋិតនៅក្នុងក្បៀសបើកបិទ និងនៅខាងស្ដាំដំពីរ(៖)

- គាត់បាននិយាយប្រាប់ខ្ញុំថា គាត់បានទៅស្រែ ស្អែកឡើងគាត់ក៏នឹងបានទៅស្រែដែរ ឱ្យខ្ញុំទៅរកគាត់នៅទីនោះ។

ដើម្បីបំប្លែងកថាផ្ទាល់ទៅកថាមិនផ្ទាល់ យើងត្រូវ៖

- លុបចោល ដំពីរ(៖)
- ប្រើចំណងឃ្លា «ថា»
- ប្ដូរ បុរសទី១ →ទី៣ និងទី២ →ទី១ ។

**ពិនិត្យ**

| កថាផ្ទាល់ | | កថាមិនផ្ទាល់ |
|---|---|---|
| គាត់បាននិយាយប្រាប់ខ្ញុំ៖ «ខ្ញុំទៅស្រែស្អែកខ្ញុំក៏នឹងទៅស្រែដែរ ចូរឯងទៅរកខ្ញុំនៅទីនោះ»។ | → | គាត់បាននិយាយប្រាប់ខ្ញុំថា គាត់បានទៅស្រែ ស្អែកឡើងក៏នឹងបានទៅស្រែដែរ ឱ្យខ្ញុំទៅរកគាត់នៅទៅនោះ។ |

| | | |
|---|---|---|
| **បង្គាញ**<br>សម្ដីនាំមកជាល្បះទោល<br>**បុរស**<br>ខ្ញុំ<br>ឯង<br>**ពេលវេលា**<br>បច្ចុប្បន្ន<br>អនាគត | → | សម្ដីនាំមកជាឃ្លារណប ផ្ដើមដោយ «ថា»<br>គាត់<br>ខ្ញុំ<br>អតីត<br>អនាគតក្នុងអតីត |

### ៣.៣- ល្បះក្រង

ល្បះក្រងកើងឡើងសោយសារល្បះច្រើនៅបន្តបន្ទាប់គ្នា។ ល្បះនីមួយៗ ជាល្បះរង។ ល្បះរងអាចនៅបន្តបន្ទាប់គ្នាឬអាចភ្ជាប់គ្នាដោយសារ «ឈ្នាប់ចង» (តែ ប៉ុន្តែ និង ឬ)។ជាតុនៅក្នុងល្បះក្រង គេហៅថាល្បះរងទោះជាល្បះទោលក្ដី ឬល្បះផ្សំក្ដី។

#### ៣.៣.១- ល្បះរងភ្ជាប់ដោយសារ «ឈ្នាប់ចង»

ក្នុងល្បះនេះ

- សុកពូកែខាងគណិតវិទ្យា <u>តែ</u>វាខ្សោយខាងអក្សរសាស្ត្រ។

ល្បះរង ល្បះរង

ល្បះ «សុក ពូកែខាងគណិតវិទ្យា» ភ្ជាប់ទៅនឹងល្បះ «វាខ្សោយខាងអក្សរសាស្ត្រ» ដោយសារឈ្នាប់ចង «តែ»។

#### ៣.៣.២- ល្បះរងនៅបន្តបន្ទាប់គ្នា

ក្នុងល្បះនេះ

- មាន់រងាវ សេះកញ្ជ្រៀវ គោរោទ៍ ពេញវាលស្រែ។

ល្បះរង ល្បះរង ល្បះរង ល្បះរង

ល្បះនេះពុំមានចំណងទេ។ ល្បះរងដាក់បន្តបន្ទាប់គ្នាពីមួយទៅមួយ។

## ឯកសារពិគ្រោះ

១- ហាន សុខុម (១៩៩៨) *សទ្ទានុក្រមសព្ទទំនើប* : ភ្នំពេញ លីដេខ្មែរ។

២- ឈុន លិះ (២០០៧) *វេយ្យាករណ៍ខ្មែរ សម្រាប់គ្រប់ថ្នាក់* : ភ្នំពេញ បណ្ណាគារបន្ទាយស្រី ។

៣- វ៉ា សោភា (២០១១) *ថ្នាក់ពាក្យ* ភ្នំពេញ : សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

៤- សូ មុយឃៀង (២០១៦) *មេរៀនសម្ព័ន្ធវិទ្យា* ភ្នំពេញ : សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។